ឯកសារប្រវត្តិសាស្ត្រ

# អៀវ-កើស

## អំពីបទល្មើស
## «ឃាតកម្មឯ.ឧ. អៀវ-កើស និង
## បំណងធ្វើឃាតកម្មលោក ទេ៉ត-ហ៊ាន»

នៅថ្ងៃ១៨ មករា ១៩៥០ វេលាម៉ោង២០
ក្នុងមន្ទីរចាត់ការគណបក្សប្រជាធិបតេយ្យ
ផ្ទះលេខ៦៦ វិថីពីកេ ទីក្រុងភ្នំពេញ
ប្រទេសកម្ពុជា

ការផ្សាយរបស់សារព័ត៌មានអង្គរបុរី
ព.ស.២៥៤៩ - គ.ស.២០០៥

# ជីវប្រវត្តិ
# លោក អៀវ~កើស



លោក **អៀវ~កើស** មានត្រកូល **អៀវ** បិតារបស់លោកនាម **ហេង** និងមាតារបស់លោកនាម **ទឹក** មានលំនៅៗឃុំសង្កែ ស្រុកសង្កែ ខែត្របាត់ដំបង ។ លោក អៀវ-កើស ប្រសូតក្នុងខែមករា គ.ស.១៩០៥ ។ កាលនៅពីក្មេង លោកបានចូលទៅរៀនអក្សរនៅឯវត្តកណ្ដាល តមកបានចូលរៀននៅឯសាលាបថមសិក្សាក្នុងទីរួមខែត្របាត់ដំបងនៅគ.ស.១៩១៨, លោកបានប្រឡងចូលរៀននៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ នៅក្នុងគ.ស.១៩២១, ប្រឡងជាប់សញ្ញាប័ត្រនៅទីនោះ ហើយក៏បានចូលទៅរៀននៅឯសាលាសិក្សាជាន់ខ្ពស់ខាងជំនួញ នៅឯទីក្រុងហាណូយ, នៅទីនោះ លោកបានប្រឡងជាប់សញ្ញាប័ត្រខាងជំនួញនៅក្នុងគ.ស. ១៩២៧ ។

ក្រោយបានបញ្ចប់ការសិក្សា លោកបានមកធ្វើការនៅផ្ទះជំនួញ ដឺនីប្រែ នៅឯក្រុងភ្នំពេញ ចាប់ពីខែសីហាដល់ខែតុលាគ.ស.១៩២៧ ។ ចេញពីនេះ លោកបាន

ទៅធ្វើជាលេខាធិការផ្ទាល់របស់លោកចាងហ្វាងចំការកៅស៊ូនៅឯមេមត់ ចាប់ពីខែតុលា ឆ្នាំដដែល ដល់ខែមិនា គ.ស.១៩២៨ ។ តមកលោកបានធ្វើជាសហាគ្រិន (អ្នកទទួលម៉ៅការ) ក្នុងទីនោះរហូតមកដល់គ.ស.១៩៣៧ ។ នៅឆ្នាំនោះ លោកបានចេញពីមេមត់ ត្រឡប់ទៅធ្វើជាសហាគ្រិនក្នុងក្រសួងសាធារណការខេត្របាត់ដំបងវិញ ។

មកដល់គ.ស.១៩៤០ លោកបានធ្វើជាសមាជិក រួចហើយធ្វើជាលេខាធិការនៃសភាតំណាងរាស្រ្ត (Chambre de représentant) តមកលោកបានធ្វើជាសមាជិករងនៃគណៈកម្មាការចម្រុះក្រុមមហាប្រឹក្សាភិបាល សំរាប់ការពារផលប្រយោជន៍ខាងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រទេសឥណ្ឌូចិន ។ តមកទៀត លោកបានធ្វើជាសមាជិកនៃគណៈកម្មាការចម្រុះនៅអមរដ្ឋាភិបាលខ្មែរ ។

មកដល់គ.ស.១៩៤៥ លោកបានធ្វើជាឧបរដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច, នៅគ.ស.១៩៤៦ បានធ្វើជាប្រធានរដ្ឋសភាបណ្តោះអាសន្ន, នៅគ.ស.១៩៤៧ លោកបានទទួលជ្រើសតាំងជាប់ឆ្នោតជាតំណាងរាស្រ្ត នៅមណ្ឌលរាជធានីភ្នំពេញ ផ្នែកទក្សិណ ហើយបានទទួលជ្រើសតាំង ជាប្រធានរដ្ឋសភា រហូតមកដល់ថ្ងៃទី១៨ ខែកញ្ញា គ.ស.១៩៤៩ (កាលបរិច្ឆេទរំលាយរដ្ឋសភា) ។ ក្រៅពីនេះ លោកបានទទួលធ្វើជាអគ្គលេខាធិការនៃគណបក្សប្រជាធិបតេយ្យ, ជាសមាជិកគណៈកម្មាការវប្បធម៌, និងជាទីប្រឹក្សាអមសមាគមមិត្រសាលាបាលីទៀតផង ។ល។

លោក អៀវ-កើស អាចរាប់បានថាជាអ្នកប្រាជ្ញខាងអក្សរសាស្រ្តខ្មែរមួយរូបដែរ ដែលលោកមានចំណេះយ៉ាងជ្រៅជ្រះ ទាំងខាងភាសាបារាំង-ខ្មែរ ទាំងខាងភាសាសៀម-បាលី-សំស្រ្កឹត ហើយនិងជាអ្នកដែលឧស្សាហ៍រិះរកហេតុផលក្នុងភាសាជាតិ ។ លោកបានចងក្រងដោយយកចិត្តទុកដាក់នូវសៀវភៅជាភាសាខ្មែរ (ការសាកល្បងពិនិត្យដោយរកហេតុផល), លោកជាមនុស្សដំបូងនៅស្រុកខ្មែរដែលបានផ្តើមគំនិតរាវរករៀបចងក្រងនូវក្បួនជវលេខខ្មែរ និងការកែប្រែអក្សរសំរាប់អង្គុលីលេខ ដែលលោកបានធ្វើការរួមជាមួយគណៈកម្មាការវប្បធម៌ ។ លោកបានចូលរួមយ៉ាងសកម្ម ហើយយ៉ាងយកចិត្តទុកដាក់ក្នុងការធ្វើសេចក្តីព្រាងច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ជារបៀបរបបប្រជាធិបតេយ្យ ជាមួយនឹងឥស្សរជនខ្មែរឯទៀតៗ មានជាអាទិ៍អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ-យុត្តិវង្ស ជាដើម ។ល។

លោក អៀវ-កើស ជាបុគ្គលដែលចូលចិត្តគិតវែងឆ្ងាយដល់សង្គម និងប្រជាពលរដ្ឋខ្មែរ ដែលលោកចង់បង្ហាញឲ្យមាតុប្រទេសរបស់លោក និងជនរួមជាតិអំពីវិជ្ជាខាងរដ្ឋធម្មនុញ្ញ ខាងរបបប្រជាធិបតេយ្យ ហើយនឹងខាងរបបនិតិរដ្ឋ, លោកបានខិតខំចងក្រងសេចក្តីអធិប្បាយរដ្ឋធម្មនុញ្ញមួយច្បាប់ ដែលលោកបាន

សរសេរដោយយកចិត្តទុកដាក់ចង់ឲ្យជនរួមជាតិរបស់លោកអាន ឲ្យយល់ដឹងដោយងាយ នូវសេចក្តីពិស្តារអំពីរដ្ឋធម្មនុញ្ញ សិទ្ធិសេរីភាព និងរបបប្រជាធិបតេយ្យ, លោកបានសរសេរចងក្រងនូវរបៀបរបប និងបទបញ្ជាសំរាប់រដ្ឋសភាមួយចំនួន។

នៅក្នុងវេលា ដែលលោកបានអញ្ជើញទៅធ្វើទស្សនកិច្ចប្រទេសបារាំង លោកបានស្រាវជ្រាវរកប្រមូលលក្ខន្តិក:របស់គណបក្សនយោបាយនានា ដែលលោកបានដកស្រង់យកមករៀបរៀងកែប្រែលក្ខន្តិក:របស់គណបក្សប្រជាធិបតេយ្យជាថ្មី ។

លោកអៀវ-កើស អាចរាប់បានជារដ្ឋបុរសម្នាក់ នៅក្នុងចំណោមរដ្ឋបុរសរបស់ខ្មែរ ដែលមានចិត្តស្នេហាជាតិមាតុភូមិ និង គោរពព្រះពុទ្ធសាសនា ហើយនិងមានសេចក្តីស្មោះបំផុត ចំពោះគោលការណ៍ប្រជាធិបតេយ្យនិងសិទ្ធិមនុស្សលោក ។ ដោយសារតែយល់ច្បាស់ថា សិទ្ធិរបស់មនុស្សលោកមានខ្លឹមសារសំខាន់យ៉ាងនេះហើយ បានជានៅក្នុងអំឡុងដើមគ.ស១៩៣០ លោកហ៊ានប្តឹងជាតិបារាំងនៅកម្ពុជា ដែលបានប្រមាទលើរូបលោក ដោយសេចក្តីប្រកាន់ពណ៌សំបុរ និងជាតិសាសន៍ លោកហ៊ានតវ៉ាទៅតុលាការដែលមានបារាំងជាអ្នកត្រួតត្រា ហើយក៏ប្តឹងឈ្នះជាតិបារាំងម្នាក់នោះ ឲ្យអ្នកចុងចោទនោះទទួលសងជម្ងឺចិត្តដល់រូបលោក, ហេតុការប្តឹងប្តល់អញ្ចឹងមិនដែលមាននរណាហ៊ានសូវធ្វើទេ ជាពិសេសនៅក្នុងសម័យកាលដែលបារាំងគេជាអាណាព្យាបាលលើប្រទេសកម្ពុជា ។

លោក អៀវ-កើស ក្រោយពីកាលបរិច្ឆេទរំលាយរដ្ឋសភាមក លោកបានដង្ហែរព្រះមហាក្សត្រខ្មែរ ទៅធ្វើទស្សនកិច្ចប្រទេសបារាំង ហើយត្រឡប់មកប្រទេសកម្ពុជាវិញនៅថ្ងៃទី៥ ខែមករា គ.ស.១៩៥០ ។ នៅក្នុងឱកាសដែលលោកអញ្ជើញមកដល់ ចំពប់លើពេលដែលរដ្ឋាភិបាលបច្ចុប្បន្ននោះចាត់ការប្រជុំមេគណបក្សនានាក្នុងប្រទេស ដើម្បីប្រកបការកែប្រែរដ្ឋធម្មនុញ្ញ ។ លោកអៀវ-កើស ដែលជាតំណាងគណបក្សប្រជាធិបតេយ្យ បានជំទាស់ជាដាច់ខាតមិនព្រមកែប្រែដោយមានយោបល់ថា «មានតែរដ្ឋសភាប៉ុណ្ណោះទេ ដែលមានសិទ្ធិកែប្រែរដ្ឋធម្មនុញ្ញបាន» នេះជាលើកដំបូង ។ នៅពេលប្រជុំលើកក្រោយ លោកពុំបានចូលប្រជុំផងទេ គ្រាន់តែបានជូនដំណឹងដល់រដ្ឋាភិបាលថាបើរដ្ឋាភិបាលអាចអះអាង ជាលាយលក្ខណ៍អក្សរថា គ្រាន់តែធ្វើជាសេចក្តីស្នើច្បាប់ទុកឲ្យរដ្ឋសភាលើកក្រោយលោកពិនិត្យ នោះទើបគណបក្សប្រជាធិបតេយ្យចូលរួមប្រជុំជាមួយ ។

សេចក្តីជំទាស់ដែលលោកអៀវ-កើស បានលើកឡើងនេះបានធ្វើឲ្យមតិខាងគណបក្សនយោបាយនានានៅកាលនោះ មានការមិនសប្បាយចិត្តជាខ្លាំង ជាពិសេសខាងក្រុមនិយមលទ្ធិផ្តាច់ការតាមបែបសក្តិភូមិជាន់ចាស់, ពួកគេបានឆ្លៀតឱ

កាសដែលលោកអញ្ជើញទៅប្រទេសបារាំងបាត់ ក៏ពួកគេឃុបឃិតយកចិត្តគ្នារៀបចំប្រុងនឹងកែប្រែរដ្ឋធម្មនុញ្ញនេះ ឲ្យបានទៅតាមបំណងរបស់ពួកគេ ដែលមិនសូវចង់ឲ្យប្រទេសជាតិប្រជាជន បានទទួលនូវសិទ្ធិសេរីភាពទូលំទូលាយ តាមរបបប្រជាធិបតេយ្យឡើយ ។

នៅពេលព្រះអាទិត្យអស្តង្គតក្នុងថ្ងៃសៅរ៍ ទី១៤ ខែមករា គ.ស.១៩៥០ រវាង ១០ថ្ងៃ ក្រោយដែលបានអញ្ជើញមកដល់មាតុភូមិវិញ លោកអៀវ-កើស ត្រូវគេពិឃាតដោយគ្រាប់បែកដៃ នៅទីស្នាក់ការគណបក្សប្រជាធិបតេយ្យ លេខ៦៦ វិថីពីកេ ក្រុងភ្នំពេញ ក្រោយបន្ទាប់ពីពេលប្រជុំគណៈកម្មាធិការនាយកពិនិត្យមើលសេចក្តីកែប្រែលក្ខន្តិកៈរបស់បក្សមក ។

គួរឲ្យអាសូរពន់ពេកណាស់ ! លោកអៀវ-កើស នៅខណៈនោះ ប្រហែលជាលោកបានជ្រាបថា ជីវិតលោកត្រូវនឹងក្ស័យរលត់ព្រោះតែនយោបាយ ទើបបានជាមុនពេលដែលលោករលត់ស្មារតី លោកបានផ្ញើរប្រាប់លោក ង៉ែត-ហ៊ាន ដែលបានទទួលរងគ្រោះជាមួយគ្នានោះថា «អ្នកនយោបាយស្រុកខ្មែរ...លេងដល់ម្លឹង !... ខ្ញុំមិនរស់ទេ លោកង៉ែត-ហ៊ាន... កុំធ្វើអាឃាដតបដល់អ្នកដែលព្យាបាទខ្ញុំ» នេះជាពាក្យចុងក្រោយរបស់លោកអៀវ-កើស ។

គេបាននាំលោកទៅមន្ទីរពេទ្យព្រះកេតុមាលា តែពុំទាន់ដល់ទៅទីនោះផងលោកក៏អស់សង្ខារតាមផ្លូវទៅ ។ លុះដល់មន្ទីរពេទ្យមួយស្របក់ គេក៏នាំសពលោកមកកាន់ភូមិចាស់របស់លោកវិញ តំកល់សពនៅទីនោះរវាងមួយអាទិត្យទើបដង្ហែរសពលោកទៅបូជានៅឯវត្តបទុមវត្តី ។ កាលនោះមនុស្សរាប់មិនដឹងប៉ុន្មាននាក់ទេ ដែលបានមកចូលរួមក្នុងពិធីដង្ហែរសពនេះ ។

គួរឲ្យអស្ចារ្យណាស់ ! ក្នុងឱកាសបូជាសពលោក ស្រាប់តែមេឃមីរងងឹតខ្វលខ្វាញ់មួយរំពេច ហាក់ដូចជាសំដែងឲ្យឃើញថា ទេពតាលោកក៏បានយាងមកចូលរួមក្នុងទុក្ខព្រួយយ៉ាងធ្ងន់នេះ ហើយភ្លៀងយ៉ាងធំមហិមា កាត់ទឹកភក់ពាសពេញទីនោះ ។៚

---

យោងតាមឯកសារដើមរបស់លោក ម៉ិញ-ណាគ្រី និងកំណាត់ហេតុបទសំភាសន៍អតីតសមាជិកគណបក្សប្រជាធិបតេយ្យ និងសេចក្តីកែសម្រួលកត់ត្រាទុកដោយ សុខ សុគន្ធ ។

⌘

⌘ ⌘

# អំពីប្រវត្តិនៃលទ្ធិយុវប្រជាធិបតេយ្យខ្មែរ និងបទល្មើសឃាតកម្មឯ.ខ្ញ. អៀវ-កើស (១៤ មករា គ.ស.១៩៥០)

## (សង្ខេប)

កាលពីចុងឆ្នាំ១៩៤៦ មានការបើកឱកាសឲ្យបោះឆ្នោតជាសកល ដើម្បីជ្រើសតាំងសភាតំណាងរាស្ត្របណ្តោះអាសន្ន តាមព្រះរាជបំណងនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។

នេះជាជំហានជឿនដំបូងរបស់ប្រជារាស្ត្រខ្មែរ, វរជនបាននាំគ្នាចាប់ឆ្នោតដោយសេចក្តីស្រឡាញ់វិជ្ជាឧត្តមគតិផ្សេងៗខ្លួនគឺ ៖

ស្រឡាញ់គណបក្សប្រជាធិបតេយ្យ របស់អ្នកអង្គម្ចាស់ស៊ីសុវត្ថិ-យុត្តិវង្ស ឬស្រឡាញ់គណៈសេរីភាព របស់ព្រះអង្គម្ចាស សុទ្ធវង្ស-នរិន្ទតេជ ។

ប្រជារាស្ត្រវិញមិនមែនដូច្នោះទេ, គឺគេចាប់ឆ្នោត រូបក្បាលដំរីកាន់ឈូក៣ ឬគេចាប់ឆ្នោតរូបប្រាសាទ ។

កាលនោះ គណបក្សប្រជាធិបតេយ្យបាន៥០មណ្ឌល គណបក្សសេរីភាពបាន ១៤ ឯកច្ឆ័ន្ទបាន៣ គណៈចំរើនជាតិគ្មានសោះ ។

ក្នុងគ្រានោះ មិនមែនតែសម្តេចក្រុមព្រះ ស៊ីសុវត្ថិ-មុនីរេត ទ្រង់ជាប្រមុខរដ្ឋនៃរដ្ឋាភិបាល មានអំណាចពេញទីតែឥតគណបក្ស ទើបអ្នកអង្គម្ចាស់ស៊ីសុវត្ថិ-យុត្តិវង្ស ទីប្រឹក្សានយោបាយនៃគណបក្សប្រជាធិបតេយ្យដែលបានបោះឆ្នោតភាគច្រើន នោះស្រាប់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះនរោត្តម-សីហនុ ទ្រង់ឲ្យរៀបចំរដ្ឋាភិបាលជាថ្មីឡើង ។

ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជជាព្រះមុខនៃគណៈរាស្ត្រសេរីភាព ដែលមានឆ្នោតភាគតិច ទ្រង់មិនព្រមទទួលធ្វើការជាមួយនឹងរដ្ឋាភិបាលថ្មីនោះ មិនចូលជាសេចក្តីជិទាស់ទេ ។

ដល់ពេលបោះឆ្នោតក្នុងឆ្នាំ១៩៤៧ គណបក្សប្រជាធិបតេយ្យបាន៥៤មណ្ឌល, គណៈរាស្ត្រសេរីភាពបាន២០, គណៈដទៃទៀតគឺគណៈចំរើនជាតិ, គណៈខេមរប៉ុណ្ណាកា, គណៈរួមជាតិ, គ្មានមួយមណ្ឌលសោះ ។

ទើបព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ព្រះមេត្តាប្រោសឲ្យគណបក្សប្រជាធិបតេយ្យ ចាត់តាំងគណៈរដ្ឋមន្ត្រីជាសភា (សមាជិករដ្ឋមន្ត្រីសុទ្ធតែពួកប្រជាធិប

តេយ្យទាំងអស់ ក្រោមអធិបតីភាពនៃឯ.ឧ. ឈាន-វ៉ំម ។

គណៈរាស្ត្រសេរីភាពឥតបានតវ៉ាជំទាស់អំពីរឿងនេះ តែបន្តិចបន្តួចក៏គ្មាន ។

គ្រានោះឯ.ឧ.យ៉ែម-សំបូរ ជាតំណាងរាស្ត្រប្រជាធិបតេយ្យ ធ្វើជារដ្ឋលេខាធិការនិងនាយកក្រុមព្រះនគរបាលជាតិ បានរកឿងហេតុអំពីមន្ត្រីជាន់ខ្ពស់ខ្លះក្នុងគណបក្សរបស់ខ្លួន ។

ហេតុនេះហើយ បានជាមានការមិនស្រុះស្រួលគ្នាក្នុងគណបក្សប្រជាធិបតេយ្យ ទើបឯ.ឧ.ឈាន-វ៉ំម បានសុំលាចេញពីតំណែង ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់តម្រូវឯ.ឧ.ប៉ែន-នុត ជាទីប្រឹក្សានយោបាយនៃគណបក្សប្រជាធិបតេយ្យពេលនោះ នៅធ្វើជាចៅហ្វាយក្រុង ក្រុងភ្នំពេញនៅឡើយ ឲ្យចាត់តាំងរដ្ឋាភិបាលឡើង, ឯ.ឧ.ប៉ែន-នុតមិនបាននឹកនាដល់ឯ.ឧ.យ៉ែម-សំបូរ ។

ដូច្នេះហើយបានជាឯ.ឧ.យ៉ែម-សំបូរនិយាយពាក្យទ្រគោះបោះពាក្យសំដីមិនជាគួរគប្បី ចំពោះឯ.ឧ.ប៉ែន-នុត ដែលជាហេតុនាំឲ្យគំនិតយោបល់ខ្វែងគ្នា ក្នុងក្រុមឯ.ឧ.ប៉ែន-នុត, អៀវ-កើស ហើយកើតមិនចុះសំរុងគ្នាឡើងក្នុងក្រុមឯ.ឧ.អៀវ-កើស និងក្រុមឯ.ឧ.យ៉ែម-សំបូរ ។ ឯ.ឧ.យ៉ែម-សំបូរបានបំបែកគណៈហើយបង្កើតឲ្យមានពួកក្រុមប្រឆាំងក្នុងគណៈឡើង ។

រួចតមកមិនបានយូរប៉ុន្មាន ក៏បានផ្ដួលរដ្ឋាភិបាលឯ.ឧ.ប៉ែន-នុត ដោយបានជំនួយ២០ឆ្នោតអំពីពួកសមាជិករដ្ឋសភាខាងសេរីភាព ។

ដោយឯ.ឧ.អៀវ-កើសបានជំទាស់ បណ្ដាលឲ្យឯ.ឧ.យ៉ែម-សំបូររើសសមាជិករដ្ឋមន្ត្រីលើកទី១មិនបានសំរេច ។

ទើបអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ-ឥន្ទ្ររាវង្ស ក៏ពុំអាចតាំងគណៈរដ្ឋមន្ត្រីបានសំរេចទៀត ។ តមកឯ.ឧ.អៀវ-កើសបានជំទាស់នឹងការជ្រើសតាំងរដ្ឋមន្ត្រី ឯ.ឧ.យ៉ែម-សំបូរម្ដងទៀត លុះត្រាតែព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់សំរុះសំរួល កុំអីឯ.ឧ.យ៉ែម-សំបូរ រើសសមាជិករដ្ឋមន្ត្រីមិនបានសំរេចទៀត ។

ក្រោយកាន់កាប់អំណាចបានក្នុងរវាង២-៣ខែ, ឯ.ឧ.យ៉ែម-សំបូរជាមេគណបក្សប្រជាធិបតេយ្យ ដែលចែកចេញទៅបានសុំដកអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រខាងគណបក្សប្រជាធិបតេយ្យខ្លះ ដើម្បីធ្វើប្រទេសឲ្យរាបសារល្អ ឬដើម្បីរំសាយសេចក្ដីព្យាបាទរបស់ខ្លួនក៏ពុំដឹង ។

ដោយការប្រកាន់គណបក្ស សមាជិករដ្ឋសភាភាគច្រើនបានបដិសេធអហង្ការមិនព្រមទទួលពាក្យសុំរបស់ឯ.ឧ.យ៉ែម-សំបូរ ។

ឯគណៈរាស្ត្រសេរីភាព ដែលមានសមាជិកភាគតិច បានតាំងខ្លួនជាអព្យាក្រឹត្យ។

ឮថាឯ.ឧ.យ៉ែម-សំបូបានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងសូ

មអំណាចពេញទី ដើម្បីចាប់ចងពួកឥស្សរជននិងពួកប្រជាធិបតេយ្យធំៗ ដែលមិនមែនជាអ្នកបំបែកគណៈ ។

តាមពាក្យចចាមអារាម គេនឹងចាប់មន្ត្រីធំម្នាក់ ដែលជាហេតុនាំឲ្យលោកស្រីម្នាក់ត្រូវជាមាតារបស់មន្ត្រីធំនោះ ទទួលអនិច្ចកម្មទៅ ព្រោះក្នុងពេលនោះលោកស្រីកំពុងមានជម្ងឺជាទម្ងន់ ។

ដោយហេតុសេចក្ដីការពារទុកជាមុន បានជាមានសមាជិកគណបក្សប្រជាធិបតេយ្យមួយក្រុមមាន ឯ.ឧ.ហាក់-ម៉ុងសេងជាដើម បានធ្វើញត្តិមួយបន្ទោសដល់រដ្ឋាភិបាល ជូនទៅរដ្ឋសភា ដើម្បីរំលំរដ្ឋាភិបាលយ៉ែម-សំបួរ ។

ឯ.ឧ.យ៉ែម-សំបួរបានដឹងមុនទើបក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង អំពីពេលមុនថ្ងៃជំនុំរដ្ឋសភា សូមទ្បាយព្រះហត្ថក្នុងព្រះរាជក្រឹត្យដែលទុកដូចជារន្ទះ ដើម្បីបាញ់រំលាយរដ្ឋសភា នៅថ្ងៃទី១៨ កញ្ញា ឆ្នាំ១៩៤៩ តាមបញ្ញត្តិប្រកាស ៣៨ ដោយឥតមានលក្ខណ៍ក្រឹត្យទុក ។

ឯ.ឧ.អៀវ-កើសបានទទួលធ្វើជានាយករដ្ឋមន្ត្រីបណ្ដោះអាសន្នដោយស្វ័យប្រវត្តិ ដើម្បីរង់ចាំការបោះឆ្នោតជាថ្មី ដែលត្រូវចាត់ចែងក្នុងរយៈកាលកំណត់២ខែ ។ ឯ.ឧ.បានចាត់តាំងឯ.ឧ. សុន-វឹនសៃ ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ប៉ុន្តែអស់ឯ.ឧ. និងអស់លោកចៅហ្វាយខេត្ត ដែលបានឲ្យអញ្ជើញចូលមកក្រោយពេលដែលរដ្ឋសភារលាយទៅហើយនោះ បានជូនយោបល់មូលមាត់គ្រប់គ្នា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រពុំអាចធ្វើទៅបានដោយមានសេចក្ដីអសន្តិសុខទូទៅ ។

ពេលនោះឯង ហាក់ដូចជាមានគេប្រើអ្នករាជការម្នាក់ឲ្យដើរទៅ បញ្ចុះបញ្ចូលអស់ឯ.ឧ.និងអស់លោកចៅហ្វាយខេត្តមុនពេលជំនុំ ។

តាមពិត ក្នុងសម័យនោះ អសន្តិសុខមានមែន តែមានដោយអន្លើៗទេ ។ តាំងពីពេលនោះមក ស្ថានការណ៍របស់ប្រទេសកាន់តែដុនដាប់ទៅជាលំដាប់ ។ រដ្ឋាភិបាលក៏បានដឹង ទុកជាមិនបាច់ពិគ្រោះសួរចៅហ្វាយខេត្តក៏នឹងដឹងបានដែរ ។ ការពិគ្រោះសួរនេះគ្រាន់តែជាគំរប់ការប៉ុណ្ណោះ ។

ដោយបានទទួលដំណឹងពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ថាទ្រង់នឹងទទួលការខុសត្រូវក្នុងការជ្រើសតាំងរដ្ឋាភិបាលថ្មីនោះ ឯ.ឧ.អៀវ-កើសក៏បានក្រាបបង្គំទូលសូមព្រះ ព្រះរាជានុញ្ញាតលាឈប់ពីតំណែងនាយករដ្ឋមន្ត្រីបណ្ដោះអាសន្ន ទើបព្រះមហាក្សត្រជាអម្ចាស់ជីវិតលើត្បូង ទ្រង់ប្រគល់តំណែងនេះទៅឯ.ឧ.យ៉ែម-សំបួរ ដែលជាអ្នកផ្ដើមហេតុរំលាយរដ្ឋសភា ។

ឯ.ឧ.យ៉ែម-សំបួរមានបំណងចង់ប្រគល់អំណាចជំនុំសំរេច ទៅក្រុមប្រឹក្សាព្រះរាជអាណាចក្រ ដែលជាសភាទីប្រឹក្សា ។ ការធ្វើដូច្នេះដើម្បីឲ្យក្រុមប្រឹក្សាព្រះរាជ

អាណាចក្រ ធ្វើការជំនួសរដ្ឋសភាដែលរលាយទៅហើយនោះ ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានសុំឲ្យគណបក្សនីមួយៗចាត់ប្រតិភូ ៣នាក់ ឲ្យចូលទៅរួបរួមជាមួយនឹងគណៈកម្មការ ដើម្បីកែប្រែច្បាប់រដ្ឋធម្មនុញ្ញថ្ងៃទី៦ ឧសភា ឆ្នាំ១៩៤៧ ។

សង្គមពួកមន្ត្រីរាជការខ្មែរ (L'asfac) ដែលពុំមែនជាគណបក្សនយោបាយ ក៏បានសុំចូលទៅជំនុំជាមួយគណៈកម្មការបាន ដោយពុំបានពិគ្រោះសួរគណៈកម្មាធិការជាមុន ហើយបានចាត់បញ្ចូលប្រតិភូ ទីប្រឹក្សាព្រះរាជអាណាចក្រសុទ្ធតែជាសមាជិកនៃគណៈរួមជាតិនិងគណៈចំរើនជាតិ ។

ការសុំចូលជំនុំនេះ ដើម្បីឲ្យកម្លាំងដល់រដ្ឋាភិបាលយ៉ែម-សំបូរ ក្នុងករណីណាដែលជំនុំទៅមិនបានចុះសំរុងគ្នា ត្រូវបញ្ចេញមតិ ។

គណបក្សធំៗដូចជា ប្រជាធិបតេយ្យ, សេរីភាព, ខេមរប៉ុណ្ណាការ បានជំទាស់នឹងគណៈកម្មការពីកែប្រែរដ្ឋធម្មនុញ្ញនេះ ។

នៅឱកាសជំនុំលើកទី២ (ថ្ងៃទី១១ មករា ១៩៥០) នោះខ្ញុំជាប្រធានគណៈប្រតិភូនៃគណៈរាស្ត្រសេរីភាព បានសូត្រញត្តិជំទាស់នឹងសេចក្តីកែប្រែរដ្ឋធម្មនុញ្ញ ញត្តិនេះបានទទួលសេចក្តីយល់ព្រមទាំងស្រុង អំពីប្រតិភូគណបក្សប្រជាធិបតេយ្យ និងគណបក្សខេមរប៉ុណ្ណាការ, ឯ.ឧ.ចាន់-ហាក់ នៃគណបក្សរួបរួមជាតិ ជាទីប្រឹក្សានៃព្រះរាជអាណាចក្រ ជាអតីតមន្ត្រីនិងជារដ្ឋមន្ត្រីបច្ចុប្បន្ននៃក្រសួងយុត្តិធម៌ក៏បានយល់ព្រមផងដែរ ។

ក្រោយការជំនុំលើកទី២នេះ ពួកប្រតិភូនៃគណបក្សប្រជាធិបតេយ្យ និងគណបក្សខេមរប៉ុណ្ណាការ ជាសំរេចជាដាច់ខាត មិនព្រមចូលជំនុំក្នុងលើកក្រោយៗទៀតទេ ។

**គឺពួកប្រតិភូទាំងនោះបានផ្តើនឱ្យរដ្ឋាភិបាលយ៉ែម-សំបូរ**

សូមជំរាបគុលាការ

*

*   *

ការថ្លែងប្រវត្តិសង្ខេបនេះបង្ហាញឲ្យឃើញជាក់ស្តែងថា តាំងពីបង្កើតលទ្ធិប្រជាធិបតេយ្យខ្មែរឡើង (បង្កើតគណបក្ស) ដរាបមកទល់នឹងថ្ងៃឯ.ឧ.អៀវ-កើសត្រូវគេធ្វើឃាតនេះ (នៅថ្ងៃទី១៤-១-៥០) ឯ.ឧ.អៀវ-កើស និងព្រះអង្គម្ចាស់សុទ្ធាវង្សនិរទ្ធជេតក្តី គណបក្សប្រជាធិបតេយ្យ និងគណបក្សរាស្ត្រសេរីភាពក្តី ពុំដែលមាន

ហេតុទាស់ទែងខ្វែងគំនិតគ្នាឲ្យបានជាធំដុំ ដល់ទៅពិឃាតគ្នាសោះឡើយ ។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ-នរិន្ទតេជទ្រង់មានសទ្ធាជ្រះថ្លា ទ្រង់សីលប្រាំបី ទ្រង់មិនសព្វព្រះទ័យឱនិយាយកុហកបញ្ឆោត ដើរបោកប្រាស់គេទេ ទ្រង់មានសេចក្តីស្រឡាញ់ ហើយគោរពព្រះវរមាតាទ្រង់រកអ្វីមកប្រៀបពុំបាន ។

ប្រសិនបើព្រះអង្គម្ចាស់ស៊ីសុវត្ថិ-នរិន្ទតេជត្រូវការប្រព្រឹត្ត ឬឲ្យគេប្រព្រឹត្តបទឧក្រិដ្ឋ ដូចជាគេបានចោទទ្រង់នោះ ទ្រង់មុចជាមិនប្រគល់ការនេះ ឲ្យទៅគូលីត្រីចក្រយាន (ស៊ីក្លូ) ដែលទ្រង់មិនស្គាល់ មិនទុកព្រះទ័យនោះទេ គួរណាស់តែទ្រង់ចាត់ពួកក្រុមរក្សាព្រះអង្គណាមួយ ដែលទ្រង់បានទុកព្រះទ័យស៊ប់សួន ដើម្បីកុំឲ្យខូវខ្វាយការសម្ងាត់នេះ ។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ-នរិន្ទតេជ តាមសម្លោកខ្មែរក្តី សម្លោកបារាំងក្តី មិនមានលក្ខណៈណាមួយ ដែលបញ្ជាក់អំពីភិនភាពរបស់មនុស្សចិត្តសាហាវឃោរឃៅសោះឡើយ ។

ចំណែកទ្រង់ គ្មានព្រះភក្ត្រា (មុខ) នលាដវ្សញ (ថ្ងាស់) ឧណ្ណាលោម ក្រួចសើច (ចិញ្ចើម) ។

ឯ.ឧ.អៀវ-កើសក្តី, ព្រះអង្គម្ចាស់ស៊ីសុវត្ថិ-នរិន្ទតេជក្តី អត្តភាពលំនាំស្រីដូចគ្នាមានឫកពាសណ្តាប់ធ្នាប់ស្លូតបូត ។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ-នរិន្ទតេជ ដែលទ្រង់មានសេចក្តីស្រឡាញ់និងគោរពកោតខ្លាចព្រះមាតាទ្រង់ដូច្នេះ ទ្រង់មិនអាចធ្វើឲ្យប្តីគេព្រាត់ប្រាស់ប្រពន្ធ ធ្វើឲ្យឪពុកគេព្រាត់ប្រាស់កូន ធ្វើឲ្យកូនព្រាត់ប្រាស់ឪពុក ។

មនុស្សពិឃាតឯ.ឧ.អៀវ-កើស ចំជាមនុស្សមានចិត្តឃោរឃៅឥតធម៌សប្បុរស សូម្បីមាតាបិតាខ្លួនក៏គ្មានសេចក្តីស្រឡាញ់ គឺមនុស្សអកត្តញ្ញូ ។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ-នរិន្ទតេជវិញ បើទុកជាជនណាបានប្រព្រឹត្តបទឧក្រិដ្ឋតែគ្មានសាលក្រមកាត់ទោសជាដាច់ខាតទេ មុខជាទ្រង់មិនអាចហ៊ានប្រើឲ្យសម្លាប់គេទេ ដូចជាពួក ឯក-សម និងគូកនជាដើម ។

ឯពួកខាងប្រជាធិបតេយ្យ ដំបូងមានយោបល់មិនស្របគ្នា បន្ទាប់មកមានយោបល់មិនព្រមព្រៀងគ្នា ក្រោយបង្អស់កើតបែកសាមគ្គីរវាងគណបក្ស ដូចអស់លោកជ្រាបស្រាប់ ។

នេះជាសេចក្តីសង្ខេប អំពីនិទ្ទិតកម្ម ដែលលូតចេញជាក់ស្តែងឡើង ក្នុងរវាងក្រុមឯ.ឧ.អៀវ-កើស និងក្រុមឯ.ឧ.យ៉ែម-សំបូរ ។

## និដ្ឋិតកម្មនិងអាកប្បកិរិយារបស់ឯ.ឧ. យ៉ែម_សំបូរ

១១- ឯ.ឧ.យ៉ែម-សំបូរ បានពោលពាក្យទ្រគោះបោកបោះ ទៅលើឯ.ឧ.ប៉ែន-

នុត ជាទីប្រឹក្សានយោបាយនៃគណបក្សប្រជាធិបតេយ្យ ។

១២- ឯ.ឧ.យ៉ែម-សំបូរ បានបំបែកគណបក្សប្រជាធិបតេយ្យ ។

១៣- ឯ.ឧ.យ៉ែម-សំបូរ បានប្តូររដ្ឋាភិបាលឯ.ឧ.ប៉ែន-នុត ជាគូបដិបក្ខរបស់ខ្លួន ។

១៤- ឯ.ឧ.យ៉ែម-សំបូរ បានសុំដកអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រពួកខ្លះនៃគណបក្សប្រជាធិបតេយ្យ ។

១៥- ឯ.ឧ.យ៉ែម-សំបូរ បានសុំអំណាចពេញទី ប៉ុន្តែព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់បដិសេធ ។

១៦- ឯ.ឧ.យ៉ែម-សំបូរ ជាអ្នកផ្តើមហេតុរំលាយរដ្ឋសភា ។

១៧- ឯ.ឧ.យ៉ែម-សំបូរ ជាអ្នកផ្តួចផ្តើមកែប្រែច្បាប់រដ្ឋធម្មនុញ្ញ ។

## និដ្ឋិតកម្មនិងអាកប្បកិរិយារបស់ឯ.ឧ. អៀវ-កើស

១១- ឯ.ឧ.អៀវ-កើស បានជំទាស់បណ្តាលឲ្យឯ.ឧ.យ៉ែម-សំបូរជ្រើសរដ្ឋមន្ត្រីលើកទី១មិនសំរេច ។

១២- ឯ.ឧ.អៀវ-កើស បានជំទាស់នឹងការចាត់តាំងរដ្ឋាភិបាលយ៉ែម-សំបូរលើកទី២ម្តងទៀត លុះត្រាតែព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់សំរុះសំរួលទើនឯ.ឧ.យ៉ែម-សំបូរ ចាត់តាំងរដ្ឋាភិបាលបានសំរេច ដោយសារ១០ឆ្នោតខាងពួកប្រជាធិបតេយ្យ ដែលជាអំណោយទាំងបង្ខំរបស់ឯ.ឧ.អៀវ-កើស ថែមទៅលើ២០ឆ្នោត របស់ក្រុមសមាជិកតំណាងរាស្ត្រសេរីភាព ។

១៣- រដ្ឋសភាអនុម័តដាច់អហង្កា មិនព្រមឲ្យដកអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភា តាមសេចក្តីសុំរបស់ឯ.ឧ.យ៉ែម-សំបូរ ។

១៤- មានតំណាងរាស្ត្រគណបក្សប្រជាធិបតេយ្យ១ក្រុម បានសុំតាំងញត្តិបន្ទោសមួយជូនទៅមន្ទីររដ្ឋសភា ដើម្បីផ្តួលរដ្ឋាភិបាលយ៉ែម-សំបូរ ។

១៥- គណៈប្រតិភូប្រជាធិបតេយ្យ ដែលមានឯ.ឧ.អៀវ-កើសជាដើម ក៏ដូចជាគណៈប្រតិភូសេរីភាព ដែលមានខ្លួនខ្ញុំជាដើម និងគណៈប្រតិភូខេមរប៉ុណ្ណាការ ដែល ដែលមានលោកលន់-នល់ជាដើម បានជំទាស់នឹងការកែប្រែរដ្ឋធម្មនុញ្ញ ។

## និដ្ឋិតកម្មដែលគេបានលើកទម្លាក់ដាក់ទម្ងន់ទៅលើឯ.ឧ.អៀវ-កើស

មានគណៈប្រតិភូនៃពួកនិស្សិតខ្មែរនៅប្រទេសបារាំង បានចូលក្រាបថ្វាយបង្គំគាល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងជំរាបសួរឯ.ឧ.យ៉ែម-សំបូរ ដើម្បីនឹង

ក្រាបបង្គំទូលសួរ អំពីហេតុនៃការរំលាយសភា ។ ដើម្បីកាត់ឲ្យខ្លី, ឯ.ឧ.យ៉ែម-សំបូរ បានសុំឲ្យគណៈប្រតិភូពួកនិស្សិត ចូលទៅជួបជុំគ្នានៅក្នុងបន្ទប់របស់លោក ឮថា ក្រោយដែលបានជជែកតវ៉ាគ្នាយ៉ាងខ្លាំង ដល់ទៅជាបបួលដាល់គ្នាតាមវិធីខ្មែរ ។

## និដ្ឋិតកម្មដែលគេបានលើកទម្លាក់ដាក់ទម្ងន់ នៅលើនាងអៀវ-បណ្ណការ និងអៀវ-ធុណីការជាបុត្រ ឯ.ឧ.អៀវ-កើស នៅគ្រាដែលឯ.ឧ.មិននៅ, ដោយមិនទាន់ត្រឡប់ពីប្រទេសបារាំង

ដោយហេតុការណ៍ផ្សេងៗរបស់ពួកកូនសិស្សនៅក្រុងភ្នំពេញ ដែលនាំគ្នាធ្វើបាតុកម្ម យ៉ាងស្ងប់ស្ងាត់តាមផ្លូវទាំងឡាយក្នុងក្រុង ។ ការធ្វើបាតុកម្មនេះ បានបណ្ដាលឲ្យមានការទាស់ទែងគ្នាយ៉ាងខ្លាំង ដល់ទៅកើតប្រទូស្ដរ៉ាយគ្នា មកតែអំពីការមិនប៉ិនប្រសប់នៃក្រុមនគរបាលក្រុង ។

-------------------------។ល។

(យើងអាចចាំបានថា កាលនិស្សិតធ្វើបាតុកម្មនៅក្រុងភ្នំពេញ គេនាំគ្នាច្រៀងស្រែកវាយឆៃយ៉ាំថា ៖ «មាស-សាឯម, យ៉ែម-សំបូរ បើកកាស៊ីណូ បិទវិទ្យាល័យ, ហ៊ុយ-ម៉ោង ! ហ៊ុយ-ម៉ោង ! ហ៊ុយ-ម៉ោង !....... ។ល។

## ស្វមដំរាបតុលាការ

ឥឡូវនេះ ខ្ញុំនឹងសារសព្វដល់ត្រង់កន្លែងដែលគួរឈឺចាប់តទៅនេះ ៖

កាលពីថ្ងៃសៅរ៍ទី១៤ មករា ១៩៥០ ជាកាលបរិច្ឆេទដែលគួរចាំទុកក្នុងប្រវត្តិនៃលទ្ធិយុវប្រជាធិបតេយ្យខ្មែរ ពួកសមាជិកប្រជាធិបតេយ្យបានទៅជំនុំគ្នានៅទីសំណាក់ការលេខ៦៦ វិថីពិកេត៍ ដើម្បីសន្ទនាប្រាស្រ័យជាមួយនិងពួកប្រតិភូ ដែលទៅជំនុំកែប្រែច្បាប់រដ្ឋធម្មនុញ្ញ ហើយនិងកំណត់កាលបរិច្ឆេទ និងទីកន្លែងធ្វើសន្និសិទរបស់ឯ.ឧ.អៀវ-កើស អំពីរឿងធ្វើដំណើរទៅកាន់ទ្វីបអឺរ៉ុប ។

ការជំនុំគ្នានៅពេលម៉ោង១៩ ប៉ុន្តែដោយហេតុមានមង្គលការនៅទីក្រុង ទើបកែប្រែកំណត់នេះទៅវិញ (ប្រហែលជាពួកភេរវជននិងក្រុមធ្វើឃាតកម្មមិនបានដឹង) ត្រូវបន្ថយកែប្រែពេលជំនុំជាថ្មី កំណត់ម៉ោង១៧ មិនមែនម៉ោង១៩តាមកំណត់ដើម ។ កាលបើកឱកាសប្រជុំឡើង ឯ.ឧ.អៀវ-កើស បានប្រាប់លោកអឹម-ផុន អតីតតំណាងរាស្ត្រខាងគណបក្សប្រជាធិបតេយ្យ ឲ្យអានញត្តិរបស់គណៈរាស្ត្រសេរីភាព នៅពេលនេះលោកធ្វើជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ។

ខ្ញុំមានសេចក្ដីត្រេកអរណាស់ ប៉ុន្តែមិនមែនមកអំពីកិច្ចការស្នាដៃរបស់ខ្ញុំទេ គឺ

ជាការបញ្ជាក់ឲ្យឃើញថា គណបក្សប្រជាធិបតេយ្យនិងគណៈរាស្ត្រសេរីភាព មិនមែនប្រព្រឹត្តដូចសត្វឆ្កែនិងឆ្មា ដូចគេគិតស្មានមកនោះទេ ។

លុះជំនុំរួចស្រេចហើយ ពួកសមាជិកនាំគ្នាចេញទៅអស់ហើយ ពេលនោះស្រាប់តែលេចលោកង៉ែត-ហ៊ាន អតីតតំណាងរាស្ត្រចូលទៅជួបឯ.ឧ.អៀវ-កើសជាពិសេស ។ ឯ.ឧ.អៀវ-កើសក៏ត្រឡប់ចូលទៅមន្ទីរជំនុំវិញ ហើយបានសន្ទនាជាមួយនឹងលោកង៉ែត-ហ៊ាន និងឯ.ឧ.ហាក់-ម៉ុងសេង ៗបានចេញទៅមុនមួយស្របក់ ។

ស្រាប់តែលោកទាំងពីរនៅក្នុងបន្ទប់ បានឮអ្វីមួយរមៀលមកលើកំរាលឥដ្ឋជិតជើងលោក ។

លោកង៉ែត-ហ៊ានថាឃីគេចោលដបអ្វី ក៏បានស្ទុះចេញទៅមើលតាមបង្អួច លោកបានឃើញមនុស្សពីរនាក់រត់ចេញទៅ ម្នាក់ស្លៀកពាក់ខ្មៅទាំងអស់ ម្នាក់ទៀតស្លៀកខោខ្មៅពាក់អាវកាគី ។

ឯ.ឧ.អៀវ-កើសអង្គុយនៅហ្នឹងកន្លែង ថាកូនក្មេងចោលអី ក៏ភើយកំរាលតុកីឈ្ងោកទៅក្រោម ស្រាប់តែគ្រាប់បែកផ្ទុះឡើងត្រូវខ្លួនលោក ។

លោកង៉ែត-ហ៊ាន ដែលនៅជិតបង្អួចម្ងាយពីរម៉ែត្រពីគ្រាប់ផ្ទុះ ក៏ត្រូវជើងម្ខាងបាក់ទៅ (ពិការជានិច្ច) ។

គេនិយាយថា កុំតែលោកង៉ែត-ហ៊ានយឺតយូរនាំឲ្យឯ.ឧ.អៀវ-កើសបង្អែបង្អង់ទាល់តែដល់ពេលម៉ោងជីវិតអន្តរាយ កុំអីឯ.ឧ.អៀវ-កើសគ្មានគ្រោះថ្នាក់ដល់មរណៈសោះ ។ ព្រោះហេតុនេះហើយបានជាគេបង្គាប់ឲ្យឆែករកវិភ្លាម នៅផ្ទះលោកង៉ែត-ហ៊ាន ។

ចំណែកខាងខ្លួនខ្ញុំៗយល់ឃើញថា ប្រសិនបើមិនផ្លាស់កំណត់ពេលប្រជុំទេ ឬបើប្រសិនបើពួកឆោរជនបានដឹងមុននូវការកែប្រែពេលម៉ោង នោះពួកសមាជិកទាំងអម្បាលមាណនៃគណបក្សប្រជាធិបតេយ្យ ឬចំនួនច្រើនដែលជំនុំការជាមួយគ្នាមុខជាបានទទួលគ្រោះថ្នាក់ ដូចជាឯ.ឧ.អៀវ-កើសនិងលោកង៉ែត-ហ៊ានជាមិនខាន

ក្រុមធ្វើឃាតកម្មនេះ មិនមែនព្យាយាមចង់សម្លាប់តែឯ.ឧ.អៀវ-កើសប៉ុណ្ណោះទេ បើគេចង់សម្លាប់តែខ្លួនលោកមួយ មុខជាគេទៅចោលគ្រាប់បែកនៅមន្ទីរផ្ទះលោក ឬក្នុងរថរបស់លោក គឺថាគេប៉ងសម្លាប់ពួកប្រជាធិបតេយ្យណា ដែលមិនមែនជាពួកបែកចេញទៅ ហើយបានទៅជួបជុំគ្នាក្នុងថ្ងៃទី១៤ មករា ១៩៥០ ។

------------ ។ល។

*

* *

សេចក្ដីដកស្រង់«រឿងក្ដី»
ព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ

ដោយមេធាវី ហ្វេរណង់ដែស្ស-សមសុន
(១៤ មករា គ.ស.១៩៥២)

# អំពីបទល្មើសឃាតកម្ម ឯ.ខ.អៀវ-កើស
# និង
# បំណងធ្វើឃាតកម្មលោក ង៉ែត-ហ៊ាន

(ថ្ងៃ១៤ មករា គ.ស.១៩៥០)
វេលាម៉ោង២០ នៅទីក្រុងភ្នំពេញ
ក្នុងមន្ទីរចាត់ការគណបក្សប្រជាធិបតេយ្យ

*

# រឿងក្ដី

*ព្រះអង្គម្ចាស់* **សុទ្ធាវង្ស-ធរិទ្ធតេជ**
*ព្រះសារលោហិត* **ធរោត្ដម-សុទ្ធាពិទ្ធ-ធរិទ្ធតេជ**

*ជនកសមាជិក ហើយជាប្រមុខគណៈរាស្ដ្រសេរីភាព*

*ដោយ* **ហ្សេរណង់ដែស្ស-សមសុន**
*ទីប្រឹក្សានយោបាយគណៈរាស្ដ្រសេរីភាព*
*ជាអ្នកតែង*

*ហាមឃាត់មិនឲ្យនានាប្រទេសប្រែ*
*បោះពុម្ពលើកទីមួយ*
*១ ៩ ៥ ២*

# បុព្វយោគ

ក្នុងសម័យរដ្ឋាភិបាល ដែលមានឯ.ឧ. យ៉ែម-សម្បូណ៍ ជានាយករដ្ឋមន្ត្រីមានព្រឹត្តិការណ៍មួយយ៉ាងធំអស្ចារ្យឧបត្តិឡើងជាព្រឹត្តិការណ៍ដែលគេត្រូវកត់ត្រាទុកក្នុងពង្សាវតាប្រទេសខ្មែរ សម័យសតវត្សរ៍ទី១៩នៃគ្រិស្តសករាជ ។

នៅមន្ទីរសំណាក់ការនៃគណបក្សប្រជាធិបតេយ្យ កាលរាត្រីថ្ងៃទី១៤ មករា គ.ស.១៩៥០ វេលាប្រហែលជាម៉ោង២០ មានគ្រាប់ដៃមួយបានផ្ទុះឡើង ហើយដោយរិទ្ធិអំណាចនៃគ្រាប់បែកដៃនេះគឺ ៖

១)- ឯ.ឧ. អៀវ-កើស (ជាអតីតអគ្គលេខាធិការនៃគណបក្សប្រជាធិបតេយ្យ, អតីតប្រធានរដ្ឋសភា និងជាប្រធាននៃគណៈប្រតិភូខាងបក្សនេះ ក្នុងឱកាសប្រជុំកែប្រែរដ្ឋធម្មនុញ្ញ) បានទទួលមរណភាព ។

២)- លោកង៉ែត-ហ៊ាន (ជាអតីតតំណាងរាស្ត្រគណបក្សប្រជាធិបតេយ្យ) បានទទួលរបួសពិការជើងជានិច្ច ។

គួរគិតពន់ពេក ឈ្មោះ នូ-យ៉ា ដែលចាប់បាន ដោយដេញប្រផាប់ចាប់ប្រភឹងនៅពេលភ្លាមនោះ ឆ្លើយដូចម្ដេចខ្លះ យើងពុំអាចស្មានដឹង, តែប្រាកដថា ក្នុងរយៈពេលវេលាប្រហែលជា២៤ម៉ោងក្រោយព្រឹត្តិការណ៍ សភាពស្ងប់ស្ងាត់បានកើតឡើងហាក់ដូចជាគ្មានហេតុអ្វីសោះ ។ លុះរយៈវេលាកន្លងទៅបានប្រហែលជា៣០ម៉ោងប្លាយ, ទើបសម្លេងដ៏អប្បលក្ខណ៍ដែលច្របូកច្របល់ទៅជាមុសាវាទ និងពាក្យចាក់រុកផ្សេងៗបានផុសឡើង ជាសំដីដែលមួលបង្កាច់យ៉ាងគ្មានគិតអៀនខ្មាស់ថាព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ ដែលជាជនកសមាជិក ហើយជាប្រធានគណៈរាស្ត្រសេរីភាព ជា«មេក្រុមមតៈគាហា» ក្នុងឧប្បត្តិហេតុនេះ ។

★ ★
★

មុនពេលដែលយើងចូលទៅជំនុំលើកទី៤ កាលពីថ្ងៃទី១៧ មករា ១៩៥០ អំពីការកែប្រែរដ្ឋធម្មនុញ្ញ យើងបានឮព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ មានព្រះបន្ទូលសួរឈ្មោះ ប៉ៅ-ស៊ុន ដែលជាអ្នកយាមទ្វារជំណាក់ចំពោះមុខយើងថា «ដំណឹងថា គេគិតចោទប្រកាន់ខ្ញុំ ហើយគិតចាប់ ប៉ៅ-ស៊ុន ឯង ដើម្បីបង្ខំឲ្យឆ្លើយដាក់ខ្ញុំ

មិនដឹងជាគេនឹងធ្វើបាប ប៉ៅ-ស៊ុន ឯងយ៉ាងណាទេ តើ ប៉ៅ-ស៊ុន ឯងគិតភៀសខ្លួន ឬដូចម្ដេច?» ពេលនោះ ប៉ៅ-ស៊ុន ទូលតបវិញថា «ទូកព្រះបង្គំសុចរិត, ទូលព្រះបង្គំមិនខ្លាចទេ មិនគេចខ្លួនទេ ទូលព្រះបង្គំនឹងឆ្លើយផ្ដេសផ្ដាសក៏ទេដែរ» ។

ក្រោយជំនុំលើកទី៤រួច, យើងបានទៅបង្អោនកាយចំពោះសពឯ.ឧ.អៀវ-កើស ឈរក្បែរមឈូសដំកល់សពនោះ ហើយយើងបាននិយាយខ្លាំងៗ ចំពោះដួងវិញ្ញាណក្ខន្ធនៃសព ចំពោះមុខគ្រួសារ និងប្រជាជនប្រុសស្រីជាច្រើនថា «បើខ្ញុំមានអំណាចអ្វី អាចជួយរាវរកហេតុផលក្នុងព្រឹត្តិការណ៍នេះ ខ្ញុំនិងខិតខំឲ្យអស់ពីចិត្ត ដើម្បីរកឲ្យឃើញនូវមនុស្សដើមគំនិត ហើយបើប្រសិនជារកទៅឃើញប៉ះពាល់ទៅលើពួកក្រុមរបស់ខ្ញុំ នោះខ្ញុំនឹងឲ្យការណ៍តាមសេចក្ដីពិតត្រង់ ហើយខ្ញុំនឹងលះបង់ពួកក្រុមរបស់ខ្ញុំចោលភ្លាម» ។ ក្នុងពេលដែលនិយាយនោះ យើងមិនបាននឹកនាថា នឹងធ្វើជាមេធាវីសោះឡើយ ព្រោះយើងតាំងចិត្តតាំងពីពេលទទួលរ៉ុត្រែតថា នឹងរកទទួលទានផ្លូវពាណិជ្ជកម្មតែម៉្យាង ។

ក)- ក្រុមព្រះនគរបាលជាតិចាប់ ប៉ៅ-ស៊ុន បញ្ចូលគុកងងឹត ដែលត្រូវទទួលពន្ធនាការយ៉ាងសំខាន់ ដែលគេហៅថានរកស្ថានកណ្ដាល ។

ខ)- បន្ទាប់ពីចាប់ ប៉ៅ-ស៊ុន មិនយូរប៉ុន្មាន ឃួន-សុត អតីតតំណាងរាស្ត្រគណៈរាស្ត្រសេរីភាព ត្រូវគេចាប់បញ្ចូលគុកទៀត ។

គ)- ព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ បានទទួលពីក្រុមព្រះនគរបាលជាតិនូវដីការកោះឲ្យចូលព្រះអង្គ ថែមទាំងមានចុតហ្មាយឲ្យដំណឹងទ្រង់ថា ក្រុមសង្គហព្រះរាជវង្សានុវង្សអនុញ្ញាតឲ្យចោទប្រកាន់លើទ្រង់ហើយ ។

ក្នុងខណៈនោះ ទ្រង់មានបន្ទូលឲ្យគេទៅស្នើថា «ទ្រង់មិនសព្វព្រះទ័យឲ្យក្រុមព្រះនគរបាលជាតិសួរចម្លើយទេ សុំឲ្យសុភាចារបុរសសួរទ្រង់តាមច្បាប់វិញ» ។ ពេលនោះគេឲ្យការណ៍មកវិញថា ក្នុងរឿងក្ដីនេះសុភាចារបុរសមិនអាចសួរចម្លើយទ្រង់បានទេ ព្រោះបានឲ្យអំណាចទាំងមូលទៅក្រុមព្រះនគរបាលជាតិអស់ទៅហើយ ។ ដោយគេពុំព្រមធ្វើការដោយត្រឹមត្រូវតាមច្បាប់ដូច្នេះបានជាទ្រង់សុំ ហើយបានអនុញ្ញាតឲ្យថយចេញពីប្រទេសកម្ពុជា ទៅរង់ចាំឲ្យតុលាការរកខុសត្រូវតាមដំណើរហេតុ ។

ជាការគួរឲ្យអាណោជអាធម្មក្រៃលែង ដែលគេល្មើសនឹងច្បាប់ក្នុងសម័យដែលមនុស្សត្រូវមានសិទ្ធិនិងសេរីភាពដូច្នេះ ។ បើប្រសិនជាមិនកាន់ការនេះឲ្យពេញលេញ អយុត្តិធម៌ទាំងឡាយមុខជានឹងក្រាលពាសពេញផែនដី ។ លុះគិតឃើញដូច្នេះ ទើបយើងសុំខ្លួនធ្វើមេធាវី ដើម្បីជួយស្រាយថ្វាយទ្រង់ និងក្រុមរបស់ទ្រង់ ហើយទ្រង់ក៏យល់ព្រម ។ តែអកុសលកម្មនៅតែតាមជ្រៀតជ្រែកជាដរាប សំណូម

ធ្វើជាមេធាវីរបស់យើង បានជួបនឹងឧបសគ្គច្រើនជាអនេក សូមអញ្ជើញជួយពិចារណាយើង ៖

- មេឃុំកំពង់ចាម ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានចេញវិញ្ញាបនប័ត្រឲ្យយើងថា «សីលធម៌និងកិរិយាមារយាទត្រឹមត្រូវ ហើយមានធនធានច្រើន» ។

- សមុហបញ្ជីសាលាដំបូងកំពង់ចាម បានចេញវិញ្ញាបនប័ត្រឲ្យយើងថា «គ្មានពាក្យបណ្ដឹង គ្មានសេចក្ដីចោទពីបទអ្វីនៅសាលាដំបូងទេ» ។

- បញ្ជីថ្កោលទោសរបស់យើង «ស្អាតបរិសុទ្ធ» សំណូមពររបស់យើងត្រូវផ្អាប់ចោល៣ខែ ស្រាប់តែនាយព្រះនគរបាលជាតិ ធ្វើសំបុត្រប្ដឹងឲ្យការណ៍ទៅក្រសួងយុត្តិធម៌ «ពិតមែនតែយើងមានធនធាន តែកិរិយាគំនិតមារយាទគួរឲ្យសង្ស័យ ព្រោះក្រសួងនេះបានដឹងថា កាលពីនៅធ្វើការក្នុងមុខងារ មានលិខិតអនាមប្ដឹងពីស៊ីសំណូក» ។ មិនតែប៉ុណ្ណោះគេបានទាំងជូនជាប់មកជាមួយផង នូវសេចក្ដីចម្លងសេចក្ដីថ្លែងការណ៍មួយ ថាជារបស់គម្មិស្សែរព្រះនគរបាលជាតិកំពង់ចាម ដែលមានសេចក្ដីដូចតទៅនេះ ៖

«លោក ហ្វៃរណង់ដែស្ស សម-សុន ចៅក្រមរ៉ឺត្រៃតមានជំរេះវិជ្ជាឆ្លៀវឆ្លាតចេះច្បាប់ជ្រៅជ្រះ តែជាមេធាវីមានពិស ។ ប្រសិនជាមេធាវីម្ខាងមិនប្រសប់តបតមុខជាគាត់ឈ្នះក្ដីបាន ។ តែគាត់មានអំណាចដោះសារការពារខ្លួនគាត់ ឬប្ដឹងប្ដល់ ឬការពារមិត្តភក្តិ, គាត់មិនទុកមុខមន្ត្រីធំណាឡើយ បើទុកជាប្រជាជនទាំងអស់ស្រឡាញ់គោរពនាម៉ឺននោះក៏ដោយ ។ មនុស្សនេះមិនរួញរាក្នុងការលំបាកទេ ហើយហ៊ានប្រព្រឹត្តដោយចិត្តាមិនស្មោះត្រង់ ។ ដែលគាត់សុំធ្វើមេធាវី គ្រាន់តែជួយដោះសារមេគណៈរបស់គាត់ ពីបទធ្វើមនុស្សឃាដដោយចេតនាគិតទុកជាមុន និងដើម្បីការពារផលប្រយោជន៍ពួកក្រុមគណបក្សគាត់ប៉ុណ្ណោះទេ» ។

យើងពុំចាំបាច់ដោះសារឬកែខ្លួនយ៉ាងណាទេ យើងគ្រាន់តែសូមជំរាបថា យើងបានធ្វើចាងហ្វាងសាលាដំបូងជាង១២ឆ្នាំ ដំរាបដល់រ៉ឺត្រៃត រាជការមិនដែលបន្ថយស័ក្តិយស ឬបន្ទោសជាផ្លូវការម្ដងណាឡើយ ។ យើងហ៊ានថា គ្មានចាងហ្វាងណាទៅនៅកំពង់ចាមបានយូរដូចយើងទេ ។

★

★ ★

ក្នុងភកាសដែលយើងរង់ចាំសេចក្ដីអនុញ្ញាតឲ្យធ្វើជាមេធាវីនេះ យើងធុញទ្រាន់ពន់ពេក តែដោយមានសេចក្ដីសង្ឃឹមថា «អំពើសុចរិតរមែងរត់ចោលមនុស្សសុចរិតទៅពុំបាន» ទើបយើងឆ្លៀតឱកាសទំនេរ ស្វែងរកល្បិចកិច្ចកលនៃពួកមនុស្សទុច្ចរិតឲ្យឃើញទំនងបណ្ដើរសិន យើងប្រើល្បិចចារកម្មយ៉ាងម៉ឹងម៉ាត់ ឆ្លៀត

ឈ្លបរាវរកការសម្ងាត់ដើម្បីឲ្យឃើញដំណើរហេតុ ដើម្បីគ្រាន់បានជាថ្នាំទិព្វយកមកបង្អាត់មុខរបួស ដែលកំពុងចាប់ពើត ដោយមិនខ្លាចដែងងិត មិនខ្លាចក្លាយជាសពដូចឯកឧត្តម អៀវ-កើស ។

ក្នុងពេលដែលយើងកំពុងបំពេញសកម្មភាព យើងបានដឹងថា ក្រុមព្រះនគរបាលជាតិកំពង់ឆ្នាំង បានធ្វើសេចក្ដីកត់ហេតុ ប្ដឹងទៅក្រសួងមហាផ្ទៃថា ៖ យើងបានទៅកំពង់ឆ្នាំងជាមួយលោកប ប៊ុន-វុង្សវត្តី លោក រស់-សុមិត្ត ដើម្បីរកជួលមនុស្សកំណាច ឲ្យមកសម្លាប់ឯកឧត្តមយ៉ែម-សំបូរ និងលោក តាន់-គឹមតឹក ។

គួរអស់សំណើចពន់ពេក រឿងទៅកំពង់ឆ្នាំងនោះដូច្នេះ ៖

ក្នុងឱកាសដើរស៊ើបការណ៍ យើងតែងទៅមកភ្នំពេញ-កំពង់ចាម ជាញឹកញយ ហើយការទៅមក ត្រូវបើឧបាយមួយដោយឡែក គឺកាលណាដល់ប៉ុស្ដិ៍ត្រួតត្រាគីឡូម៉ែត្រលេខ៦ យើងប្រាប់ថាទៅកំពង់ឆ្នាំង, ដល់កំពង់ចម្លងព្រែកក្ដាម យើងប្រាប់ថាទៅកំពង់ធំ ឬសៀមរាបវិញ, កាលបើទៅដល់ស្គន់ យើងទៅកំពង់ចាមឯណោះសោះ កំពង់ឆ្នាំង ឬកំពង់ធំ ឬសៀមរាប យើងឥតបានទៅឡើយ ។

រឿងទៅកំពង់ឆ្នាំងនេះ ប្រហែលជាគេតាមសៀវភៅកត់ត្រា នៅគីឡូម៉ែត្រលេខ៦ ដែលគេឃើញលេខរថយន្ត P˘3704 ទៅកំពង់ឆ្នាំងញឹកញយពេក គេស្មានថាបានការហើយ បានជាគេប្រើគ្នាគេឲ្យប្ដឹងពីយើងដូច្នេះ នេះហើយជាល្បិចក្នុងការជំទាស់មួយទៀតដែលគេឧប្បត្តិកឡើង ដើម្បីឲ្យយើងខានបានធ្វើជាមេធាវី តែយើងមិនលះបង់សេចក្ដីព្យាយាមសោះ ។

សូមលោកអ្នកអានទាំងឡាយ ជួយពិចារណាផង តើការឧប្បត្តិករឿងធំសំបើម ដែលគេទម្លាក់ទៅលើព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ ឲ្យទ្រង់វិនាសអន្តរាយ តើគេថាទ្រង់ប្រាថ្នាអ្វី ?

- នឹងថាទ្រង់ប្រាថ្នាដណ្ដើមមុខងារ ជាប្រធានរដ្ឋសភា អំពីឯកឧត្តមអៀវ-កើស ។ «មិនសមទេ» ព្រោះពេលនោះរដ្ឋសភារលាយទៅហើយ ហើយបើទុកជាហៅអ្នកតំណាងរាស្ត្រចាស់មកវិញ ក៏ទ្រង់មិនអាចដណ្ដើមមុខងារនេះបានដែរ ដោយទ្រង់មិនមែនជាសមាជិករដ្ឋសភា ។

- នឹងថាទ្រង់ប្រាថ្នាមុខងារជាអគ្គលេខាធិការ នៃគណបក្សប្រជាធិបតេយ្យ «ក៏មិនសមទៀត» ព្រោះទ្រង់ជាមេគណបក្សរាស្ត្រសេរីភាពទៅហើយ ទ្រង់ពុំដែលជាសមាជិកគណបក្សប្រជាធិបតេយ្យ ឬមួយធ្លាប់ជាសមាជិក ហើយដកខ្លួនពីគណៈនេះក៏ទេដែរ ។

- នឹងថាទ្រង់ប្រាថ្នាបំផ្លិចបំផ្លាញគណបក្សប្រជាធិបតេយ្យ ឲ្យសាបសូន្យដើម្បីឲ្យគណៈរាស្ត្រសេរីភាពលូតលាស់ធំខ្ពស់បាន «ក៏មិនសមដែរ» ព្រោះទ្រង់មិន

ដែលសំដែងអាក្បកិរិយាឲ្យឃើញប្លែកដោយកាយ ឬដោយវាចា ដែលសឲ្យឃើញថា ទ្រង់ជាសត្រូវប្ដូរឈាមគ្នានឹងឯកឧត្ដមអៀវ-កើស ឬក៏ចំពោះគណបក្សនេះសោះឡើយ ។

ដោយអំណាចសេចក្ដីព្យាយាមយ៉ាងម៉ឺងម៉ាត់របស់យើង ទើបអាថ៌កំបាំងយ៉ាងជ្រាលជ្រៅ បានរលាយមួយដុំ គឺយើងបានដឹងច្បាស់ថា «គេបានហែកសេចក្ដីកត:ហេតុត្រឹមត្រូវមួយចោល ហើយធ្វើសេចក្ដីកត់ហេតុក្លែងក្លាយ មកជំនួសវិញ គឺគេបញ្ចូលមនុស្សសុចរិតខាងគណៈយើង ឲ្យជាប់ចោទជំនួសមនុស្សទុច្ចរិត ដែលជាពួកខាងណាផ្សេងទៅវិញ» ។

ដោយដុំងងឹតមួយធ្លាយ ទើប ប៉ៅ-ស៊ុន, ឃួន-លុត និងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ បានជ្រះមន្ទិលហើយ តុលាការសាលាឧក្រិដ្ឋក៏បានកាត់ឲ្យរួចខ្លួនជាដាច់ខាត ។

មុខជាមានលោកអ្នកអានខ្លះឆ្ងល់ហើយថា បើឲ្យក្រុមខាងលើនេះរួចខ្លួន ចុះត្រូវយល់ដូចម្ដេចវិញ ? តើលោកណា អ្នកណា ជាដើមគំនិតជួល នួ-យ៉ា វិញ ?

យើងសូមជូនយោបល់ថា ៖

គឺលោកអ្នកណាប្រាថ្នាធ្វើតែម្ដង ឲ្យគណៈទាំងពីរវិនាស,

- គឺធ្វើឲ្យព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ និងឯកឧត្ដមអៀវ-កើសរលត់ព្រះជន្ម និងជីវិត ។

- គឺលោកអ្នកណាប្រាថ្នាធ្វើតែម្ដង ឲ្យគណបក្សទាំងពីរនេះរលាយរូប ។

យើងស្ដាយណាស់ ដោយការស្វែងរកអ្នកដើមគំនិត ក្នុងព្រឹត្តិហេតុនេះពុំទាន់ឃើញ តែយើងសង្ឃឹមថា ដុំងងឹតដែលមិនអាចបែកធ្លាយនេះ គង់តែប្រទះនឹងឥទ្ធិពលនៃអ្នកណាមួយ មកដោលបំបែកជាពុំខាន ព្រោះក្រុមព្រះនគរបាលជាតិធ្លាក់លើដៃគណបក្សប្រជាធិបតេយ្យស្រាប់ហើយ បើចេះរក បើចង់រក មុខជានឹងឃើញ ។

បើឈាមឯកឧត្ដមអៀវ-កើសចេះស្រែក

បើស្បែកឯកឧត្ដមអៀវ-កើសចេះហៅ

បើពួកក្រុមដើមបណ្ដឹងរដ្ឋប្បវេណី ខំខ្នះខ្នែងដោយចិត្តស្នេហា ឯកឧត្ដមអៀវកើស ស្មោះចំពោះសេចក្ដីសុចរិត មុខជារត់មករកអ្នកប្រាថ្នាចង់បាន សុចរិតជាពិតប្រាកដ ។

សៀវភៅដែលទ្រង់កាន់ នៅនាព្រះហត្ថ ដែលលោកអ្នកកាន់នៅដៃ បើសង្កេតតាមសេចក្ដីអធិប្បាយខ្លីៗរបស់ទូលព្រះបង្គំ របស់យើង ខាងលើនេះឃើញថា ទំរាំនឹងកើតឡើងបាន ប្រទះនឹងឧបសគ្គច្រើនណាស់ ត្រាតែយើងខំព្យាយាមពេញ

ទំហឹងទើបកើតជាសៀវភៅនេះឡើង ។

យើងពុំបាននឹកនាថា នឹងបោះពុម្ពជាសៀវភៅទេ ដោយឃើញថាជារឿងដែលជាទីស្លែងចិត្ត តែដោយមានមិត្តភក្តិជាច្រើនបានដាស់តឿនខ្លាំងពេក ទើបអត់ទ្រាំនឹងបោះពុម្ពពុំបាន ។

យើងសូមឧទ្ទិសសៀវភៅនេះ ចំពោះដួងវិញ្ញាណនៃឯកឧត្តមអៀវ-កើស ។

សូមឧទ្ទិសទុកជាពន្លឺដល់យុវជនជាន់ក្រោយ ។

ទុកជាអនុស្សាវរីយ៍ចំពោះព្រឹត្តិការណ៍ ក្នុងសតវត្សទី២០នៃគ្រឹស្តសករាជ ។

ព្រមទាំងបូជាចំពោះការកាន់ខ្ជាប់ នូវសេចក្តីយុត្តិធម៌របស់ចៅក្រមនៃព្រះរាជអាណាចក្រខ្មែរ ។

ហើយសូមឧទ្ទិសចំពោះជនរួមជាតិ ដែលមានភក្តីចិត្តចំពោះព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ។

នឹងឧទ្ទិសទុកជាគំរូ ក្នុងការរាវរកឃាតកម្មយ៉ាងឃោរឃៅ ដែលមានអាថ៌កំបាំងច្រើនស្រទាប់ ចំពោះបងប្អូនរួមជាតិណា ដែលប្រាថ្នាចង់ដឹងនូវរឿងដែលមានទំនងប្រហែលគ្នានេះ ។

ភ្នំពេញ, ថ្ងៃទី១៤ ខែកមរា ឆ្នាំ១៩៥២
ហ្សេរណង់ដែស្ស-សមសុន

★ ★
★

# អំពីបទរំលោភ

## ១) មនុស្សឃាដដោយចេត្តនាគិតទុកមុន

លើរូប ៦.ឧ. អៀវ-កើស
អតីតអគ្គលេខាធិកា នៃគណបក្សប្រជាធិបតេយ្យ
អតីតប្រធានរដ្ឋសភា
កម្ពុជរដ្ឋ សមាគតរដ្ឋ ក្នុងសហភាពបារាំង

## ២) បំណងធ្វើមនុស្សឃាដដោយចេត្តនាគិតទុកជាមុន

លើរូបលោក ង៉េត-ហ៊ាន
សមាជិកគណបក្សប្រជាធិបតេយ្យ
អតីតតំណាងរាស្ត្រ

## ៣) ស្ម័គ្របក្ខពួក និងក្រុមសម្រេចឃាដ

★
★ ★

## ពួកជាប់ចោទ ខាងគណៈរាស្ត្រសេរីភាព

### ១) ព្រះអង្គម្ចាស់ សុទ្ធវង្ស-នរិន្ទតេជ

ព្រះសាលោហិត នរោត្តម-សុទ្ធាពិន្ទ-នរិន្ទតេជ
ជនកសមាជិក ហើយជាប្រមុខគណៈរាស្ត្រសេរីភាព

- ព្រះជន្ម ៨៣ វស្សា
- ប្រសូតនៅថ្ងៃទី២៨ មេសា ១៩០៧
- នៅក្រុងភ្នំពេញ (សង្កាត់លេខ៤) ប្រទេសកម្ពុជា
- ព្រះឱរសព្រះសពព្រះអង្គម្ចាស់ នរោត្តម-សុទ្ធាវង្ស
- និងសម្តេចក្សត្រី ស៊ីសុវត្ថិ-ពិន្ទុជារា
- ព្រះរាជនត្តាព្រះបាទសម្តេចព្រះ នរោត្តម (ចំណែកខាងព្រះវរបិតា)
- ព្រះរាជនត្តាព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ (ចំណែកខាងព្រះមាតា)

- មានព្រះឱរស១អង្គ
- ដំណាក់លេខ ១២២ វិថីបារី
- ទូរស័ព្ទលេខ ២៦៦
- បាត់ព្រះអង្គ (នៅវិថី ដឺបាល់ហ្សាក់ លេខ១១, ប៉ារីស (៨) បារាំង) ។

---

## ២) ឃួន-លុត

អតីតមេឃុំ

អតីតតំណាងរាស្ត្រ គណៈរាស្ត្រសេរីភាព

- អាយុ ៥៣ឆ្នាំ
- កើតនិងនៅក្នុងឃុំចោមចៅ ស្រុកភ្នំពេញ ខែត្រកណ្តាល
- នៅសង្កាត់លេខ៦ ក្រុងភ្នំពេញ
- បុត្ររបស់ឈ្មោះ អ៊ូ (អនិច្ចកម្ម)
- ភរិយាឈ្មោអនាង អឹម
- មានកូន៩នាក់
- ទោសពីមុនគ្មាន
- ឃុំខ្លួនពីថ្ងៃ២៨ មករា ១៩៥០, លេខគុក ៨.៨២២ ។

---

## ៣) ចៅ-ស៊ុន

បោយ, យាមគេហដ្ឋាន

- អាយុ ៣២ ឆ្នាំ
- កើតនៅដុងហូវ ស្វាយទង មាត់ជ្រូក (យៀកណាមប៉ែកខាងត្បូង)
- ទីលំនៅៗមហាវិថី ឌូដាដឺឡាគ្រេ លេខ៧ សង្កាត់លេខ៣ ភ្នំពេញ
- បុត្ររបស់ឈ្មោះ ចៅ-ទូច (អនិច្ចកម្ម) និងនាង ឃុន
- ភរិយាឈ្មោះនាង អ៊ិត
- មានកូន១នាក់
- ទោសពីមុនគ្មាន
- ឃុំខ្លួនពីថ្ងៃទី១៨ មករា ១៩៥០ លេខគុក ៨.៧៩៨

★

★ ★

# ពួកអ្នកជាប់ចោទក្រៅពីគណៈរាស្ត្រសេរីភាព

## ១) នូ-យ៉ា

- អាយុ ៣៥ ឆ្នាំ
-កើតនិងនៅឃុំក្នុងឃុំ កំបូល ស្រុកភ្នំពេញ ខែត្រកណ្តាល
- ទីលំនៅសង្កាត់លេខ៥ ក្រុងភ្នំពេញ
- បុត្ររបស់ឈ្មោះ នូ នាង កាំ
- ភរិយាឈ្មោះនាង លឿង
- មានកូន១នាក់
- ទោសពីមុនគ្មាន
- ឃុំខ្លួននៅថ្ងៃទី១៦ មករា ១៩៥០ លេខគុក ៨.៧៧២

---

## ២) ហាន-ច្រិប

- អាយុ ២០ ឆ្នាំ
- កើតនិងនៅឃុំ កន្ទោក ស្រុកភ្នំពេញ ខែត្រកណ្តាល
- បុត្ររបស់ឈ្មោះ ហាន នាង អឹម
- នៅលីវ
- ទោសពីមុនគ្មាន
- ឃុំខ្លួនពីថ្ងៃទី ៣០ មករា ១៩៥០ លេខគុក ៨.៨៤២

---

## ៣) ឡាំ-ស៊ុត

- អាយុ ៤៥ ឆ្នាំ
- កើតនិងនៅឃុំ កំបូល ស្រុកភ្នំពេញ ខែត្រកណ្តាល
- បុត្ររបស់ឈ្មោះ ឡាំ នាង ហ៊ុន
- នៅលីវ
- ទោសពីមុនគ្មាន
- ឃុំខ្លួនពីថ្ងៃទី ១២ មេសា ១៩៥០ លេខគុក ៨.៩១៦

## ៤) ប៉ុល-សៀង

- អាយុ ២៩ ឆ្នាំ
- កើតនិងនៅឃុំ កំបូល ស្រុកភ្នំពេញ ខេត្តកណ្ដាល
- បុត្ររបស់ឈ្មោះ ប៉ុល នាង ហ៊ិន
- ភរិយាពុំស្គាល់
- មានកូន៣នាក់
- មានទោសជាប់គុកពីបទលួច
- បាត់ខ្លួន

---

## ៥) អ៊ុំ- ឃួវ

- អាយុ ៣៤ ឆ្នាំ
- កើតនិងនៅក្នុងឃុំ កន្ទោក ស្រុកភ្នំពេញ ខេត្តកណ្ដាល
- បុត្ររបស់ឈ្មោះ អ៊ុំ នាង ញ៉ែម
- ភរិយាឈ្មោះ នាង កៀម
- មានកូន៤នាក់
- បាត់ខ្លួន

---

## ៦) អ៊ុក-សាយ

- អាយុ ៤៦ ឆ្នាំ
- កើតនិងនៅឃុំ កន្ទោក ក្រុងភ្នំពេញ ខេត្តកណ្ដាល
- បុត្ររបស់ឈ្មោះ អ៊ុក ម្ដាយមិនស្គាល់
- ភរិយាពុំស្គាល់
- បាត់ខ្លួន

---

## ៧) អ៊ូច-មុំ

- អាយុ ៣៤ ឆ្នាំ
- កើតនិងនៅឃុំ កន្ទោក ក្រុងភ្នំពេញ ខេត្តកណ្ដាល
- បុត្ររបស់ឈ្មោះ អ៊ូច ម្ដាយមិនស្គាល់

- ពោះម៉ាយ
- បាត់ខ្លួន

## ៨) មៀច-ឆែម

- អាយុ ៣៧ ឆ្នាំ
- កើតនិងនៅឃុំ កន្ទោក ស្រុកភ្នំពេញ ខេត្រកណ្តាល
- បុត្ររបស់ឈ្មោះ មៀច នាង ផង់
- ភរិយាឈ្មោះនាង យ៉ា
- មានកូន២នាក់
- បាត់ខ្លួន

★ ★
★

## សាលាឧក្រិដ្ឋជំនុំជំរះខុសពីពេលធម្មតា

នៅថ្ងៃទី ១៦ - ១៧ ខែសីហា ឆ្នាំ១៩៥០

### តុលាការសាលាឧក្រិដ្ឋមាន ៖

| | |
|---|---|
| លោកអ្នកឧកញ៉ា អ៊ុំ-ច្រិក | ចៅក្រមប្រឹក្សាសាលាវិនិច្ឆ័យ ជាចាងហ្វាង |
| អ្នកឧកញ៉ា សៅ-អួន | ចៅក្រមប្រឹក្សាសាលាឧទ្ធរណ៍ ជាចៅក្រមអម |
| អ្នកឧកញ៉ា អែម-ឆុម | ចៅក្រមប្រឹក្សាសាលាឧទ្ធរណ៍ ជាចៅក្រមអម |
| លោក ទេព-ចេង | ជាចៅក្រមជំនួយពេញទី |
| លោក ជ័យ-មៀច | ជាចៅក្រមជំនួយពេញទី |
| លោក អ៊ុក-សួន | ជាចៅក្រមជំនួយរង |
| លោក ម៉ក់-ហុក | ជាចៅក្រមជំនួយរង |
| អ្នកឧកញ៉ា ចាច់-ធួន | ព្រះរាជបំរើសាលាឧទ្ធរណ៍ ជាមហាអយ្យការ |

### មេធាវីមាន ៖

| | |
|---|---|
| លោក អ៊ឹម-ផុន | ថណាយលោកស្រី គីម-ស៊ីរី ភរិយាឯ.ឧ.អៀវ កើស (ជាដើមបណ្តឹងរដ្ឋប្បវេណី) |
| លោក សោម-យឹម | ថណាយឈ្មោះ នូ-យ៉ា |

លោក យស-ឌុច ថណាយឈ្មោះ ឡាំ-សុត
លោក គង់-ម៉ង ថណាយឈ្មោះ ឃួន-សុត
លោក សួស-ឡុង ថណាយឈ្មោះ ចៅ-ស៊ុន, ឃួន-សុត
លោក ហ៊្វែរណាង់ដែស្ស-សមសុន ថណាយឈ្មោះ ចៅ-ស៊ុន, ឃួន-សុត
លោក ជុំ-យិន ថណាយឈ្មោះ ហាន-ច្រិប

បើកឱកាសដំបូង ៖

តុលាការចេញមក លោកចាងហ្វាងបានថ្លែងសេចក្ដីស្ដាយស្រណោះចំពោះ ឯ.ឧ. អៀវ-កើស ដែលជារដ្ឋបុរសមួយ ជាអ្នកជួយពង្រីកការកសាងប្រទេសជាតិចប់ហើយ លោកចាងហ្វាងបានសុំឲ្យតុលាការ ព្រមទាំងមហាជនទាំងអស់ក្រោកឈរនិងរំពឹងបញ្ជូនចេត្តនាចំពោះវិញ្ញាណក្ខន្ធ ឯ.ឧ. អៀវ-កើស រួចហើយតុលា-ការត្រឡប់ចូលក្នុងមន្ទីរពិភាក្សាចំនួន៥នាទី ។

## តុលាការចេញមកវិញ

### សេចក្ដីរំលឹករបស់លោកចាងហ្វាង

១- ចំពោះចៅក្រមជំនួយ សុំឲ្យជួយជំនុំជំរះ កុំឲ្យលុះដោយអគតិទាំង៤ ។

២- ចំពោះមេធាវី, សុំឲ្យដោះស្រាយដោយយុត្តិធម៌ដ៏សុភាព និងដោយគោរពតុលាការ, លោកចាងហ្វាងបានទាំងចង្អុលបង្ហាញលក្ខន្តិកៈរបស់មេធាវី ។

ចំពោះមេធាវី ហ៊្វែរណាង់ដែស្ស-សមសុន លោកចាងហ្វាងរំលឹកថា កុំឲ្យនិយាយកាត់តុលាការ, កុំឲ្យសួរខណាក្រៅពីរឿងនេះ, ហើយលោកចាងហ្វាងប្រសាសន៍ថា លោកមេធាវី ហ៊្វែរណាង់ដែស្ស-សមសុន ធ្លាប់ធ្វើជាចាងហ្វាងសាលាឧក្រិដ្ឋចាស់ស្រាប់ ជាអ្នកចេះច្បាប់ជ្រៅជ្រះជាងខ្លួនលោកជាចាងហ្វាងទៅទៀត ធ្លាប់មានថ្វីដៃខាងតែងសៀវភៅច្បាប់ បានតែងសៀវភៅច្បាប់មួយឲ្យឈ្មោះថា «សេចក្ដីទូន្មានរបស់ចៅក្រមចាស់ដល់ចៅក្រមក្មេងៗ» ។

តុលាការបានហៅមនុស្សជាប់ចោទទាំងអស់ (សួរសាវតា)

តុលាការ បានឲ្យស្មូត្រសេចក្ដីចោទ

★ ★
★

# ត្រូវចោទ ៖

ទី១- ឈ្មោះ នូ-យ៉ា ពីបទធ្វើមនុស្សឃាដដោយចេត្តនា ដោយបានគិតទុកជាមុន លើរូបលោក អៀវ-កើស និងធ្វើមនុស្សឃាដលើរូបលោក ង៉ែត-ហ៊ាន ដោយបានគិតទុកជាមុន ។

ឈ្មោះ២ដល់ទី១២- ពីបទសមគំនិតក្នុងបទខាងលើ និងទី១ដល់ទី១២- ពីបទស្ម័គ្របក្សពួកនឹងក្រុមសម្រេចឃាដ ។

យោងតាមសេចក្តីដែលបានពិនិត្យលិក្ខិតក្នុងសំណុំរឿងនេះសព្វគ្រប់ទៅ លេចហេតុដូចមានខាងក្រោមនេះ ។

កាលពីថ្ងៃ ១២ ឆ្នាំឆ្លូវឯកស័ក ១៤-១-១៩៥០ នៅទីក្រុងភ្នំពេញ កាលម៉ោង៧យប់ មានមនុស្សកំណាច១នាក់ ទៅលបលួចចោលគ្រាប់បែកនៅក្នុងមន្ទីរចាត់ការគណបក្សប្រជាធិបតេយ្យ ផ្ទះលេខ៦៦ វិថីពិកេ បណ្តាលឲ្យផ្ទុះត្រូវលោក អៀវ-កើស ដល់មរណភាព និងរបួសជាទម្ងន់ដល់លោក ង៉ែត-ហ៊ាន ។

តាមសេចក្តីសង្កេតក្រសួងក្រុមព្រះនគរបាលជាតិ មេតំបន់ទី២ និងទី៣ ១៥-១-១៩៥០ បានសេចក្តីថា រឿងបោះគ្រាប់បែកខាងលើនេះ នៅមន្ទីរចាត់ការគណបក្សប្រជាធិបតេយ្យមានជំនុំពួកសមាជិកនេះថា នៅពេលម៉ោង៧យប់ ពួកសមាជិកលើកជំនុំចេញផុតទៅ មានមនុស្សកំណាច១នាក់ ទៅលបលួចចោលគ្រាប់បែកចូលទៅក្នុងមន្ទីរនោះ ផ្ទុះត្រូវលោក អៀវ-កើស និងលោក ង៉ែត-ហ៊ាន ដែលកំពុងអង្គុយនិយាយគ្នាក្នុងនោះ មានរបួសជាទម្ងន់ ថាលោក អៀវ-កើស ទទួលមរណភាពនៅមន្ទីរពេទ្យព្រះកេតុមាលា ក្រោយនេះ១ម៉ោង ចំណែកលោក ង៉ែត-ហ៊ានត្រូវរបួសជើងជាទម្ងន់ ឯមនុស្សកំណាចនោះ ក្រោយដែលបានប្រព្រឹត្តរួចហើយ រត់កាត់តម្រង់ទៅផ្សារថ្មី ទើបមានទាហានជើងទឹកម្នាក់ជាតិបារាំង ឈ្មោះ ម៉ាកកើ ណូឯល ប្រ៊ែង់ស្វា ដេញតាមចាប់បាន (បារាំងដែលចាប់បានរបៀបដូច្នោះ) នៅថ្ងៃ-ខែ និងពេលម៉ោងដូចខាងលើនេះ ទាហានបារាំងឈ្មោះ ម៉ាកកើ ណូឯល ប្រ៊ែង់ស្វា ដើរមកពីមន្ទីរសេនាធិការដល់មកផ្លូវប៊ូឡូស ឮសូរផ្ទុះគ្រាប់បែក ក្រោយនោះ៣០នាទីស្រាប់តែឃើញ មនុស្ស១នាក់កាន់បេរ៉េនៅដៃ រត់ពីឯជើងទៅឯត្បូងកាត់តម្រង់ទៅផ្សារថ្មី មានជនម្នាក់ជិះទោចក្រយានយន្តបរតាមរកមកដល់បារាំងនោះសួររកមនុស្សដែលរត់ បារាំងនោះប្រាប់ថា ឃើញរត់ទៅផ្សារថ្មី ក៏នាំគ្នាជិះទោចក្រយានយន្ត តាមចាប់បាននៅពេលដែលទើបនឹងឡើងជិះត្រីចក្រយាន ថាបានសួរចម្លើយវាៗឆ្លើយឈ្មោះ នូ-យ៉ា ហើយទទួលសារភាពថា វាបានទៅបោះគ្រាប់បែកនៅក្នុងមន្ទីរចាត់ការគណបក្សប្រជាធិបតេយ្យមែន ហើយឆ្លើយដាក់ឈ្មោះ ប៉ុ

ល-សៀង ជាគូកន ធ្វើការក្រោមបង្គាប់ឈ្មោះ រ៉ុន ១, ជាមេក្រុមសម្ងាត់សម្រាប់ពិឃាដជនខ្លះក្នុងក្រុង មានលំនៅៗក្នុងកំផែងផ្ទះពេទ្យភ្នែក ផ្ទះបាយលោក នាលផ្លែង តែប្រាស្រ័យចេញចូលក្នុងដំណាក់ព្រះអង្គម្ចាស់ នរិន្ទតេជ ។

ឈ្មោះ នូ-យ៉ា មនុស្សត្រូវចោទ ឆ្លើយចំពោះមុខលោកមេតំបន់ទី២ ពីថ្ងៃ១៥-១-១៩៥០ នៅចំពោះមុខសេហ្វស្នួរ តែពីថ្ងៃ១៦-១-៥០, ១៩-១-៥០, ២០-១-៥០ សារភាពហូរហែរដោយសំឡុត ថានៅក្នុងខែកត្តិក ឈ្មោះសៀង១, ស៊ួន១, បានបបួលវាឲ្យចូលធ្វើពួកដើរសម្លាប់កុង្សី បបួលម្តងជា២ដង ទើបវាព្រមចូលថាធ្វើការនោះ បើគេចាប់បានកុំឆ្លើយស៊ូស្លាប់ ថាយើងនឹងសងសឹកឲ្យហើយ ចិញ្ចឹមប្រពន្ធកូន១ខែ៦០០រៀលឡើង ថាបើសម្លាប់បាន១នាក់ ឲ្យ១០០០រៀល ដូច្នេះទើបខ្លួនវាសុខចិត្តចូល ឈ្មោះស៊ួនក៏បានឲ្យប្រាក់វា១០០រៀលភ្លាម ឈ្មោះសៀង, នាង, ស្លួង ក៏នាំគ្នាទៅជួបនឹងឈ្មោះ រ៉ុន (ហៅចៅ-ស៊ុន) ៗក៏សួរដេញដោលពិនិត្យមើលមាត់វា រួចក៏សួរថាសុខចិត្តធ្វើទេ វាថាសុខចិត្តធ្វើក្រោយនោះឈ្មោះសៀងនិងស៊ុនបានប្រាប់វាថា ឥឡូវលោកកុង្សីមកពីស្រុកបារាំងវិញហើយ ល្មមយើងធ្វើការហើយ ហើយក៏នាំគ្នាទៅជួបនឹងឈ្មោះ រ៉ុន ឯផ្ទះឈ្មោះនេះ ទៅដល់ឃើញឈ្មោះ នាង ក៏នៅទីនោះដែរ ហើយក៏គេបង្ហាត់ឲ្យចោលគ្រាប់បែក រួចឲ្យវាទៅវិញទៅ លុះដល់ថ្ងៃដែលចោលគ្រាប់បែក ពេលរសៀលឈ្មោះនាង ទៅហៅឈ្មោះសៀង ៗទៅហៅខ្លួនមក ឯឈ្មោះ នាង ក៏ជិះកង់ទៅមុនឈ្មោះសៀង និងខ្លួនទៅតាមក្រោយដល់ផ្ទះឈ្មោះ រ៉ុន យកគ្រាប់បែកចេញពីផ្ទះឈ្មោះរ៉ុនពេលម៉ោង៦ល្ងាច ឈ្មោះសៀង និងវាដើរតម្រង់ទៅផ្ទះដែលចោលគ្រាប់បែក ដល់ស្នួនច្បារឈ្មោះសៀងចង្អុលប្រាប់ផ្ទះ ថានឹងហើយឲ្យចូលទៅ ថាវាក៏ដើរចូលទៅដល់ ក៏បោះគ្រាប់បែកតាមទ្វារផ្តោងទៅលើឡាបឡែដែលបាំងពីមុខ គ្រាប់បែកធ្លាក់ភ្លាម វាក៏រត់ចេញភ្លាមទៅដល់ថ្នល់ព្ធសួរផ្ទះ ហើយវាក៏រត់ទៅលិចសំដៅទៅផ្សារថ្មី ពុំទាន់ដល់ផងស្រាប់តែបារាំងចាប់វាបានមក វាថាវាបានបើកប្រាក់៥លើកហើយ ១លើក១០០រៀល ជួនកាលបើកពីឈ្មោះ រ៉ុន ហៅ ចៅ-ស៊ុន ជួនកាលបើកពីឈ្មោះ ឃួន-លុត ថាប្រាក់បើកពីឈ្មោះ រ៉ុន ៗយកពីព្រះអង្គម្ចាស់នរិន្ទតេជ ថាឈ្មោះ សៀង បាននិយាយប្រាប់វាមុនចោលគ្រាប់បែក១ថ្ងៃ និងប្រាប់នៅថ្ងៃចោលគ្រាប់បែកនោះ ថាលោកមេប្រជាធិបតេយ្យធ្វើការ៤-៥ឆ្នាំហើយ មិនបានអ្វីដល់រាស្ត្រសោះ, ថាពួកក្រុមដែលសម្រាប់សម្លាប់គេនោះ មានឈ្មោះឯទៀត គឺឈ្មោះ មុំ១, សាយ១, យូវ១, ឆែម១, ច្រិប១ ថាបានដឹងដោយឈ្មោះ ទេព-ស្នួន ប្រាប់ថា ក្រុមនេះសម្រាប់សម្លាប់កុង្សីលក់នគរ ថាខ្លួនវាការក្រោមបង្គាប់ឈ្មោះ រ៉ុន១, សៀង១ មិនដែលបានចូលក្នុងដំណាក់ព្រះអង្គម្ចាស់ នរិន្ទតេជ ទេ ថាឈ្មោះ រ៉ុន មានគ្រាប់បែក៧-៨គ្រាប់ និងពិស្តូឡេ១

តែសព្វថ្ងៃមិនដឹងទុកនៅឯណា ។

ឈ្មោះ នូ-យ៉ា ឆ្លើយថា ឈ្មោះរុនបានប្រាប់វាថា ឈ្មោះសៀងត្រូវធ្វើអ្នកដែលនៅផ្ទះពីរជាន់ នៅកាច់ជ្រុងមុខគេបង្អស់ ថាឈ្មោះសៀងបាននាំវាទៅបង្ហាញផ្ទះថ្មពីរជាន់មួយខាងជើងផ្ទះកុម្មីស្សែរ ហើយប្រាប់ថាអ្នដែលនៅផ្ទះនឹង គេក៏បំរុងនឹងសម្លាប់ដែរ ក្រៅពីផ្ទះនេះ ឈ្មោះសៀងបាននាំទៅបង្ហាញផ្ទះពីរជាន់មួយទៀត នៅខាងកើតព្រះអង្គម្ចាស់ នរិន្ទតេជ ផ្ទះខាងចុងបង្អស់ប្រាប់ថា អ្នកផ្ទះនេះគេប្រុងសម្លាប់ដែរ ហើយថាចាំស្កាត់ផ្សារកាប់គោ ចាំគុបគ្រាប់បែក និងចាំទៅធ្វើផ្ទះមួយទៀតនៅចំការមន ឯសីហនុ ក៏បំរុងនឹងធ្វើមួយដែរនៅថ្ងៃ១៦-១-៥០ និង ២១-៤-៥០ ឈ្មោះ នូ-យ៉ា បានឆ្លើយទទួលសារភាពចំពោះមុខសុភាចាបុរសហួរហែរទៀត ថាកាបោះគ្រាប់បែកនោះមិនចំពោះនឹងចិត្តទេ គឺមកពីឈ្មោះ សៀង១, នាង១, រុន១ ប្រើវានៅក្នុងថ្ងៃនោះ ឈ្មោះសៀងបានទៅហៅវានៅផ្ទះឈ្មោះរុន វានៅចាំក្រៅរបង ឈ្មោះសៀងចូលទៅយកគ្រាប់បែកពីរមកចែកគ្នាកាន់១ម្នាក់ ហើយក៏នាំគ្នាដើរចេញ តម្រង់ផ្ទះចោលគ្រាប់បែកតែម្តង ទៅដល់សៀងបង្ហាញផ្ទះនោះ ហើយក៏ដើរទៅលិចមុខផ្ទះឃ្លាំងប្រាក់ សំឡឹងមើលពីនោះមកពុំឃើញមានមនុស្សដើរចេញចូល ក៏នាំគ្នាដើរមកផ្ទះចោលគ្រាប់បែកនោះ ឈ្មោះសៀងប្រាប់ថាដល់ពេលហើយ វាក៏ចូលទៅបោះគ្រាប់បែកតែម្តងទៅ ឯឈ្មោះសៀងក៏បែរទៅលិច នៅលើស្មៅនោះទៅ វាឆ្លើយហួរហែរដាក់ឈ្មោះដូចរាយខាងលើ ។

ឈ្មោះ នូ-យ៉ា ឆ្លើយទៀតថា ក្រុមធ្វើឥស្សរៈសម្រាប់សម្លាប់នោះ គឺនៅក្រោមបង្គាប់ឈ្មោះរុនទាំងអស់ ថាឈ្មោះរុនជាអ្នកចេញចូលក្នុងដំណាក់ព្រះអង្គម្ចាស់ នរិន្ទតេជ ថាកាលវាព្រមព្រៀងធ្វើហើយ ឈ្មោះសៀងនាំគ្នាមកផ្ទះរុន ជួបនឹងឈ្មោះ នាង១, រុន១, ប្រជុំគ្នា ឈ្មោះ នូ-យ៉ា ឆ្លើយថា ចម្លើយវានៅមុខកុម្មិស្សែរទី២ក្តី នៅមុខមេគិញក្តី ដែលលោកសូត្រឲ្យស្តាប់នោះត្រឹមត្រូវតាមចំណាំហើយ គឺឆ្លើយចំពោះពីចិត្តវាទាំងអស់ ឥតមានអ្នកណាបង្ខិតបង្ខំឲ្យឆ្លើយទេ ម៉្យាងទៀតខោអាវដែលវាពាក់នោះ ពួកក្រុមបើកឲ្យហើយ វាយកទៅបញ្ចាំនៅកុងស៊ីមុខវត្តព្រះពុទ្ធមានបុណ្យ រាជការរឹបយកមកធ្វើជាតាងហើយ ។

គេបានយកឈ្មោះ នូ-យ៉ា ទៅដល់កន្លែងកើតហេតុ ឲ្យធ្វើសញ្ញាបែបបទដែលចោលគ្រាប់បែក ឈ្មោះ នូ-យ៉ា បានធ្វើឲ្យមើលសព្វគ្រប់ ដូចមានក្នុងសេចក្តីកត់ហេតុស្រាប់ (៦៨-៧០)

មនុស្សត្រូវចោទឈ្មោះ ចៅ-ស៊ុន ហៅ រុន បានឆ្លើយទទួលនៅមុខគិញ ថាវាបានស្គាល់ព្រះអង្គម្ចាស់ នរិន្ទតេជ ដោយលោកជួយឲ្យរួចខ្លួនពីបារាំងចោទ ថាវាបានចាំយាមដំណាក់ព្រះអង្គម្ចាស់ នរិន្ទតេជ ជាមួយនឹងឈ្មោះឯទៀតផ្លាស់គ្នាម្តង

ម្នាក់ ថាខ្លួនវានៅជំណាក់ព្រះអង្គម្ចាស់ នរិន្ទតេជ នោះមិនដែលមានរឿងអ្វីទេ គឺលោកស្រឡាញ់ទុកចិត្ត ថាធ្វើបាយនៅផ្ទះលោកពេទ្យ ផ្លែង នោះ នៅពេលដែលលោកទទួលភ្ញៀវធំ លោកឲ្យប្រាក់ខែប្រពន្ធវា១ខែ ២០០រៀល ថាវាយាមផ្ទះព្រះអង្គម្ចាស់នរិន្ទតេជ បានប្រាក់ខែ៣០០រៀលក្នុង១ខែ ថាកាលថ្ងៃបោះគ្រាប់បែកវាមិនដឹងទេ ព្ុតែលោក រស់-សុមិត្ត និងតំណាងរាស្ត្រឈ្មោះ ហ៊ាវ ប្រាប់វា ពួកក្រុមសេរីភាពចំនួន១០នាក់ និងចាម១នាក់នៅជ្រោយចង្វា មកទូលព្រះអង្គម្ចាស់ នរិន្ទតេជ ពីរឿងបោះគ្រាប់បែកនោះ នៅថ្ងៃដដែលពេលល្ងាច ឈ្មោះ ចៅ-ស៊ុន ហៅ រុន ឆ្លើយអំពីចេញចូលក្នុងជំណាក់ព្រះអង្គម្ចាស់ នរិន្ទតេជ នៅថ្ងៃ១៨-១-៥០ ថាកាលពេលព្រះអង្គម្ចាស់ នរិន្ទតេជ នៅថ្ងៃ១៨-១-៥០ ថាកាលពេលម៉ោង៦ ប្រពន្ធវាទៅសួរវា ។ ពុំបានទៅផ្ទះទេ ព្រោះគ្រូកាក់ហៅទៅបាយ ថាតាំងពីថ្ងៃគប់គ្រាប់បែកមកឥតហ៊ានទៅណាមកណាទេ គឺខ្លាចគេគុបគ្រាប់បែក គឺនៅក្នុងជំណា ក់ លុះដល់ថ្ងៃ១៦-១-៥០ វាបានទៅយកព្រះដែលវាជួលគេនៅមុខវត្តសំពៅមាស លុះដល់ម៉ោង១២មកវិញ មិនហ៊ានទៅផ្ទះខ្លាច នៅតែក្នុងជំណាក់ដោយមានគេតាម នៅថ្ងៃ១៨-១-៥០ ពេលព្រឹកថាលោកសក្តិ១ ធិញ បានប្រើមនុស្សម្នាក់មិនស្គាល់ឈ្មោះ ឲ្យគិតជួយដូចម្តេចឲ្យបានឯករាជ្យ វាឆ្លើយថាគ្មានកាំភ្លើងទេ ថាក្រោយ៤-៥ខែមកមាន១នាក់ឈ្មោះ ផុល បបួលវាថា គិតធ្វើដូម្តេចចាប់រដ្ឋាភិបាលទាំងអស់បាន ហើយថាសក្តិ១ ធិញ ចង់ជួបលោកនៅកន្លែងថ្នល់ទទឹង ខ្លួនវាថាមិនអីទេ កុំឲ្យតែចាប់វាសម្លាប់ រំលងមួយខែមក ថាមានឈ្មោះ សួង មកប្រាប់វាថាបំរើ សុវាំងវង្សលោកសក្តិ១ ធិញ ឲ្យទៅជួបនៅកំពង់ត្រាំ ខ្លួនវាក៏បានទៅជួប សុវាំងវង្ស ថាកាំភ្លើងយើងតិច ឲ្យខ្លួនវាគិតជាមួយព្រះអង្គម្ចាស់ នរិន្ទតេជ ឲ្យចំណាយប្រាក់ទើបបាន ថាខ្លួនវាបាននិយាយទៅនឹងព្រះអង្គម្ចាស់ នរិន្ទតេជ ថាគ្មានប្រាក់ទេ និយាយនោះចំនួន១ខែហើយ នៅថ្ងៃ១៨-១-៥០ ឈ្មោះ ចៅ-ស៊ុន ឆ្លើថា ដែលនិយាយនឹងឈ្មោះ ផុល នៅជិតរបងផ្ទះពេទ្យភ្នែក នៅថ្ងៃត្រង់ម៉ោង១២ វាថាស្គាល់ឈ្មោះ យ៉ា១, សៀង១, នាង១, សួង១ ប្រហែល១ខែហើយ ព្រោះឈ្មោះទាំងនោះបានមករកខ្លួនវា ពួកទាំងអស់ធ្វើឥស្សរៈ ថាឲ្យនាំរកទីកន្លែងរដ្ឋសភានិងកន្លែងគណបក្សទាំងប៉ុន្មាន ថាអាទាំងនោះនៅក្រោមបង្គាប់ ពុត-ឆាយ ទាំងអស់ ថាខ្លួនវាក៏នាំឈ្មោះទាំងនោះមើលកន្លែងរដ្ឋសភា១ មន្ទីរគណបក្សប្រជាធិបតេយ្យ និងមន្ទីរសេរីភាព មុនថ្ងៃដែលរដ្ឋសភារលាយ លុះបង្ហាញគេរួចក៏បែកគ្នាទៅ ថាខ្លួនវាក៏បានទៅផ្ទះឈ្មោះ សួង ចំនួន១អាទិត្យ ដើម្បីជំនុំគ្នាពីរឿងបោះគ្រាប់បែកនេះ ជំនុំនៅថ្នល់ជិតផ្ទះឈ្មោះសៀង មានឈ្មោះ យ៉ា១, សួង១, សៀង១ និងខ្លួនវានេះ ថាបានសួរឈ្មោះ យ៉ា ៗថាហ៊ានបោះគ្រាប់បែកហើយ ថាបើបោះត្រូវ ៗឲ្យប្រាក់១០០០រៀល

ជាគ្រាប់បែកដែលបោះនោះ គឺព្រះអង្គម្ចាស់ នរិន្ទតេជ ឲ្យវា៣ថ្ងៃមុនប្រគល់២គ្រាប់ មុនប្រគល់ព្រះអង្គម្ចាស់ នរិន្ទតេជ សួរវាថា ហ៊ានទៅបោះគ្រាប់បែកឬទេ ? «វាថា ហ៊ាន» ហើយសួរថា បើចាប់បាន ថាព្រះអង្គម្ចាស់ឆ្លើយវិញថា ធ្វើកុំឲ្យគេចាប់បាន តែគេចាប់បានមុខជាស្លាប់ ហើយជួយមិនរួចទេ ថាវាយកគ្រាប់បែកដាក់ក្នុងហោ-ប៉ៅ យកទៅទុកក្រោមរទេះសេះកញ្ចាស់មួយ គេដាក់ចោលនៅក្រោមបន្ទប់ខាងជើង ដល់រសៀលម៉ោង៥ ក៏ប្រើឈ្មោះ នាង ឲ្យទៅហៅឈ្មោះ សៀង និងឈ្មោះ យ៉ា មកប្រគល់គ្រាប់បែកហើយប្រាប់ថា មុនចោលឲ្យបើកគន្លិះ ហើយធ្វើឲ្យឈ្មោះ យ៉ាមើលផង ថាបានទទួលគ្រាប់បែកហើយ ឈ្មោះ នាង១, សៀង១, យ៉ា១ ក៏នាំគ្នាទៅដំណាក់ទូលព្រះអង្គម្ចាស់ នរិន្ទតេជ ភ្លាម តាមដំណើរ ថាដល់ម៉ោង៨យប់ ស្រាប់តែឃើញឈ្មោះ អាធំ១ នៅជ្រោយចង្វា អ៊ុក១, កេត១ ថាលោក សុមិត្ត មកខ្សឹបៗនឹងព្រះអង្គម្ចាស់ មិនដឹងជានិយាយការអ្វីទេ ព្រោះគេដេញវាឲ្យទៅឃ្លាម ថា ព្រះអង្គម្ចាស់ នរិន្ទតេជ ចង់សម្លាប់លោក អៀវ-កើស តាំងពីមុនលោក សំបូរ ឡើងធ្វើនាយករដ្ឋមន្ត្រីម្លេះ ថាព្រោះលោក អៀវ-កើស ចេះតែចាក់រុក ថាពួកព្រះអង្គម្ចាស់ នរិន្ទតេជ មានតែឈ្មោះ សៀង១, យ៉ា១, នាង១, ប៉ុណ្ណោះទេ ត្រង់មានបក្សពួកឯណាទៀតមិនដឹងទេ គឺព្រះអង្គម្ចាស់ នរិន្ទតេជ លោកគិតការសម្លាប់នោះប្រហែលជាង៥ខែហើយ គឺដំបូងគិតសម្លាប់លោក អៀវ-កើស បន្ទាប់មកលោក យ៉ែម-សំបូរ ឯត្រង់ព្រះករុណាទុកមួយអន្លើសិន ថាបើព្រះករុណាមិនតាំងឲ្យធ្វើអ្វីទេ នឹងសម្លាប់ទៀត ឯមុនីពង្ស មុនីរេត សម្តេចទាំងពីរនេះសម្លាប់ក្រោយ បានជាសម្លាប់លោក អៀវ-កើស មុន ព្រោះគាប់នឹងព្រះករុណា ហើយចេះតែចាក់រុក ថាព្រះអង្គម្ចាស់ នរិន្ទតេជ មានគ្រាប់បែកប្រហែល១០០ តែកាលបារាំងម្នាក់មិនស្គាល់ឈ្មោះ ផ្លាស់ទៅព្រៃនគរវាយកទៅវិញអស់ទៅ ថាមុនពេលដែលរដ្ឋសភារលា-យ បារាំងនោះតែងយកគ្រាប់បែកមកឲ្យ គ្រាប់នោះលោកទុកក្នុងប៉ុយរូលោក កា-លលោកយកគ្រាប់បែកទៅចែកឲ្យនោះ ឃើញលួកពីក្នុងតុលោក ថាសាស្ត្រាវុធព្រះអង្គម្ចាស់ នរិន្ទតេជ មានកាំភ្លើងខ្លីមួយទៀតនិងពីស្តូឡេ១ ថាក្រោយដែលចោ-លគ្រាប់បែកបានចូលសុំលោករក លោកថាកុំ ស្លាប់លោកហើយបើគេចាប់បានកុំឆ្លើយទទួល តែទទួលជួយមិនរួចទេ ថាក្រោយដែលរលាយរដ្ឋសភា ខ្លួនវាបានទៅជួបនឹងឈ្មោះ គុង នៅផ្ទះបាំងអាំងដូស៊ីន ឈ្មោះ គុង ថាចាំមើលចុះ លោកយ៉ែម សំបូរចិត្តអាក្រក់រំលាយរដ្ឋសភា គង់មានថ្ងៃណាមួយមិនខាន តែឈ្មោះ គុង នេះមិនស្គាល់សាវតាទេ ថាកាលវាទៅជួបនឹងសក្តិ១ធិញនេះ មានពួក ពុត-ឆាយ ម្នាក់មិនស្គាល់ឈ្មោះមកចូលនឹងលោក ធិញ បាននិយាយថា ពួកអ៊ិតសៀប, ម៉ុងស្រេង, ម៉ុងស្រ៊ុន ជាអ្នកទំនុកបំរុងថ្នាំនិងអាវុធ ឲ្យពួកអាចារ្យ យី ដែលប្លន់គេយកប្រាក់

មកឲ្យពួកទាំងនោះ ថាពួកសម្លាប់គេនោះមានឈ្មោះ លុត ទៀត ផ្ទះនៅក្រោយវត្តលង្ការ វាបានជាព្រមធ្វើការនៅក្រុមព្រះអង្គម្ចាស់ នរិន្ទតេជ ព្រោះនិយាយថា លោកបំរុងឲ្យធ្វើ garde républicain ដូចស្រុកអាមេរិកាំង ឲ្យមានសេនាទើបមានដេប៉ុ-តេ ឯស្តេចបើរដ្ឋសភាឲ្យមានក៏ទុក បើមិនឲ្យមានទេនឹងបំបាត់ចោល ព្រះអង្គម្ចាស់នរិន្ទតេជនេះ ថាបើបោះឆ្នោតលើកក្រោយមានសង្ឃឹម ចាំមើលពួកព្រៃ ថាបោះឆ្នោតចាញ់លោកលែងនៅស្រុកហើយ ពីថ្ងៃ២៨-១-៥០ ឈ្មោះ ចៅ-ស៊ិន ឆ្លើយថា ឈ្មោះលុតជាអ្នកបើកប្រាក់ ហើយឆ្លើយថាឈ្មោះ យ៉ា១, សួន១ ជាមនុស្សកូនចៅឈ្មោះ លុត នេះ វាបានបើកប្រាក់ពីឈ្មោះ លុត ទៅលេងតែស៊ីវចាញ់អស់តែម្តង ។

ឈ្មោះ ឃួន-លុត មនុស្សត្រូវចោទ បានឆ្លើយចំពោះមុខ ២៣-១-៥០ ថាបានស្គាល់ព្រះអង្គម្ចាស់ នរិន្ទតេជ និងលោក មាស-ហែល ថាខ្លួនបានចូលគណបក្សរាស្ត្រសេរីភាព លើកក្រោយបានជាប់ជាតំណាងរាស្ត្រ រហូតដល់រលាយរដ្ឋសភា តាំងពីធ្វើតំណាងរាស្ត្រមកចេញចូលក្នុងដំណាក់ព្រះអង្គម្ចាស់ជាធម្មតា លុះមកដល់ថ្ងៃ ១៨-១-៥០ ទើបចូលមកនៅក្នុងដំណាក់ព្រះអង្គម្ចាស់ជាធម្មតា ដោយសម្តេចលោកខ្លាចឃាត់ឲ្យនៅបានជាគ្នា មានឈ្មោះ ជា-ហៀវ ម្នាក់ទៀតនៅជាមួយផង តាំងពីថ្ងៃដែលខ្លួនចូលនៅក្នុងដំណាក់ ខ្លួនមិនដែលចេញទៅជួបនឹងប្រពន្ធកូនទេ លុះតែឈ្មោះ សុខ-ទិត ជាបងថ្លៃខ្លួនចូលមកក្នុងដំណាក់ ទើបខ្លួនបានផ្តាំទៅប្រពន្ធដែលផ្ទះឈ្មោះ សុខ-ទិត នោះ កាលខ្លួននៅធ្វើតំណាងរាស្ត្រ ឈ្មោះស៊ិន បានទៅផ្ទះខ្លួន៤ដង ទៅហៅថា ព្រះអង្គម្ចាស់ឲ្យយកប្រាក់បាំង ថាបានជាស្គាល់ឈ្មោះ ចៅ-ស៊ិន ឈ្មោះនេះនៅក្នុងដំណាក់ព្រះអង្គម្ចាស់ នរិន្ទតេជ ឯឈ្មោះសួន១, សៀង១, យ៉ា១, ខ្លួនមិនស្គាល់ទេ ថាពេលដែលគេចោលគ្រាប់បែក ខ្លួននៅក្នុងដំណាក់ស្តាប់គេជំនុំកែប្រែច្បាប់រដ្ឋធម្មនុញ្ញ មានឈ្មោះ ហៀវ១, គ្រូកាក់១, ប៊ុនរឿន១, ឈឿត១ និងព្រះអង្គម្ចាស់ នរិន្ទតេជ ដល់ពេលម៉ោង៦ ព្រះអង្គម្ចាស់ចេញឡានបរទៅខាងកើតបាត់ទៅ ពុំដឹងលោកទៅណា លុះប្រហែលកន្លះម៉ោង ទើបឃើញលោកមកវិញ ។

ថានៅថ្ងៃ ១៥-១-៥០ ពេលម៉ោង១១ ខ្លួនមកដំណាក់ ឈ្មោះគ្រូ កាក់ សួរខ្លួនថា ដឹងគេចាប់អា ចៅ-ស៊ិន បានឬទេ ខ្លួនថាមិនដឹងទេ ? ហើយសួរទៅវិញថា គេចាប់ដោយហេតុអ្វី ? គ្រូ កាក់ ថា ប្រហែលអា យ៉ា ឆ្លើយដាក់ ថាកាលនោះឃើញព្រះអង្គម្ចាស់ អើតតាមបង្អួត ថាកាលដែលខ្លួនទៅនៅក្នុងដំណាក់ បានជួបព្រះអង្គម្ចាស់ នរិន្ទតេជ ព្រឹកល្ងាច លោកគ្មាននិយាយការអ្វីទេ គ្រាន់តែថាឆ្ងល់ណាស់ បើគេចោលគ្រាប់បែក ត្រូវលោក អៀវ-កើស ហេតុអ្វីបានជារាជការចាប់ ចៅ-ស៊ិន

ថា ខ្លួនបានជិះស៊ីក្លូទៅទិញផ្លាំង អ្នកធាក់ស៊ីក្លូសួរថា កាលណាគេបោះឆ្នោតទៀត ថា ចាំលោក អៀវ-កើស មកពីស្រុកបារាំង ហើយនិយាយនិងអ្នកធាក់ស៊ីក្លូថា ឲ្យជួយរកមនុស្ស ជួយឃោសនាការឲ្យ អ្នកធាក់ស៊ីក្លូក៏ទៅបាត់ទៅ ក្រោមមកចំនួន៦ថ្ងៃ ឃើញអ្នកធាក់ស៊ីក្លូទាំង២នាក់ទៅរកខ្លួន ខ្លួនសួរឈ្មោះទៅប្រាប់ថា ឈ្មោះសួន ១, សៀង១, នាង១, ខ្លួនក៏បានពន្យល់ពីការឃោសនា ហើយពួកនោះក៏ទៅវិញទៅ ក្រោយមក ឃើញឈ្មោះ សួន ទៅផ្ទះខ្លួនហើយប្រាប់ថា មានម្នាក់ទៀតឈ្មោះ យ៉ា ជាគូកនវា ខ្លួនក៏ឲ្យរង្វាន់ទៅឈ្មោះ សួន ៥០រ០០ ថ្ងៃក្រោយឲ្យឈ្មោះសួន ៤រៀល ទៀត ថាខ្លួនទៅទូលព្រះអង្គម្ចាស់ នរិន្ទតេជ ពីរកមនុស្សបានហើយ ៗខ្លួនឲ្យឈ្មោះ ចៅ-ស៊ុន មើលឈ្មោះ សួន និង៣នាក់ទៀត ថាជាមនុស្សជួយឃោសនាការរបស់ យើងហើយ ៗប្រគល់លុយឲ្យជាស្រេច ថាក្នុងខែវិច្ឆិកា (ណូវមប្រ៍) ១៩៤៩ ខ្លួនបានប្រគល់ប្រាក់ ៤០០រ០០ ឲ្យទៅឈ្មោះសួន ចែកគ្នាក្នុងខែធ្នូ (ដេសមប្រ៍) ១៩៤៩ ខ្លួនបានប្រាក់ទៅឈ្មោះសួន ១២០០រ០០ ខ្លួនបានប្រាប់ទៅឈ្មោះសួនថា ឲ្យទៅជំនុំគ្នាជាមួយនឹង ចៅ-ស៊ុន គិតសម្លាប់លោក អៀវ-កើស ជាមេគណបក្ស បើសម្លាប់បាន មុខជាគណៈយើងមានកម្លាំងហើយ ថាដែលប្រើឲ្យឈ្មោះ សួន១, នាង១, យ៉ា១, សៀង១, ឲ្យដើរឃោសនានេះ ដើម្បីឲ្យវាព្រមចុះចូល ព្រមទៅសម្លាប់គេនោះឯង ពីថ្ងៃ២៦-១-៥០ ឆ្លើយទទួលថា ដែលធ្វើឃាតលោក អៀវ-កើស នេះ ខ្លួននិងព្រះអង្គម្ចាស់ នរិន្ទតេជ ជាមេគំនិត ដែលសម្លាប់លោក អៀវ-កើស នោះ គឺឈ្មោះ សួង បានផ្ដើមនិយាយមុន ថាខ្លួនបានទៅទូលព្រះអង្គម្ចាស់ នរិន្ទតេជ ថាសម្លាប់ ៗក៏សម្លាប់ចុះ គិតឲ្យតែស្រួល និងឲ្យបោះឆ្នោតលើកក្រោយនេះ ថាខ្លួនក៏ចេញមកប្រាប់ឈ្មោះ សួន វិញថា ព្រះអង្គម្ចាស់ព្រមហើយ ស្រេចតែឯងទៅគិតគ្នានឹង ចៅ-ស៊ុន ចុះ ពេលនោះ ចៅ-ស៊ុន ក៏ទៅក្នុងជំណាក់ដែរ ថាប្រហែលជា៦ថ្ងៃក្រោយមក ទើបបានចោលគ្រាប់បែក ថាខ្លួនបានបើកប្រាក់ឲ្យឈ្មោះ យ៉ា១, សៀង១, នាង១, សួន១ ក្នុង១ខែ២ដង បើកឲ្យម្ដង៣០០រ០០ ក្រោយ ២០០រ០០ បើកអស់ទាំងអស់ ៤០០០រ០០ ហើយប្រាក់ខ្លួន២០០០រ០០ ព្រះអង្គម្ចាស់ ២០០០រ០០ ដែលសម្លាប់លោក អៀវ-កើស នោះ គឺឲ្យគណបក្សខ្វាត់ខ្វាយទៅ ដើម្បីឈ្នះឆ្នោត ថាព្រះអង្គម្ចាស់នរិន្ទតេជ ក៏យល់ព្រមដូច្នោះដែរ ចម្លើយពីថ្ងៃ២៧-១-៥០ ពេលព្រឹកទំនងដូចខាងលើនេះដែរ អំពីពិគ្រោះនឹងព្រះអង្គម្ចាស់ ពីរឿងសម្លាប់នោះ ថ្ងៃដដែលពេលរសៀល ឆ្លើយថាខ្លួនមិនដែលនាំឈ្មោះទាំង៤នាក់ទៅជួប នឹងព្រះអង្គម្ចាស់នរិន្ទតេជទេ លុះតែលោកត្រូវការ ទើបលោកហៅឲ្យទៅជួបនឹងលោក ពុំដែលហៅដោយសំបុត្រទេ គឺប្រើឈ្មោះ ចៅ-ស៊ុន ឲ្យទៅហៅផ្ទាល់តែម្ដង ដំបូងបំផុតគឺព្រះអង្គម្ចាស់ នរិន្ទតេជ ជាដើមគំនិត គិតពីសម្លាប់លោក អៀវ-កើស នេះ

លោកថា បើសម្លាប់លោក អៀវ-កើសទៅ ងាយនឹងបោះឆ្នោតលើកក្រោយ បើគណ:យើងឈ្នះ នឹងបានកាន់កាប់អំណាចតទៅ ថាខ្លួនឆ្លើយទៅវិញថា បើដូច្នោះចាំទូលព្រះបង្គំទៅប្រាប់អា សួន ឲ្យគិតការនេះ ថាប្រាក់ ២០០៛០០ បើកឲ្យឈ្មោះទាំងប៉ុន្មានខាងលើនេះ គឺចេញជំនួសព្រះអង្គម្ចាស់ នរិន្ទតេជ ព្រោះពេលនេះបើកពីលោកមិនទាន់ ។

ឈ្មោះ ហាន-ច្រិច មនុស្សត្រូវចោទ ឆ្លើយនៅមុខសុភាចាបុរស ពីថ្ងៃ៣១-១-៥០ ថាមិនបានចូលដៃសម្លាប់ទេ មិនដែលស្គាល់ឈ្មោះ ឃួន-លុត១, ងួន-លី១, ឃិន-សែន១, ចៅ-ស៊ិន១, ឃុវ១, នាង១ ទេ ឯឈ្មោះមុំ១ ឆែម១, សួង១, សាយ១, សៀង១, យ៉ា១, ខ្លួនធ្លាប់ស្គាល់យូរមកហើយ ត្រង់ឈ្មោះនេះរកស៊ីអ្វី ឬប្រព្រឹត្តទុច្ចរិតអ្វី ខ្លួនពុំដឹងទេ ថាខ្លួនបានមកនៅផ្ទះឈ្មោះ សួង ផ្ទះនៅទួលតាពូងម្តង មករកការធ្វើ បាន៤ថ្ងៃវិលទៅស្រុកវិញ ដោយឈ្មោះ សួន ពុំឃើញរកការឲ្យធ្វើ ចេះទៃដើរទៅបាត់ទៅ ពីថ្ងៃ២៤-២-៥២ ឆ្លើយនៅមុខគិញថា ឈ្មោះ សួន១, សៀង១, ហៅមកឲ្យទៅទួលតាពូងឲ្យការធ្វើ តែមិនដឹងការអ្វី មួយថ្ងៃឲ្យចាយ៥រៀល ឈ្មោះ សួន និង សៀង ប្រាប់ថាឲ្យនៅតែស្ងៀម ចាំមានការគេហៅ ថាកាលមកនៅនឹងឈ្មោះ សួង ឃើញឈ្មោះ សាយ ដែរ ។

ឈ្មោះ ឡាំ-សុត មនុស្សត្រូវចោទ ឆ្លើយចំពោះមុខសុភាចាបុរស ពីថ្ងៃ២៤-២-៥០ ថាពុំបានសមគំនិតនឹងឃួន-លុត សម្លាប់លោក អៀវ-កើសទេ ថាឈ្មោះឃួនលុតនេះ បានប្រើខ្លួន ឲ្យដើររៃអង្ករនិងប្រាក់ពីអ្នកស្រុក ឃុំត្រពាំងក្រសាំង យកមកចិញ្ចឹមពួកឥស្សរ:នៅភ្នំពេញ ថាគេបង្កើតការយ៉ាងណាក៏ពុំដឹងទេ ថាក្រោយពីបោះគ្រាប់បែកមក នៅថ្ងៃ១៤ ។ ពីឆ្នាំឆ្លូវ ១៧-១-៦០ តំណាងរាស្ត្រ ឃួន-លុត បានទៅជួបនឹងខ្លួន នៅឃុំកំបូល ពេលម៉ោង៩ព្រឹក និយាយប្រាប់ថា ខ្លួនគេបានប្រើឈ្មោះ យ៉ា១, សៀង១, សួន១, ទៅចោលគ្រាប់បែករួចហើយតែប៉ុណ្ណោះ ឈ្មោះ ឃួន-លុត ក៏វិលមកភ្នំពេញវិញមក ថាកាលនិយាយនេះតែ២នាក់ទេ ឆ្លើយនៅមន្ទីរក្រុងព្រះនគរបាលរបៀបដូចខាងលើ ហើយថាខ្លួនចូលធ្វើក្នុងក្រុមលោក ឃួន-លុត ៤-៥ខែមកហើយ មុខការខ្លួនគ្រាន់តែដើររៃអង្ករនិងប្រាក់គឺ ៖

ក្នុងខែមិគ្គសិរ រៃប្រាក់បាន២០០៛០០ អង្ករ៣តៅ

| | | | | |
|---|---|---|---|---|
| - | បុស្ស | - | ៣០០៛០០ | - ៦ - |
| - | មាឃ | - | ៣០០៛០០ | - ៦ - |

ថាឈ្មោះ ឃួន-លុត ប្រើឲ្យរៃលុយនិងអង្ករនោះ

មានឈ្មោះ ឌួង១, ហាន១, ថា ឃួន-លុត ប្រគល់ប្រាក់ឲ្យឈ្មោះ ឌួង និង ហាន ២០០៛០០ ឲ្យយកទៅឲ្យ យ៉ា១, សៀង១, សួន១, ថាឈ្មោះ ច្រិច នោះ ជាកូន

ឈ្មោះ ហាន ធ្វើឥស្សរៈនៅក្រោមបង្គាប់លោក ឃួន-លុត ទើបតែនឹងឈប់នៅពេលដែលគេចាប់ឈ្មោះ យ៉ា និង ឃួន-លុត នោះឯង ថាពួកឥស្សរៈឯទៀត នៅក្រោមបង្គាប់ ឃួន-លុត គឺឈ្មោះ យ៉ា១, សៀង១, សួន១, ឆែម១, យូវ១, ច្រិច១, ថាពីថ្ងៃមុនដែលគេរកចាប់វាបានមកនេះ វាបានឃើញឈ្មោះ សេង-ផុន កាន់កាំ-សែតមួយ មានមនុស្សនៅជុំ ឈ្មោះ សេង-ផុន និយាយថា អ្នករាល់គ្នាដឹងទេ ថ្ងៃស្អែកគេសម្លាប់មេស្រុក លុត ហើយ ថាពុំប៉ុណ្ណោះវាដើរទៅបាត់ទៅ មនុស្សដែលនៅជុំនោះ ស្គាល់ឈ្មោះ គឹម-ឈួន១, ឆែម១, ឆែជាឥស្សរៈក្រោមបង្គាប់ឈ្មោះឃួន-លុត ថាបានជាដឹង ព្រោះឈ្មោះ គឹម-ឈួន សេង-ផុន និងឆែមប្រាប់ ចម្លើយទាំងប៉ុន្មានខាងលើនេះ ឈ្មោះ ឡាំ-សុត បានឆ្លើយចំពោះមុខសុភាចាបុរសថា ជាបរិសុទ្ធត្រឹមត្រូវតាមចំណាំហើយ ។

អំពីបទស្មគ្របក្សពួកជាក្រុមសំរាប់ធ្វើឃាតកម្ម

ឈ្មោះនូ-យ៉ា១, ចៅ-ស៊ិន១, ឃួន-លុត១, ហាន-ច្រិច១, ឡាំ-សុត១, (ឃុំខ្លួន) ឆ្លើយប្រកែកពីសេចក្តីចោទ ឆ្លើយដោះសាទៅផ្សេងៗ ហើយបទល្មើសទាំងអម្បាលមាណ ដែលឈ្មោះទាំងនេះបានប្រព្រឹត្តហើយ ឆ្លើយទទួលសារភាពគ្រប់ខហូរហែដោយសំឡូតរួចមកពីខាងលើហើយនោះ ត្រឡប់ទៅជាធ្វើពាក្យគ្រប់គ្នាប្តឹងតវ៉ាជាក្រោយ សុំឲ្យបដិសេទចម្លើយរៀងខ្លួន ដែលបានឆ្លើយទទួលពីលើកមុននោះចោល អាងហេតុថាខ្លួនទាំងអស់គ្នា បានឆ្លើយទទួលសារភាពមែន តែឆ្លើយដោយក្រសួងព្រះនគរបាលវាយបង្ខិតបង្ខំបង្គាប់ឲ្យឆ្លើយ ពុំមែនឆ្លើយដោយសុចរិតទេ ថាសុំឲ្យសួរចម្លើយពួកខ្លួនជាថ្មីម្តងទៀត តាមសេចក្តីដែលបានស៊ើបសួរបំពេញ បានសេចក្តីថា ឈ្មោះ នូ-យ៉ា១, ចៅ-ស៊ិន១, ឃួន-លុត១, ហាន-ច្រិច១, ដែលបានធ្វើពាក្យតវ៉ាដូចខាងលើ បានមកឆ្លើយប្រកាន់តាមពាក្យតវ៉ានេះរហូត ថាចម្លើយទាំងប៉ុន្មានដែលឆ្លើយនោះ មកពីគុម្មិស្សែរ៍មេគិញនិងភូឈួយគិញវាយដំច្រំធាក់ខ្លួនឲ្យឆ្លើយ ថាវាយបង្ខំនេះឥតមានសាក្សីណាបានឃើញទេ ឯស្លាកស្នាមជាសះអស់ទៅហើយ បានសាកសួរដល់ក្រុមព្រះនគរបាលសព្វគ្រប់តាមចម្លើយមនុស្សត្រូវចោទទាំងនេះទៅ មិនឃើញមានលេចហេតុអំពីវាយដំច្រំធាក់ដូចខាងលើនេះសោះ ចំណែកឈ្មោះនូ-យ៉ា ដែលបានឆ្លើយទទួលរហូត មុខសុភាចាបុរស ថាចម្លើយខ្លួននៅមុខគុម្មិស្សែរ៍ទី២ និងក្រសួងស៊ើបការណ៍សម្ងាត់ទាំងប៉ុន្មាន សុទ្ធតែសុចរិតតាមចម្លើយខ្លួនទាំងអស់នោះ ក៏ឆ្លើយទទួលនៅមុខសុភាចាបុរសដូច្នេះមែន លោកសុភាចាបុរសឥតមានវាយដំកំហែងអ្វីទេ ថាកាលគេនាំមកសាលាលុកឃុន មានមនុស្សជាច្រើនមកឈរមើល ហើយសួរវាថា បានចោលគ្រាប់បែកមែនឬទេ វាឆ្លើយថាបានចោលមែន ។

## យល់ឃើញទូទៅលើអង្គសេចក្ដី

យល់តាមសេចក្ដីដែលបានពណ៌នារួចមកពីខាងលើហើយនេះ ឃើញថាបទល្មើសទាំងអម្បាលមាណ ដែលបានចោទប្រកាន់ទៅលើមនុស្សត្រូវចោទ ឃុំខ្លួននោះ ឈ្មោះទាំងនេះក៏ឆ្លើយទទួលសារភាពគ្រប់ខ គ្រប់អន្លើរួចហើយៗឥឡូវនេះត្រឡប់មកប្រែឆ្លើយប្រកែកទៅវិញ មិនព្រមទទួលតាមចម្លើយមុន ដែលបានឆ្លើយរួចមកហើយនោះៗ ជាការគ្រាន់តែដោះសារទេ ព្រោះគ្មានភស្តុតាងអ្វីខ្លឹមសារល្មមឲ្យយើងស្ដាប់បានសោះ អួតអាងថាឆ្លើយដោយគេវាយបង្ខំបញ្ចេះឲ្យឆ្លើយ តែមិនឃើញស្លាកស្នាមសំអាងអ្វីសោះ ឯតវ៉ាដូចខាងលើនេះ ក៏មិនបានតវ៉ាភ្លាមៗ គឺថា តាំងពីខែយាំងវីយេ ១៩៥០ នៅពេលដែលគេចាប់បានយកមកសួរចម្លើយ ទុកកន្លងមកជាយូរខែ ទើបតវ៉ាជាក្រោយ ការដែលទុកឲ្យយូរទើបតវ៉ានេះ អាចនឹងឲ្យជឿថារឿងដែលតវ៉ានោះពុំពិត គឺគ្រាន់តែជាផ្លូវដោះសារប៉ុណ្ណោះទេ ដើម្បីនឹងបំភ័ន្តតុលាការឲ្យរួចពីសេចក្ដីចោទ ។

មនុស្សត្រូវចោទ គឺព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ១, ប៉ុល-សៀង១, ទេពសួន១, អ៊ុំ-យូវ១, អ៊ុក-សាយ១, អ៊ូវ-មុំ១, មៀច-ឆែម១, បាត់ខ្លួនពុំបានចូលមកដោះសារការពារខ្លួនទេ ។

សរុបហេតុយល់ឃើញថា មានពិរុទ្ធជនល្មមលើមនុស្សត្រូវចោទទាំងប៉ុន្មានដោយបានចម្លើយទទួលសារភាពដូចខាងក្រោមនេះ ៖

### ហេតុដូច្នេះត្រូវចោទប្រកាន់

១-ក, លើរូបឈ្មោះ នូ-យ៉ា ឃុំខ្លួនពីបទធ្វើមនុស្សឃាត លើរូបលោក អៀវ-កើស ដោយចេតនាបានគិតជាមុន ប្រព្រឹត្តនៅទីក្រុងភ្នំពេញ កាលពីយប់ថ្ងៃទី១៤-១-៥០ នៅបន្ទីរចាត់ការគណបក្សប្រជាធិបតេយ្យ ផ្ទះលេខ៦៦ ផ្លូវ កេពិកេ បទល្មើសជាឧក្រិដ្ឋ ដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ២១-៥០១-៥០៥-៥០៦ ព.ទ. ។

ខ- លើមនុស្សត្រូវចោទដដែលខាងលើនេះ នៅវេលានិងទីកន្លែងដូចខាងលើ ថាបានប្រព្រឹទ្ធបទបំណងធ្វើមនុស្សឃាតដោយបានគិតទុកជាមុន លើរូបលោក ង៉ែត-ហ៊ាន បទល្មើសជាឧក្រិដ្ឋ ដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ២១-៧៧-៧៩-៥០១-៥០៦ ព.ទ. ។

២- លើរូប ចៅ-ស៊ិន (ឃុំខ្លួន) បានសមគំនិតក្នុងបទឧក្រិដ្ឋទាំងពីរខាងលើនេះ ដោយបានឲ្យគ្រឿងប្រដាប់ បានឲ្យការផ្សេងៗ និងជួយការពារដោយគំនិតបទល្មើសជាឧក្រិដ្ឋ ដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោស តាមមាត្រាដូចបានចង្អុលក្នុងខទី១-ក និងខខាងលើនេះ ។

៣- លើរូបមនុស្សត្រូវចោទឈ្មោះ ឃួន-លុត (ឃុំខ្លួន) ព្រះអង្គម្ចាស់នរោត្តម សុទ្ធាវង្ស-នរិន្ទតេជ (បាត់ខ្លួន) ថាសមគំនិតក្នុងបទឧក្រិដ្ឋទាំងពីរខាងលើនេះ ដោយបានបង្គាប់បញ្ជា ទំនុកបំរុង ដោយបានចេញប្រាក់ចិញ្ចឹមជាដើម បទល្មើស ឧក្រិដ្ឋដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៨២-៨៣-៨៤-៨៧-២១-៥០១-៥០៥-៥០៦ និងមាត្រា ៧៧-៧៩-៥០១-៥០៥-៥០៦ ព.ទ. ។

៤- លើឈ្មោះ ហាន-ច្រិច១, ឡាំ-សុត១ (ឃុំខ្លួន), អ៊ុំ-យូវ១, ស៊ុក-សាយ១, អ៊ូវ-មុំ១, នៀច-ឆែម១ (បាត់ខ្លួន), ខាងលើដដែល ថាកាលវេលាដែលមិនទាន់ហួសព្រះរាជកំណត់នៅឡើយក្នុងឆ្នាំ១៩៤៩ នៅទីក្រុងភ្នំពេញ បានស្ម័គ្របក្ខពួក និងក្រុមសំរាប់ធ្វើឃាតកម្ម បទល្មើសឧក្រិដ្ឋ ដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២១-២៩០ ព.ទ. ។

ធ្វើនៅមន្ទីរក្រុមមហាអយ្យកានៅថ្ងៃ ៧ ខែសីហា ១៩៥០

| | |
|---|---|
| បានចម្លងត្រឹមត្រូវតាមដើមហើយ | ព្រះរាជបំរើរង |
| សមុហបញ្ជី | ស៊ីញ៉េ ៖ ថាច-ធួន |
| ស៊ីញ៉េនិងត្រា ៖ នៅ-ស៊ុំ | |

បានឃើញ
អ្នកឧកញ៉ាចាងហ្វាង
ស៊ីញ៉េនិងត្រា ៖ សៅ-អ៊ួន

❑ ❑

❑

តុលាការបានហៅសាក្សីទាំងអស់ ។

តុលាការសួរមនុស្សជាប់ចោទ ។

ចំពោះឈ្មោះ នូ-យ៉ា

លោកចាងហ្វាង (សួរ) ក្នុងថ្ងៃទី១៥ មករា ឆ្នាំ១៩៥០ ម៉ោង៧យប់ អ្នកឯងបានចោលគ្រាប់បែកនៅមន្ទីរចាត់ការគណបក្សប្រជាធិបតេយ្យ ត្រូវឯ.ឧ. អៀវ-កើស ស្លាប់មែនទេ ?

នូ-យ៉ា ៖ ទេ ។

លោកចាងហ្វាង ៖ ចុះបើអ្នកឯងមិនចោលគ្រាប់បែកទេ ម្តេចក៏អ្នកឯងរត់ពេលនោះ ?

នូ-យ៉ា ៖ បានជាខ្ញុំរត់ ព្រោះខ្ញុំភ័យនឹងសូរគ្រាប់បែកផ្ទុះ ។

លោកចាងហ្វាង ៖ ចុះអ្នកឯងមកធ្វើអ្វីនៅទីនោះ ?

នូ-យ៉ា ៖ ខ្ញុំមកផ្សារត្រូវការទិញថ្នាំយកទៅឲ្យប្រពន្ធ ដល់ឮសូរគ្រាប់បែក ខ្ញុំក៏រត់ឡើងស៊ីក្លូ ស្រាប់តែឃើញគេមកចាប់ខ្ញុំ ។

លោកចាងហ្វាង ៖ ដល់គេចាប់អ្នកឯងបានហើយ គេនាំយកអ្នកឯងទៅឯណា ?

នូ-យ៉ា ៖ គេនាំខ្ញុំទៅមន្ទីរតម្រួតក្រុមព្រះនគរបាលផ្នែកទី២ ។

លោកចាងហ្វាង ៖ តាមចម្លើយអ្នកឯងចុះថ្ងៃទី១៥=១=៥០ ម៉ោង១៥:៣០ នៅមន្ទីរតម្រួតក្រុមព្រះនគរបាលផ្នែកទី២ បានទទួលសារភាព ហើយបានឆ្លើយដាក់ឈ្មោះ ចៅ-ស៊ុន, ឃួន-លុត មិងព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ, តាមចម្លើយអ្នកឯងចុះថ្ងៃទី ១៦-១-៥០ នៅមន្ទីរស៊ើបសួរសុភាចារបុរស បានទទួលសារភាព និងឆ្លើយដាក់ឈ្មោះ ចៅ-ស៊ុន, ឃួន-លុត និងព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ, តាមចម្លើយអ្នកឯងចុះថ្ងៃទី ៦-៧-៥០ នៅសាលាក្រុមចោទប្រកែកថា ឆ្លើយនៅមន្ទីរតម្រួតក្រុមព្រះនគរបាលផ្នែកទី២ ដោយគេវាយបង្ខំ, ថាឆ្លើយនៅមន្ទីរស៊ើបសួរសុភាចារបុរស ដោយខ្លាចលោក តាន់-គឹមតឹក ជានាយកក្រុមព្រះនគរបាលជាតិ ដែលជូនដល់មាត់ទ្វារ, ថាចម្លើយនៅមន្ទីរក្រុមព្រះនគរបាលជាតិដោយគេវាយបង្ខំ ។

ចំពោះឈ្មោះ ចៅ-ស៊ុន ។

លោកចាងហ្វាង ៖ ចម្លើយអ្នកឯងនៅមន្ទីរក្រុមព្រះនគរបាលជាតិលើកដំបូងប្រកែក, លើកក្រោយមកទទួលសារភាព, ហើយឆ្លើយថាឈ្មោះឃួន-លុត និងព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ, នៅមន្ទីរស៊ើបសួរសុភាចារបុរស អ្នកឯងប្រកែកវិញ, តែដល់មន្ទីរក្រុមព្រះនគរបាលជាតិ អ្នកឯងត្រឡប់ជាឆ្លើយទទួលសារភាព

វិញ, នៅសាលាក្រុមចោទអ្នកឯងប្រកែកវិញទៀត, តើឥឡូវអ្នកឯងថាម៉េច ?

ចៅ-ស៊ិន ៖ បានជាខ្ញុំឆ្លើយទទួលដោយគេវាយបង្ខំ ។

ចំពោះឈ្មោះ ឃួន-លុត ។

លោកចាងហ្វាង ៖ ចម្លើយអ្នកឯងនៅមន្ទីរព្រះនគរបាលជាតិនៅថ្ងៃទី២៣-១-៥០ អ្នកឯងប្រកែកហើយថាមិនបានស្គាល់ឈ្មោះ សៀង ឈ្មោះ សួន និងនូ-យ៉ាទេ, ចម្លើយនៅថ្ងៃទី២៦-១-៥០ អ្នកឯងឆ្លើយទទួលសារភាព តើឥឡូវអ្នកឯងថាម៉េច ?

ឃួន-លុត ៖ បានជាខ្ញុំឆ្លើយសារភាព ដោយគេវាយបង្ខំ ។

ចំពោះឈ្មោះ ហាន-ច្រិច ។

លោកចាងហ្វាង ៖ ចម្លើយអ្នកឯងនៅក្រុមព្រះនគរបាលជាតិ ថាបានវៃអង្ករនិងប្រាក់យកទៅឲ្យឈ្មោះឃួន-លុត ចិញ្ចឹមពួកឥស្សរៈនៅក្រុងភ្នំពេញ ។

ហាន-ច្រិច ៖ ខ្ញុំមិនបានវៃទេ ។

ចំពោះឈ្មោះ ឡាំ-សុត ៖ ខ្ញុំមិនបានដឹងអ្វីសោះ រួចយំ ។

លោកចាងហ្វាង ៖ យើងសម្គាល់ថា ឡាំ-សុត ដូចជាមនុស្សវិបត្តិចរិត ។

តុលាការ សួរសាក្សី

ចំពោះឈ្មោះ តាន់-គីស៊ិត

លោកចាងហ្វាង ៖ អ្នកបានដឹងរឿងគេបោះគ្រាប់បែកនៅវេលាយប់ថ្ងៃទី១៤-១-៥០ ទេ ?

តាន់-គីស៊ិត ៖ នៅវេលាម៉ោង ៧:៤៥ យប់ថ្ងៃទី១៤-១-៥០ ខ្ញុំបានឮសូរក្តុងយ៉ាងខ្លាំង ខ្ញុំក៏ស្ទុះចេញមកមើល ឃើញមនុស្សម្នាក់ស្លៀកពាក់ខ្មៅ រត់តាមរបៀងផ្ទះទៅខាងលិច ដល់ឮកេស្រែកថាចាប់ៗ ខ្ញុំក៏អើតមើលបញ្ជាក់ទៅឃើញមនុស្សស្លៀកពាក់ខ្មៅដែលរត់ទៅខាងលិចនោះ រត់បត់ទៅឯត្បូង, ខ្ញុំក៏ស្ទុះយកម៉ូតូជិះដេញតាមប្រកិតទៅ បានជួបទាហានជើងទឹកបារាំងម្នាក់ បានហៅទាហាននោះឡើងជិះម៉ូតូជាមួយ ដេញតាមប្រកិតទៅទៀត ដល់ទៅភោជនិយដ្ឋានប៉ារីស (ផ្សារថ្មី) ឃើញអ្នករត់នោះរត់ចូលតាមច្រកតូចមួយ, ទាហានបារាំងនោះលោតរត់ដេញតាមច្រកនោះពីខាងកើត, ខ្ញុំជិះម៉ូតូស្កាត់ទៅព័ទ្ធពីខាងលិច ដល់មាត់ច្រកខាងលិច ឃើញអ្នករត់នោះឡើងជិះស៊ីក្លូ ខ្ញុំក៏ស្ទុះទៅចាប់បានលើស៊ីក្លូនោះយកទៅប្រគល់ឲ្យតម្រួតក្រុមព្រះនគរបាលផ្នែកទី២ ។

ចំពោះលោក ង៉ែត-ហ៊ាន ។

លោកចាងហ្វាង ៖ សុំឲ្យលោកបរិយាយរឿងតាមចំណាំរបស់លោក ។

លោកង៉ែត-ហ៊ាន ៖ នៅយប់ថ្ងៃទី១៤-១-៥០ សមាជិកគណបក្សប្រជាធិប-

តេយ្យជាច្រើននាក់ បានទៅប្រជុំគ្នានាមន្ទីរចាត់ការគណបក្សនេះ, ខ្លួនខ្ញុំក៏ទៅដែរ តែបើករទេះឡានទៅដល់ទីនោះក្រោយគេ លុះបញ្ឈប់រទេះឡាននៅមុខមន្ទីរចាត់ការនោះ ខ្ញុំបានឃើញមនុស្សពីរហាក់មិនស្គាល់ឈ្មោះ ស្លៀកពាក់ខោអាវខ្លីៗពណ៌ខ្មៅ អង្គុយនៅចិញ្ចើមថ្នល់ឆៀងខាងលិចមន្ទីរនោះ, លុះខ្ញុំចូលទៅដល់ក្នុងមន្ទីរ ឃើញលោកអតីតប្រធាន អៀវ-កើស អង្គុយតែពីរនាក់នឹងលោក ហាក់-ម៉ុងសេង ឯសមាជិកក្រៅពីនេះគេចេញទៅអស់ ។ លោកអតីតប្រធានបានសួរខ្ញុំថា លោកមានដឹងការអ្វីប្លែកទេ ពីដំណើរការកែប្រែរដ្ឋធម្មនុញ្ញ ? ខ្ញុំឆ្លើយថា មិនបានដឹងទេ, ខ្ញុំត្រឡប់សួរទៅលោកអតីតប្រធានវិញថា ចុះពួកសមាជិកដែលបានមកប្រជុំក្នុងពេលនេះ តើជំនុំពីរឿងអ្វីខ្លះ ? លោកអតីតប្រធានប្រាប់ខ្ញុំថា ជំនុំពីរឿងធ្វើសន្និសីទចំពោះករណីដែលលោកទៅស្រុកបារាំង...។ ដល់លោកហាក់-ម៉ុងសេងចេញទៅមុនផុតទៅ ស្រាប់តែឃើញដុំមួយរមៀលចូលមកតាមមាត់ទ្វារ ។ លោកអតីតប្រធានសួរថាដុំអ្វីនោះដូចជាដបទឹកខ្មៅ ? ខ្ញុំក៏ស្ទុះក្រោកពីកៅអីសំដៅទៅមាត់បង្អួច បានឃើញមនុស្សពីរនាក់កំពុងតែរត់ គឺម្នាក់រត់តាមរបៀងផ្ទះទៅខាងលិច ម្នាក់ទៀតរត់ទៅតាមថ្នល់ ដល់ដុំនោះផ្ទុះឡើងត្រូវលោកអតីតប្រធានធ្លាក់ពីលើកៅអីដួលទៅ លោកស្រែកប្រាប់ខ្ញុំថា មិនមែនដបទឹកខ្មៅទេ គឺគ្រាប់បែកដៃ ហើយក៏លោកបាត់មាត់ទៅ ខ្លួនខ្ញុំក៏ត្រូវបាក់ជើងខាងស្តាំ និងរបួសជើងខាងឆ្វេងជាច្រើនអន្លើ ។

លោកចាងហ្វាង ៖ ចុះមនុស្សដែលរត់នោះ លោកបានស្គាល់វាទេ ?

លោកង៉ែត-ហ៊ាន ៖ មនុស្សដែលរត់នោះ គឺមនុស្សដែលអង្គុយនៅលើចិញ្ចើមថ្នល់នោះឯង ខ្ញុំចំណាំតាមសំលៀកបំពាក់វា តែខ្ញុំមិនឃើញមុខវា ឃើញតែបីក្រោយខ្នង ។ ដល់ពេលរសៀលថ្ងៃបន្ទាប់មក បានឃើញក្រុមព្រះនគរបាលនាំមនុស្សដែលគេចាប់បាននោះទៅបង្ហាកខ្ញុំឯមន្ទីរពេទ្យព្រះកេតុមាលា, ពេលនោះខ្ញុំនិយាយពុំរួច ខ្ញុំគ្រាន់តែឲ្យសញ្ញាថា ប្រហែលជាមនុស្សហ្នឹងហើយ ដែលខ្ញុំបានឃើញវាកំពុងរត់ ។

ចំពោះឈ្មោះ ជាម-ឃុន ។

លោកចាងហ្វាង ៖ អ្នកបានឃើញគេរត់មែនឬទេ នៅពេលដែលគេចោលគ្រាប់ចែកត្រូវ ឯ.ឧ. អៀវ-កើស ។

ជាម-ឃុន ៖ ខ្ញុំបាទបានឃើញមនុស្សម្នាក់សៀកខោចិនខ្មៅ ពាក់អាវសឺមីសខ្មៅ ពាក់បេរ៉េខ្មៅ បានរត់កាត់មុខខ្ញុំបាទ ត្រង់ផ្លូវប៉ូឡូសសំដៅទៅផ្សារថ្មី ។

លោកចាងហ្វាង ៖ អ្នកបានសួរទៅមនុស្សអ្នករត់នោះទេ ?

ជាម-ឃុន ៖ ខ្ញុំបាទបានសួរថា ហេតុអ្វីបានជារត់ដូច្នេះ ? អ្នករត់នោះឆ្លើយមកខ្ញុំបាទវិញ សួរធ្វើអី ហើយក៏រត់លឿនបាត់ទៅ ។

លោកចាងហ្វាង ៖ ចុះមានអ្នកណាដេញតាមមនុស្សនោះទេ ?

ជាម-ឃុន ៖ បន្តិចមកទើបមានម៉ូតូស៊ីក មានមនុស្សពីរឬបីនាក់ដេញតាមទៅទៀត ។

លោកចាងហ្វាង ៖ ចុះអ្នកឯងចាំភិនភាគអ្នករត់នោះទេ ?

ជាម-ឃុន ៖ ខ្ញុំបាទចាំមុខមិនបានទេ តែមនុស្សនោះរាងក្រអាញមាំ សម្បុរស្បែកកាត់សក់ឡូងសុង ។

លោកចាងហ្វាង ៖ ចុះក្នុងមនុស្សជាប់ចោទដែលមានខ្លួននៅទីនេះ អ្នកចង្អុលមើល តើអ្នកណាមួយ ?

ជាម-ឃុន ៖ ខ្ញុំបាទបញ្ជាក់ជូនឲ្យច្បាស់ពុំបានទេ ព្រោះស្រពិចស្រពិលទៅហើយ ។

ចំពោះឈ្មោះ ត្រឹង-តុង ។

(ចំឡើយឈ្មោះនេះដូចឈ្មោះ ជាម-ឃុន)

ចំពោះឈ្មោះ ហៃ-មុយឆៃ

លោកចាងហ្វាង ៖ អ្នកបានឃើញគេចាប់ឈ្មោះ នូ-យ៉ា ដូចម្ដេចខ្លះ ?

ហៃ-មុយឆៃ ៖ ខ្ញុំបាទបានឃើញគេចាប់មនុស្សនោះនៅមាត់ច្រកឡើងហែមត្រង់ជ្រុងផ្លូវដូហ្វ៊ូឃីនិងម៉ូរិស្សិឡុង មនុស្សនៅហាកំពុងតែហាត់បែកញើសរកតែនិយាយពុំកើតផង ។

លោកចាងហ្វាង ៖ តើគេចាប់បាននៅពេលកំពុងរត់ ឬនៅលើស៊ីក្លូ ?

ហៃ-មុយឆៃ ៖ (ឆ្លើយដោយប្រពិចស្រពិល) ចាប់បាននៅវេលាកំពុងរត់ ។ ( ត្រង់នេះ លោមធាវី ហ្វៀរណង់ដែស្ស-សមសុន បានសុំអនុញ្ញាតបញ្ជាក់ជូនតុលាការបន្តិច ហើយបានអធិប្បាយថា ក្នុងពេលដែលចាប់នោះ គឺចាប់នៅលើស៊ីក្លូ លោកម៉ារគស្ទ័រធ្វើទាហានជើងទឹក និងតាន់-គីស៊ុត ដែលបានចាប់មនុស្សនោះ ក៏បានឆ្លើយឲ្យការថាចាប់លើស៊ីក្លូ តែមានការមួយប្លែកបន្តិច គឺកាលណោះមានមនុស្សម្នាក់ជិះប៊ីស៊ីក្លែតមកទ្រោបលើស៊ីក្លូ ហាក់ដូចជាមកចង់សង្គ្រោះមនុស្សដែលគេចាប់នោះ តាន់-គិសុតបានសួរមនុស្សដែលមកទ្រោបលើស៊ីក្លូនោះថា អ្នកឯងធ្វើការអី ? ស្រាប់តែមនុស្សនោះដើរចេញទៅវិញទៅ បើប្រសិនជាមនុស្សនោះបានឆ្លើយថា ខ្លួនធ្វើគិញ ម្ល៉េះសមគេប្រគល់អ្នករត់នោះឲ្យទៅអ្នកទ្រោបនោះហើយ ។ ឈ្មោះ នូ-យ៉ា មើលទៅប្រហែលជានឹងបាត់ខ្លួនតាំងពីថ្ងៃនោះទៅហើយ) ។

ចំពោះលោក តាន់-កែមឡុង (ភូឈ្មួយមេក្រុមព្រះនគរបាលផ្នែកទី២) ។

លោកចាងហ្វាង ៖ លោកបានសួរចម្លើយឈ្មោះ នូ-យ៉ា ទេ កាលដែលចាប់ឈ្មោះនេះមក ?

តាន់-កែមឡុង ៖ ក្នុងយប់ដែលចាប់នោះ បានសួរត្រួសៗដែរ តែពុំបានកត់ចំឡើយទេ ក្នុងពេលនោះឈ្មោះ នូ-យ៉ា បានប្រកែក ដល់ស្អែកឡើងម៉ោង១៥កន្លះបានសួរតទៅទៀត ចំពោះមុខប៉ូលិស ជា-ឡុង, ឈ្មោះនូ-យ៉ាបានឆ្លើយថា ខ្លួនបានចោលគ្រាប់បែកមែន ។

លោកចាងហ្វាង ៖ ចុះនូ-យ៉ា បានឆ្លើយដល់អ្នកសមគំនិតនិងអ្នកផ្ដើមគំនិតឬទេ ?

លោកតាន់-កែមឡុង ៖ បានឆ្លើយដែរ តែខ្ញុំបាទមិនចាំឈ្មោះ ។

លោកចាងហ្វាង ៖ ចុះ នូ-យ៉ា បានឆ្លើយដល់ព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ និងមនុស្សជាប់ចោទដែលមានខ្លួននៅក្នុងទីនេះឬទេ ?

លោកតាន់-កែមឡុង ៖ គ្មានទេ ។

លោកចាងហ្វាង ៖ ចុះមានឆ្លើយដាក់ឈ្មោះសៀងឬទេ ?

លោកតាន់-កែមឡុង ៖ (ទ្រឹងមួយស្របក់) ដូចជាឆ្លើយដល់ដែរ ។

លោកចាងហ្វាង ៖ ចុះកាលពីសួរនោះ មានធ្វើទុក្ខធ្វើបាបអ្វីទេ ?

លោកតាន់-កែមឡុង ៖ ទេ ។

លោកចាងហ្វាង ៖ ចុះកាលដែលសួរចំឡើយនោះ មានធ្វើធ្វើសេចក្ដីកត់ហេតុដោយត្រឹមត្រូវឬទេ ?

លោកតាន់-កែមឡុង ៖ បានធ្វើ តែខ្ញុំបាទមិនបានស៊ីញ៉េទេ ។

ចំពោះលោក ជា-ឡុង ដោយប៉ូលិស

លោកចាងហ្វាង ៖ សេចក្ដីកត់ហេតុមានធ្វើឬ ?

ជា-ឡុង ៖ នូ-យ៉ាបានផ្ដិតដៃ, លោកតាន់-កែមឡុងបានស៊ីញ៉េ ហើយជូនទៅលោក សេង-ទិប មេក្រុមព្រះនគរបាលផ្នែកទី២ ។

លោកចាងហ្វាង ៖ (បានហៅលោក តាន់-កែមឡុងមកតទល់នឹងលោកជា-ឡុង) លោកតាន់-កែមឡុង ចុះរឿងស៊ីញ៉េនោះមែនឬមិនមែន ? ។

លោកតាន់-កែមឡុង ៖ ខ្ញុំបាទនឹកឃើញហើយ ខ្ញុំបាទបានស៊ីញ៉េត្រឹមត្រូវមែន ។

លោកចាងហ្វាង ៖ (សួរទៅនូ-យ៉ា) អ្នកឯងបានឆ្លើយដាក់អ្នកណាខ្លះ ?

នូ-យ៉ា ៖ ដល់ឈ្មោះឃុត១, ប៊ុន១, និងឈ្មោះ ហ៊ាន ជាចៅហ្វាយស្រុកឥស្សរៈនៅកំបូល ។

ចំពោះលោក សេង-ទិប ជាកុម្មីស្សែរ ផ្នែកទី២

លោកចាងហ្វាង ៖ រឿងបោះគ្រាប់បែកដល់ទៅបង់ជីវិតឯ.ឧ. អៀវ-កើស ជាអតីតប្រធានរដ្ឋសភា នោះលោកបានដឹងយ៉ាងណាខ្លះ ?

លោកសេង-ទិប ៖ នៅពេលដែលចោលគ្រាប់បែកហើយ បារាំងបានចាប់មនុស្សអ្នកចោលបាន ហើយនាំមកកុម្មិស្សារិយ៉ាផ្នែកទី២ ។ ខ្ញុំបាទបានឲ្យប៉ូលិសដាក់ខ្នោះនៅនឹងកន្លែងមួយឥតមានស៊ើបសួរអ្វីទេ នៅពេលយប់ ដោយខ្ញុំបាទរវល់សួរចំឡើយបារាំងដែលជាអ្នកចាប់នោះ និងសាក្សីដទៃទៀត ព្រមទាំងទៅពិនិត្យដល់ទីកន្លែងកើតហេតុនោះផង ។ ដល់ថ្ងៃអាទិត្យទី១៥ មករា ១៩៥០ ម៉ោង២០ ទើបចាប់ស៊ើបសួរមនុស្សដែលចាប់បាននោះ ។

លោកចាងហ្វាង ៖ មានអ្នកណាសួរចំឡើយលោកនូ-យ៉ានេះមុនលោកទេ ?

លោក សេង-ទិប ៖ លោកកែម-ឡុង សួរមុន ទើបខ្ញុំបាទសួរក្រោយ ។

លោកសេង-ទិប ៖ នៅពេលដែលចោលគ្រាប់បែកហើយ បារាំងបានចាប់មនុស្សអ្នកចោលបាន ហើយនាំមកកុម្មិស្សារិយ៉ាផ្នែកទី២ ។ ខ្ញុំបាទបានឲ្យប៉ូលិសដាក់ខ្នោះនៅនឹងកន្លែងមួយឥតមានស៊ើបសួរអ្វីទេ នៅពេលយប់ ដោយខ្ញុំបាទរវល់សួរចំឡើយបារាំងដែលជាអ្នកចាប់នោះ និងសាក្សីដទៃទៀត ព្រមទាំងទៅពិនិត្យដល់ទីកន្លែងកើតហេតុនោះផង ។ ដល់ថ្ងៃអាទិត្យទី១៥ មករា ១៩៥០ ម៉ោង២០ ទើបចាប់ស៊ើបសួរមនុស្សដែលចាប់បាននោះ ។

លោកចាងហ្វាង ៖ មានអ្នកណាសួរចំឡើយលោកនូ-យ៉ានេះមុនលោកទេ ?

លោក សេង-ទិប ៖ លោកកែម-ឡុង សួរមុន ទើបខ្ញុំបាទសួរក្រោយ ។

លោកចាងហ្វាង ៖ លោកបានទទួលលិខិតស៊ើបសួរលើកទីមួយ ដែលលោកជា-ឡុង ថាបានជូនទៅឲ្យលោកនោះឬទេ ?

លោក សេង-ទិប ៖ ខ្ញុំបាទបានទទួល តែវង្វេងដៃបាត់នៅក្នុងពេលនេះ ។

លោកចាងហ្វាង ៖ លោកបានមើលលិខិតនោះទេ ?

លោក សេង-ទិប ៖ ខ្ញុំបាទមិនបានមើលទេ ។

លោកចាងហ្វាង ៖ ក្នុងពេលដែលស៊ើបសួរនោះ មានគ្នាប៉ុន្មាននាក់ ? ។

លោក សេង-ទិប ៖ មានគ្នា៣នាក់ គឺខ្ញុំបាទ, លោកតាន់-គឹមតិក ជានាយក្រុមព្រះនគរបាលជាតិ និងលោកជា-ឡុង ។

លោកចាងហ្វាង ៖ តាមធម្មតាមក នៅពេលស៊ើបសួរ លោកនាយក្រុមព្រះនគរបាលជាតិ តែមកជួយស៊ើបសួរដែរឬទេ ? ។

លោក សេង-ទិប ៖ មិនដែលមកទេ, ទើបតែនៅពេលនោះ លោកមកចាំខ្ញុំបាទនៅខាងក្រៅយូរ លោកក៏ចូលទៅ ។

លោកចាងហ្វាង ៖ លោកជា-ឡុង, ថាចម្លើយដែលលោកនូ-យ៉ាឆ្លើយនៅលើកទីមួយ ខុសពីចម្លើយលើកទីពីរដែលលោកស៊ើបសួរ មានឆ្លើយដល់លើរូបមនុស្ស៤នាក់ផ្សេងៗពីមនុស្ស៤នាក់ ដែលឆ្លើយលើកទីមួយ ។

លោក សេង-ទិប ៖ ត្រង់ផ្សេងឬមិនផ្សេង កាលនោះខ្ញុំបាទមិនបានសួរលោកជា-ឡុងទេ ហើយលោកជា-ឡុងក៏មិនឃើញមានប្រាប់អ្វីដល់ខ្ញុំបាទដែរ ។

លោកចាងហ្វាង ៖ ក្នុងការសួរចម្លើយនេះ លោកបានវាយបង្ខិតបង្ខំទេ ? ។

លោក សេង-ទិប ៖ គ្មានការវាយបង្ខិតបង្ខំទេ គឺឈ្មោះនេះទទួលសារភាពដោយស្រួលទាំងអស់ ។

លោកចាងហ្វាង (បែរទៅសួរនូ-យ៉ាថា) គេថាសួរអ្នកឥតមានវាយដំអ្វីទេ សួរដោយស្រួលទាំងអស់ ម្តេចក៏អ្នកឯងឆ្លើយថាគេវាយបង្ខំឲ្យឆ្លើយ ?

នូ-យ៉ា ៖ ទានប្រោស, គ្មានសួរដោយស្រួលទេ គឺលោកហ្នឹងហើយដែលជា

ល់ ហើយទាត់ខ្ញុំបាទផង, លោកដាល់មួយដៃៗមិនលេងទេ ខ្លាំងៗណាស់ ។
លោកចាង់ហ្វាង ៖ (ក៏បែរទៅសួរលោកសេង-ទិបតទៅទៀតថា) លុះស៊ើបសួរហើយ លោកបានបញ្ជូនឈ្មោះនូ-យ៉ាទៅណាទៀត ? ។
លោក សេង-ទិប ៖ លុះសួរហើយ, ខ្ញុំបាទបានបញ្ជូនទៅក្រុមព្រះនគរបាលជាតិទាំងយប់នោះ ។
លោកមេធាវី- ហ្វៀរណង់ដៃស្ស សម-សុន (សុំឲ្យលោកចាងហ្វាងសួរលោកសេង-ទិបថា) ហេតុអ្វីក៏បានជាបញ្ជូនទៅក្រសួងព្រះនគរបាលជាតិទាំងយប់ តើមានបង្គាប់ពីណាមក ? ព្រោះតាមធម្មតាត្រូវបញ្ជូនឲ្យសុភាចារបុរសឯណោះទេ ?
លោក សេង-ទិប ៖ បានជាខ្ញុំបញ្ជូនទៅក្រសួងព្រះនគរបាលជាតិទាំងយប់ដូច្នេះ ព្រោះរឿងនេះជារឿងធំ ទើបនឹងមានម្ដងក្នុងស្រុកខ្មែរ ហើយចំឡើយរបស់ឈ្មោះនេះ នៅឲ្យមានការស៊ើបសួរជាសម្ងាត់តទៅទៀត ។ ការបញ្ជូននេះ ខ្ញុំធ្វើដោយចិត្តឯងគ្មានទទួលបង្គាប់ពីណាទេ ។
លោកមេធាវី ហ្វៀរណង់ដៃស្ស សម-សុន សុំឲ្យលោកចាងហ្វាងសួរលោកសេង-ទិបតទៅទៀត ថាលោកនូ-យ៉ា មុនបាយឬក្រោយបាយ ព្រោះឮថាលោកទៅបាយឯណា, និយាយការជាមួយអ្នកឯណា រួចទើបត្រឡប់មកសួរវិញ, ត្រង់នេះខ្ញុំសង្ស័យណាស់ ?
លោក សេង-ទិប ៖ វេលាយប់នោះ ខ្ញុំឥតទទួលទានបាយទេ លុះសួររួច ទើបខ្ញុំទៅទទួលទានភោជនីយដ្ឋានហីម៉ាលយ៉ា ។
លោកមេធាវី ហ្វៀរណង់ដៃស្ស សម-សុន ៖ តាមចំឡើយឃើញថាលោកសេង-ទិប ធ្វើឲ្យបាត់លិខិតសាធារណៈ ដែលមានសារៈសំខាន់, ហេតុនេះ ខ្ញុំសូមប្រគល់រឿងនេះ ជូនលោកព្រះរាជបំរើចោទប្រកាន់ចុះ ។
លោកព្រះរាជបំរើ (ក៏សួរទៅលោកសេង-ទិបភ្លាមថា) លិខិតនោះនៅឯណា?
លោក សេង-ទិប ៖ មិនដឹងនៅឯណាទេ បាត់ទៅហើយ ។ ខ្លួនខ្ញុំជាកុម្មិស្សែរត្រូវទទួលខុសត្រូវចំពោះកិច្ចការទាំងពួងដោយខ្លួនឯងទាំងអស់ ។ ព្រោះតែខ្ញុំមិនទុកចិត្តគេបានជាខ្ញុំត្រូវស៊ើបសួរដោយខ្លួនឯង ហើយខ្ញុំមិនអើពើនឹងលិខិតដែលភូឈ្មួយខ្ញុំស៊ើបសួរនោះទេ ។
លោកព្រះរាជបំរើ ៖ ឥឡូវនេះលោកសេង-ទិប ឆ្លើយថាលោកធ្វើកុម្មិស្សែរលោកត្រូវទទួលខុសត្រូវលើខ្លួនលោក, លោកមិនទុកចិត្តអ្នកដែលសួរមុន បានជាលោកយកលិខិតដែលលោកស៊ើបសួរនោះទុកជាបានការ ឯលិខិតមុនលោកមិនរវល់អើពើ ។
លោកមេធាវី ហ្វៀរណង់ដៃស្ស សម-សុន ៖ តាមធម្មតាមកកិច្ចការនៅក្នុងកុ

ម្ចិស្ស៊ែរផ្ទែកទី២ ស្រេចលើលោកកុម្មិស្ស៊ែររងជាអ្នកធ្វើតែទាំងអស់, ឯលោកសេង ទិប ជាកុម្មិស្សែរចាំតែស៊ីញ៉េប៉ុណ្ណោះ, ចុះម្តងនេះ ម្តេចក៏ទៅជាថាមិនទុកចិត្តលោកកុម្មិស្ស៊ែររងទៅវិញ ? លិខិតនេះ មិនត្រឹមត្រូវ ឬមិនត្រូវចិត្ត ?

លោកព្រះរាជបំរើ ៖ ការនេះគេធ្វើតែពួកគ្នាគេ ហើយបាត់ក៏បាត់ក្នុងក្រសួងរបស់គេ មិនគួរចាប់ហេតុត្រង់ហ្នឹងទេ បើទៅដល់ក្រសួងដទៃហើយបាត់នោះសិមចាប់ហេតុ ។

លោកមេធាវី ហ្វ៊ែរណង់ដែស្ស សម-សុន (ងាកទៅសួរលោកសេង-ទិបថា រឿងធំសំបើមដល់ម្ល៉េះ ហេតុអ្វីក៏លោកកុម្មិស្ស៊ែរមិនសួរពេលថ្ងៃ ?

លោក សេង-ទិប ៖ បានជាមិនសួរពេលថ្ងៃ ព្រោះរវល់សួរសាក្សី ។

ចំពោះលោក តាន់-គិមតិក- នាយក្រុមព្រះនគរបាលជាតិ ។

លោកចាងហ្វាង ៖ រឿងចោលគ្រាប់បែក ដែលនាំឲ្យលោកអៀវ-កើសអតីតប្រធានរដ្ឋសភាអនិច្ចកម្មនោះ យ៉ាងដូចម្តេចខ្លះ សូមលោកនិយាយរៀបរាប់ទៅមើល ?

លោក តាន់គិមតិក ៖ ក្នុងយប់ចោលគ្រាប់បែកនោះ មុនដំបូងខ្ញុំរវល់នាំភ្នាក់ងារទៅព័ទ្ធផ្ទះលោក ង៉ែត-ហៀន ដល់ម៉ោង៩ជិតភ្លឺ ដោយម៉ែចិត្តទៅលើលោកនេះ ក្រែងមានទាក់ទងអ្វីក្នុងរឿងឃាតកម្មនោះ ព្រោះគ្រាន់តែលោកចូលទៅនិយាយការនិងលោកអតីតប្រធានបន្តិច ស្រាប់តែមានគេចោលគ្រាប់បែកតែម្តង ប៉ុន្តែដល់រើផ្ទះមើលទៅ គ្មានឃើញវត្ថុតាងអ្វីជាសំខាន់ទេ មានតែសំបុត្រមួយច្បាប់ដែលនិយាយពីការអង្គាសប្រាក់ធ្វើសាលារៀន ។

លោកចាងហ្វាង ៖ (លោកង៉ែត-ហៀន បានឆ្លើយនៅក្រុមព្រះនគរបាលជាតិថា កាលរដ្ឋសភាទើបនឹងបោះឆ្នោតលើកទី២ហើយ មានមនុស្សម្នាក់ឈ្មោះ ព្រំ-ណៃ ធ្លាប់ធ្វើឥស្សរៈ បានចូលទៅក្នុងរដ្ឋសភា និយាយពាក្យមិនគប្បី) រឿងនេះលោកដឹងទេ ?

លោក តាន់-គិមតិក ៖ កាលនោះលោកង៉ែត-ហៀន បានឆ្លើយដូច្នេះមែន ។ ឈ្មោះព្រំ-ណៃ កាលពីដើមធ្វើឥស្សរៈ តែសុំចុះចូលមកហើយនៅក្នុងដំណាក់ព្រះអង្គម្ចាស់សុទ្ធារង្ស-នរិន្ទតេជ ឥឡូវនេះឮថាទៅនៅឯកំពង់ឆ្នាំង ។

លោកចាងហ្វាង ៖ កាលពីល្ងាចថ្ងៃទី១៥ មករា ១៩៥០ លោកបានទៅសួរចំឡើយនូ-យ៉ា នៅកុម្មិស្ស៊ែរទីពីរទេ ?

លោក តាន់-គិមតិក ៖ ខ្ញុំបានទៅសួរមែន ។ តែខ្ញុំមិនមែនមានបំណងទៅសួរចម្លើយទេ ។ បានជាខ្ញុំទៅក្នុងពេលនោះ ដោយលោកកុម្មុយស្ស៊ែរទី២មិនឃើញបញ្ជូនមនុស្សនោះមកឲ្យខ្ញុំ ព្រោះកាលដែលទើបនឹងចាប់បានហើយ ខ្ញុំបានប្រាប់ថា

ឲ្យបញ្ជូនទៅឲ្យខ្ញុំជាប្រញាប់ កុំទុកឲ្យយឺតយូរ ស្រាប់តែបាត់មួយយប់មួយថ្ងៃមិនឃើញបញ្ជូនទៅ បានជាខ្ញុំទៅជាមួយលោកកុម្មិស្ស៊ែរធំ ។ ដល់ទៅចាំយូរពេកខ្ញុំក៏ចូលទៅ ។ ឯលោកកុម្មិស្ស៊ែរធំនៅចាំខាងក្រៅ ។

លោកចាងហ្វាង ៖ នៅពេលដែលលោកកុម្មិស្សែរទី២សួរ នោះមានវាយទេ ?

លោក តាន់-គិមតិក ៖ ឥតមានវាយទេ ។

លោកចាងហ្វាង ៖ លោកបានសួរវាទេ ? ។

លោក តាន់-គិមតិក ៖ លុះដល់ថ្ងៃរសៀលស្អែកឡើង គេបញ្ជូនមកឲ្យខ្ញុំ ទើបខ្ញុំសួរ ហើយបញ្ជូនទៅឲ្យលោកសុភាចារបុរស ។ នៅពេលដែលខ្ញុំសួរនោះ កុំថាឡើយដល់ទៅវាយដំ សូម្បីតែនិយាយពាក្យធ្ងន់ក៏គ្មានផង ថែមទាំងដកបារីក្រអូបពីកំប៉ុងឲ្យ ហើយគូសឈើគូសឲ្យជក់ទៀត ។

លោកចាងហ្វាង ៖ វាឆ្លើយដាក់ទៅឈ្មោះណាខ្លះ ?

លោក តាន់-គិមតិក ៖ ខ្ញុំបាទចាំមិនច្បាស់ទេ ដូចជាឈ្មោះ សៀង និង សួន, ត្រង់នេះខ្ញុំចាំមិនច្បាស់ដែរ ។

លោកចាងហ្វាង ៖ (នូ-យ៉ា ថាលោកវាយវា បានជាវាឆ្លើយដូច្នេះ ។ ឯយុន-លុត ក៏ដូច្នោះដែរ សួរនៅមុខសុភាចារបុរសកាលពីថ្ងៃទី២៩ មករា ១៩៥០ បានឆ្លើយប្រកែក លុះបញ្ជូនត្រឡប់ទៅខាងក្រុមព្រះនគរបាលជាតិវិញ ឃើញមានឆ្លើយទទួលថាខ្លួនបានប្រព្រឹត្តមែន) ។ រឿងនេះយ៉ាងម៉េច លោកវាយវាមែនទេដឹង ? ។

លោក តាន់-គិមតិក ៖ ខ្ញុំបាទមិនបានវាយទេ ។ នូ-យ៉ានេះ នៅថ្ងៃដែលខ្ញុំបាទសួរមុនដំបូង ប្រាប់ថាអស់កម្លាំងណាស់ ឆ្លើយមិនកើតទេ ខ្ញុំបាទក៏ទិញមីឆាឲ្យទទួលទាន ហើយឲ្យបារីក្រអូបជក់ថែមទៀត ។ ធ្វើឲ្យស្និទ្ធស្នាលដូច្នេះ ទាល់តែលើកក្រោយគ្រាន់តែឃើញខ្ញុំបាទ ក៏នូ-យ៉ាសុំបារីជក់តែម្តង ។ នៅពេលសួរចម្លើយទៀត ខ្ញុំបាទបានសំដែងកិរិយាយ៉ាងស្និទ្ធ មានជូនកាលឲ្យអ្នកដទៃនាំនិយាយ ហើយខ្ញុំបាទលបចាំស្តាប់មិនឲ្យនូ-យ៉ាដឹងខ្លួនមានគេយាមខ្លួនផង ដោយឲ្យអ្នកយាម-ចាត់ការប្រយ័ត្នប្រយែង ។

ឯយុន-លុត ក៏ខ្ញុំបាទគ្មានបានវាយដំដែរ ។ ខ្ញុំសួរដេញដោលកៀងចុះឡើងៗ ស្រាប់តែឆ្លើយខ្លួនឯងមក ហើយបានទាំងលាន់មាត់ថា យីចំពូកែមែន ! សួរនេះទ្រាំឆ្លើយប្រាប់មិនបាន ។

លោកចាងហ្វាង ៖ កាលនោះ មានមេធាវីទៅសុំជួបកូនក្តី និងសុំស្តាប់នៅពេលសួរចម្លើយ លោកមិនព្រមឲ្យមែនទេ ? ។

លោកតាន់-គិមតិក ៖ កាលនោះ មានលោកមេធាវីទៅសុំសួរមែន តែខ្ញុំថាមិនចាំបាច់មកទេ ចាំសួររួចខ្ញុំជូនទៅតុលាការ ហើយចាំទៅជួបនៅតុលាការឯណោះចុះ

តែពេលនោះ ចេះតែទទូចសុំពេក ខ្ញុំក៏អនុញ្ញាតឲ្យចូលទៅជួប ឲ្យចូលទៅស្តាប់សួរចម្លើយ ។ សួរហើយ បានយកមកឲ្យមើល ។

លោកចាងហ្វាង ៖ (បានហៅឈ្មោះ នូ-យ៉ា ហើយថា) ចម្លើយលោកក្រុមនគរបាលថា ឥតមានវាយអ្នកឯងទេ ថាសួរដោយស្រួល ថាបានឲ្យបារីជក់និងទិញមីឆាឲ្យស៊ីទៀតផង ម៉េចក៏អ្នកឯងឆ្លើយថាលោកវាយ ?

នូ-យ៉ា ៖ ពេលនោះលោកមិនវាយមែន តែនៅឯកុម្មិស្ស៊ែរទី២ លោកនេះបានវាយហើយទាត់ខ្ញុំបាទ៤ជើង ?

លោកចាងហ្វាង ៖ (បានសួរចៅ-ស៊ីនថា) លោកនាយក្រុមនគរបាល មានវាយអ្នកឯងទេ ?

ចៅ-ស៊ីន ៖ មានទាត់ខ្ញុំបាទ២ជើង ហើយលោកទៅពិសារបាយបាត់ទៅ នៅតែលោកអ៊ុក-ស៊ីននិងភ្នាក់ងារលោកវាយខ្ញុំបាទ ? ។

លោកចាងហ្វាង ៖ (សួរលោកឃួន-លុតទៀត តើស្គាល់មុខអ្នកវាយទេ) ។

ឃួន-លុត ៖ ពេលវាយនោះ ខ្ញុំបាទមិនស្គាល់មុខទេ ព្រោះនៅពេលវាយនោះគេព្រលត់ភ្លើង ហើយមានមនុស្ស៣នាក់ចូលទៅវាយទាត់ផាក់កាច់ដៃកាច់ជើងខ្ញុំបាទ ។ មនុស្សទាំង៣នោះ ខ្ញុំបាទមិនស្គាល់មុខទេ ។ លុះវាយរួចហើយ គេចេញបាត់ទៅ ទើបគេឲ្យនាំខ្ញុំទៅសួរចម្លើយទៀត ។

លោកចាងហ្វាង ៖ (បានហៅមនុស្សជាប់ចោទឈ្មោះ ឡាំ-សុត មកសួរ ហើយមានប្រសាសន៍ថា ៖ មនុស្សនេះបែបមិនស្រួល ពិបាកសួរណាស់ រកសួរមិនកើត ។ ហើយក៏សួរទៅលោកនាយក្រុមនគរបាលជាតិថា) មនុស្សនេះមិនស្រួលតាំងពីដើមមកឬ ? ។

លោកតាន់-គិមតិក ៖ បាទ, មនុស្សនេះបែបមិនស្រួលដូច្នេះតាំងពីដើមមកតែខ្ញុំលួងសួរបានការខ្លះដែរ ។ ការដែលខ្ញុំចាប់មនុស្សនេះមក ដោយពួកភ្នាក់ងារខ្ញុំឲ្យការមកពីខាងកំបូលថា ឈ្មោះនេះដើរប្រាប់រៃអង្ករឲ្យមេឃុំឃួន-លុត ដើម្បីយកមកចិញ្ចឹមឥស្សរៈនៅភ្នំពេញ ។ ពួកវាដែលនៅកំបូលនោះ មានគ្នាចំណានណាស់ មិនងាយនឹងចាប់បានទេ ឲ្យតែលេចមនុស្សប្លែកទៅ វារត់គេចបាត់មួយរំពេចមិនងាយនឹងរកចាប់បានទេ ដែលពួកភ្នាក់ងារទៅចាប់បានមកនេះ ដោយក្លែងខ្លួនជាអ្នកស្រុកដូចគ្នា ទើបចាប់បាន ។

លោកចាងហ្វាង ៖ (បានហៅមនុស្សជាប់ចោទឈ្មោះ ហាន-ច្រិច មកសួរថា) លោកនាយក្រុមព្រះនគរបាល ឆ្លើយថាឥតបានវាយអ្នកឯងទេ មែនឬអី ?

ហ៊ាន-ច្រិច ៖ បាទ, មិនវាយមែន តែពួកភ្នាក់ងារលោក៣នាក់បានវាយខ្ញុំបាទ !

លោកចាងហ្វាង ៖ (សួរទៅតាន់-គិមតិក) ឈ្មោះហ៊ាន-ច្រិចនេះលោកចាប់ពី

ណាមក ? ។

លោក តាន់-គិមតិក ៖ ឈ្មោះនេះរកស៊ីរត់ស៊ីក្លូ បានជាខ្ញុំចាប់ ព្រោះឃើញចម្លើយពីនូ-យ៉ាមក ។

លោកមេធាវី ហ្វ៊ែរណង់ដែស្ស សម-សុន (សុំសួរទៅលោកតាន់-គិមតិក) ៖ នៅយប់ថ្ងៃទី១៤ មករានោះ លោកមានឃើញលោកកុម្មិស្ស៊ែរសង្កាត់ទីមួយ សួរចម្លើយដែរឬទេ ? ។

លោកតាន់-គិមតិក ៖ ខ្ញុំមិនបានដឹងជាលោកសួរឬមិនសួរទេ ព្រោះវេលាយប់នោះ ខ្ញុំគ្រាន់តែទៅសួរលោកសេង-ទិប ដឹងថាមនុស្សនោះ គេចាប់បានហើយប៉ុណ្ណោះ ខ្ញុំក៏ទៅជំរាបឯ.ឧ. នាយករដ្ឋមន្ត្រីយ៉ែម-សំបូរ ឯផ្ទះលោក ។

លោកមេធាវី ហ្វ៊ែរណង់ដែស្ស សម-សុន (សុំឲ្យសួរ) ចុះបើលោកគ្មានដឹងហេតុអ្វីទេ ម៉េចក៏មានលិខិតលោកលេខ១៧០ ចុះថ្ងៃទី១៤ មករា ១៩៥០ថា មនុស្សនោះគេចាប់បានហើយ តែមិនស្គាល់ឈ្មោះ ។ មួយទៀតលោកធ្វើនាយក្រុមនគរបាល គួរតែខិតខំស្រាវស្រទិញ ? យកចិត្តទុកដាក់ក្នុងរឿងនេះឲ្យណាស់, នេះដឹងជាចាប់បានហើយ បែរជាទៅណាទៅវិញ ។

លោកចាងហ្វាង ៖ (បានយកសំបុត្រជាភាសាបារាំងនោះ មកអានប្រែជាភាសាខ្មែរ មានសេចក្ដីថា) «នៅថ្ងៃទី១៤-១-៥០ មានមនុស្សមិនស្គាល់ឈ្មោះ បានចោលគ្រាប់បែកនៅទីចាត់ការកណាបក្សប្រជាធិបតេយ្យ វិថីពិកេ... មនុស្សនោះគេចាប់បានហើយ មានឈ្មោះថា នូ-យ៉ា» ។

លុះអានហើយ លោកចាងហ្វាងមានប្រសាសន៍បញ្ជាក់ថា មានឈ្មោះគេដែរនៅខាងក្រោមនេះ តែពីខាងលើគេមិនចេញឈ្មោះ ។

លោកមេធាវី ហ្វ៊ែរណង់ដែស្ស សម-សុន ៖ ហេតុអ្វីបានជាលោកតាន់-គិមតិកត្រូវទៅសួរចម្លើយនៅកុម្មិស្ស៊ែរទី៧វិញ លោកច្រឡំកន្លែងឬអ្វី ? ។

លោកចាងហ្វាង ៖ ត្រូវគេទៅបាន ព្រោះក្រុមព្រះនគរបាលមានអំណាចធំជាងកុម្មិស្ស៊ែរ ។

លោកមេធាវី យស-ឌុច ៖ សុំសួរលោកតាន់-គិមតិក ថារឿងឈ្មោះហ៊ាន-ច្រិចនេះ លោកបានដំណឹងពីណាមក ? លោកបង្គាប់ឲ្យចាប់ឬអ្វី ?

លោកតាន់-គិមតិក ៖ រឿងនេះពួកភ្នាក់ងាររបស់ខ្ញុំបានឲ្យការមកខ្ញុំ ហើយខ្ញុំបង្គាប់ឲ្យចាប់មក ។

លោកមេធាវី គង់-មង់ ៖ (សុំសួរលោកតាន់-គិមតិកថា) អំពីរឿងសំបុត្រដែលខ្ញុំសុំយកបេទ្យទៅមើលកូនក្ដីខ្ញុំ ម្ដេចក៏លោកមិនព្រមឲ្យ លោកថាមិនឈឺ ខ្ញុំពិនិត្យមើលទៅថាដូចជាឈឺ បើដូច្នេះលោកមិនធ្វើគ្រូពេទ្យផងទៅហើយ ? ។

លោកព្រះរាជបំរើ ៖ រឿងនេះខ្ញុំបានសួរចៅ-ស៊ុន, យូន-លុត ព្រឹកមិញ ហើយពុំឃើញបានរៀបរាប់រឿងនេះសោះ, ខ្ញុំបានសួរទៅ ថាឥតមាននិយាយការប្រាប់មេធាវីទេ, ថាគ្មានទាំងមេធាវីផង ។

មួយទៀតខ្ញុំឆ្ងល់ណាស់ ម៉េចក៏លោកមិនធ្វើសំបុត្រមកតាមរយៈលោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឲ្យធ្វើទៅឲ្យ ?

លោក គង់-មង់ ៖ ខ្ញុំធ្វើតាមនេះហើយ តែមិនព្រមឲ្យធ្វើម៉េច ?

លោកចាងហ្វាង ៖ ម៉េចក៏លោកមិនសុំលោកសុភាចារបុរស ? ។

លោកព្រះរាជបំរើ ៖ ពេលសួរនៅមុខសុភាចារបុរស មិនឮឆ្លើយថាគេវាយសោះ ស្រាប់តែនៅពេលនេះលេចពាក្យថា គេវាយគ្រប់ៗគ្នា ។

លោកមេធាវី ហ្វៃរណាង់ដៃស្សូ សម-សុន ៖ យកកូនក្តីខ្ញុំទៅដាក់ក្នុងគុកងងឹត ដូចជាខ្លានៅក្នុងទ្រុង តើនឹងទ្រាំមិនបានឆ្លើយតាមគេឯណាបាន ។

លោកព្រះរាជបំរើ ៖ កាលពីមុនឈ្មោះទាំងនេះឆ្លើយថា បានធ្វើមនុស្សឃាតក្នុងរឿងនេះមែន, ដល់ក្រោយមកស្រាប់តែធ្វើពាក្យទៅលោកក្រុមចោទដោះសាថាចម្លើយមុននេះសុំបដិសេធចោល ព្រោះឆ្លើយដោយគេបង្ខំ ហើយចេះតែឆ្លើយទៅៗ ។

លោកមេធាវី ហ្វៃរណាង់ដៃស្សូ សម-សុន ៖ ខ្ញុំសូមឲ្យអស់លោកនិងប្រជាជនជួយមើល ឃួន-លុតនេះឈឺឬមិនឈឺ ? នេះគឺឈឺជាប់តាំងពីពេលនោះមក ។

លោក តាន់-គិមតិក ៖ បើមិនជឿខ្ញុំ សូមសួរស្មៀនជាអ្នកកត់ហេតុរបស់ខ្ញុំចុះ តើខ្ញុំវាយឬទេ ?

ចំពោះលោក សេង-ឈន ភ្នាក់ងារក្រុមព្រះនគរបាលជាតិ (ដែលជាអ្នកកត់ហេតុ) ។

លោកចាងហ្វាង ៖ កាលនាយក្រុមព្រះនគរបាលជាតិសួរចម្លើយនោះ លោកមានឃើញវាយដំអ្វីទេ ? ។

លោក សេង-ឈន ៖ គ្មានឃើញវាយដំអ្វីទេ ។

លោកចាងហ្វាង ៖ (ក៏ហៅស្មៀនសំ-សារិន ដែលជាអ្នកសរសេរសេចក្តីកត់ហេតុ របស់លោកនាយក្រុមព្រះនគរបាលជាតិមកសួរទៀត ហើយស្មៀននោះក៏ឆ្លើយដូចលោកសេង-ឈនដែរ ហើយលោកចាងហ្វាងក៏សួរទៀតថា) ៖ លោកបានធ្វើសេចក្តីកត់ហេតុ តាមមនុស្សទាំងនោះឆ្លើយ ឬក៏មានគេធ្វើសេចក្តីកត់ហេតុពីណាស្រេចហើយ យកមកឲ្យលោកស៊ីញ៉េតែម្តង ?

លោក សំ-សារិន ៖ ខ្ញុំបាទធ្វើកំណត់ហេតុនោះតាមចម្លើយ មិនមែនចាំតែស៊ីញ៉េលើរបស់ដែលគេធ្វើស្រេចហើយនោះទេ ។

ចំពោះឈ្មោះ គិម-ហ៊ុន ជាអ្នកយាមកន្លែងឃុំឃាំង ។

លោកចាងហ្វាង ៖ កាលដែលអ្នកឯងនៅយាមនោះ មានដែលឃើញគេទៅពន្លត់ភ្លើង ហើយចូលទៅវាយមនុស្សទោសទាំងនោះទេ ?

គិម-ហ៊ុន ៖ មិនដែលឃើញទេ ធ្លាប់ឃើញពួកភ្នាក់ងារក្រុមព្រះនគរបាលជាតិមកសុំនាំយកអ្នកត្រូវចោទទៅសួរចម្លើយនៅខាងលើដែរ ។

លោកចាងហ្វាង ៖ កាលដែលពួកប៉ូលិសនាំយកទៅខាងលើនោះ អ្នកឯងមានឮសូរគេវាយទេ ?

គិម-ហ៊ុន ៖ ឥតមានឮសូរគេវាយទេ ។

ចំពោះឈ្មោះ ឆាយ-អ៊ុក (ជាអ្នកយាម) ។

លោកចាងហ្វាង ៖ នៅពេលដែលអ្នកឯងយាមនោះ ធ្លាប់បានឃើញគេចូលទៅវាយសួរចម្លើយនៅកន្លែងគុកនោះទេ ? ។

ឆាយ-អ៊ុក ៖ ឥតតែមានអ្នកណាចូលទៅវាយសួរចម្លើយក្នុងទីនោះទេ មានតែគេឲ្យនាំចេញ ហើយយកទៅសួរខាងលើប្រហែលជាម៉ោង៨យប់នោះដែលមាន ។

លោកចាងហ្វាង ៖ ដែលមកនាំទៅនោះមានគ្នាប៉ុន្មាននាក់ ? ។

ឆាយ-អ៊ុក ៖ ចួនកាល២នាក់ ចួនកាល៣នាក់ ។

លោកចាងហ្វាង ៖ នៅពេលដែលគេយកទៅសួរនៅខាងលើនោះ តើអ្នកឯងដែលឮសូរគេវាយទេ ?

ឆាយ-អ៊ុក ៖ ឥតដែលឮសូរគេវាយទេ ។

ចំពោះឈ្មោះ សៅ-ណាល់ (ជាអ្នកយាម) ។

លោកចាងហ្វាង ៖ លោកនាយក្រុមនគរបាល មានដែលឲ្យបញ្ចេញមនុស្សទោសយកទៅសួរចម្លើយដែរឬទេ ? ។

សៅ-ណាល់ ៖ មានដែលឲ្យបញ្ចេញទៅសួរនៅពេលយប់ក៏មាន, ពេលថ្ងៃក៏មាន ។

លោកចាងហ្វាង ៖ នៅពេលដែលគេយកទៅសួរនោះ លោកមានឮសូរគេវាយទេ ? ។

សៅ-ណាល់ ៖ ឥតដែលឮសូរទេ ។

ចំពោះឈ្មោះ ងួន-លី (អ្នកនៅជិតខាងឈ្មោះនួ-យ៉ា)

លោកចាងហ្វាង ៖ អ្នកឯងស្គាល់ឈ្មោះនួ-យ៉ាទេ ? ។

ងួន-លី ៖ ខ្ញុំបាទស្គាល់ ព្រោះជួលផ្ទះនៅជិតគ្នា ។

លោកចាងហ្វាង ៖ អ្នកឯងរកស៊ីអ្វី ? ។

ងួន-លី ៖ ខ្ញុំជាអ្នកស៊ីឈ្នួលសែងលីឲ្យគេនៅផ្សារថ្មី ។

លោកចាងហ្វាង ៖ ឈ្មោះ នូ-យ៉ា រកស៊ីអ្វី ? ។

ងួន-លី ៖ ឈ្មោះនេះរកស៊ីផាក់ស៊ីក្លូ ។

លោកចាងហ្វាង ៖ អ្នកឯងមានដែលឃើញមនុស្សណាទៅផ្ទះឈ្មោះនូ-យ៉ា នោះដែរឬទេ ?

ងួន-លី ៖ ខ្ញុំបាទមិនដឹងដែរ ព្រោះតែម៉ោង៥ជិតភ្លឺ ខ្ញុំបាទទៅផ្សារថ្មីបាត់ទៅហើយ ។

លោកចាងហ្វាង ៖ អ្នកឯងស្គាល់ឈ្មោះសួនទេ ? រាងរៅយ៉ាងម៉េច ? ។

ងួន-លី ៖ ខ្ញុំបាទស្គាល់ ជួលផ្ទះនៅជិតខ្ញុំបាទដែរ ។ ឈ្មោះសួននេះ រាងក្រអាញសំបុរខ្មៅ ។

លោកចាងហ្វាង ៖ (ងាកទៅសួរលោកង៉ែត-ហ៊ានថា) នៅពេលដែលលោកបើកឡានទៅនោះ លោកឃើញមនុស្សម្នាក់ទៀតនោះរាងរៅយ៉ាងម៉េច ? ។

លោកង៉ែត-ហ៊ាន ៖ មនុស្សនោះរាងក្រអាញ, រាងឆ្អឹង, សំបុរខ្មៅ ឯមុខមាត់មិនច្បាស់ទេ ។

លោកចាងហ្វាង ៖ (ងាកទៅសួរងួន-លីវិញថា) អ្នកឯងដែលឃើញយ៉ាងនិងសៀងដើរជាមួយគ្នាទេ ? ។

ងួន-លី ៖ ដែលឃើញដើរជាមួយគ្នា នៅផ្សារក៏មាន នៅទីដទៃក្រៅពីផ្សារក៏មាន ។

លោកចាងហ្វាង ៖ អ្នកឯងដឹងទេ កាលដែលគេចោលគ្រាប់បែកនោះ ? ។

ងួន-លី ៖ ខ្ញុំបាទដឹងដែរ តែព្រឹកឡើងបានខ្ញុំបាទដឹង ។

លោកចាងហ្វាង ៖ អ្នកឯងឃើញមនុស្ស៣នាក់នោះរត់ស៊ីក្លូទាំងអស់គ្នាឬ ? ។

ងួន-លី ៖ ប្របាទ, ឃើញរត់ស៊ីក្លូទាំងអស់គ្នា ។

លោកចាងហ្វាង ៖ កាលដែលចោលគ្រាប់បែកហើយ អ្នកឯងបានឃើញឈ្មោះនូ-យ៉ា, ប៉ុល-សៀង, ទេព-សួន នៅផ្ទះទេ ? ។

ងួន-លី ៖ បាត់ឈ្មោះនូ-យ៉ា មិនឃើញនៅផ្ទះទេ ឯឈ្មោះសៀងក៏បាត់តាំងពីយប់ដែរ ចំណែកទេព-សួន នៅបានមួយយប់ព្រឹកឡើងទើបបាត់ ។

លោកចាងហ្វាង ៖ មុនថ្ងៃចោលគ្រាប់បែក អ្នកឯងដែលឃើញទេព-សួន និងប៉ុល-សៀងទៅប្រជុំគ្នានឹងឈ្មោះនូ-យ៉ាទេ ? ។

ងួន-លី ៖ មុនចោលគ្រាប់បែក៣ថ្ងៃ មានឃើញឈ្មោះទាំង២នេះ ទៅលេងសើចនៅផ្ទះឈ្មោះនូ-យ៉ា មានច្រៀងរាំផង ខ្ញុំបាទមិនបានទៅស្តាប់ទេ ព្រោះទទួលទានដំណេកទៅ ។

ចំពោះឈ្មោះ សំ-សាត ។

លោកចាងហ្វាង ៖ អ្នកឯងរកស៊ីធ្វើអ្វី ? ។
សំ-សាត ៖ ខ្ញុំបាទរកស៊ីរត់ស៊ីក្លូ ។
លោកចាងហ្វាង ៖ ផ្ទះអ្នកឯងនៅឯណា ? ។
សំ-សាត ៖ ផ្ទះខ្ញុំបាទនៅវាលវង់ ។
លោកចាងហ្វាង ៖ អ្នកឯងស្គាល់ឈ្មោះយ៉ា និងឈ្មោះសៀងទេ ? ។
សំ-សាត ៖ ខ្ញុំបាទស្គាល់ ជួលផ្ទះនៅជាមួយគ្នា ។
លោកចាងហ្វាង ៖ កាលគេចោលគ្រាប់បែកអ្នកឯងបានដឹងទេ ? ។
សំ-សាត ៖ ខ្ញុំបាទបានដឹងក្នុងយប់នោះ ។
លោកចាងហ្វាង ៖ អ្នកឯងឃើញឈ្មោះសៀង និងស្ងួនទេយប់នោះ ? ។
សំ-សាត ៖ ខ្ញុំបាទមិនដឹងដែរ ព្រោះខ្ញុំបាទរត់ស៊ីក្លូ ដល់ព្រឹកឡើងទៅផ្ទះឃើញឈ្មោះស្ងួននៅ ហើយដល់ថ្ងៃត្រង់ស្រាប់តែបាត់រហូតដល់ឥឡូវនេះ ។
លោកចាងហ្វាង ៖ អ្នកឯងដែលឃើញមានអ្នកណាទៅរកឈ្មោះសៀង និងឈ្មោះយ៉ាទេ ? ។
សំ-សាត ៖ ដែលឃើញមានមនុស្សម្នាក់ទៅរក នៅពេលមុនចោលគ្រាប់បែក៣ថ្ងៃ ។
លោកចាងហ្វាង ៖ អ្នកឯងស្គាល់ទេ មនុស្សដែលចំណាំទៅរកឈ្មោះសៀងនិងឈ្មោះយ៉ានោះ ? ។
សំ-សាត ៖ គ្រាន់តែប្រហែលៗ ខ្ញុំបាទស្គាល់មិនច្បាស់លាស់ទេ ។
លោកចាងហ្វាង ៖ (បានចង្អុលទៅអ្នកជាប់ចោទនោះ ហើយសួរសំ-សាតថា អ្នកមើលនៅក្នុងចំណោមអ្នកត្រូវចោទទាំងនេះ) តើមានឃើញមុខអ្នកដែលចំណាំតែទៅរកឈ្មោះយ៉ានិងឈ្មោះសៀងទេ ? ។
សំ-សាត ៖ ចង្អុលទៅឈ្មោះចៅ-ស៊ុនហើយថា គ្រាន់តែប្រហែលៗ មិនស្គាល់ទេ ។
លោកចាងហ្វាង ៖ កាលអ្នកឯងឆ្លើយនៅឯក្រុមព្រះនគរបាលជាតិ ថាប្រាកដជាឈ្មោះនេះហើយ ដល់ឥឡូវម៉េចក៏ឆ្លើយថាប្រហែលៗទៅវិញ ? ។
សំ-សាត ៖ យូរហើយ, ភ្លេចភ្លាំងទៅហើយ ។
លោកចាងហ្វាង ៖ អ្នកឯងឆ្លើយឲ្យច្បាស់ ព្រោះសុទ្ធតែបានសច្ចាប្រណិធានរួចហើយ ប្រយ័ត្នចាញ់សម្បថ ។
សំ-សាត ៖ ក៏ចង្អុលទៅរូបចៅ-ស៊ុន ថាទានប្រោសនេះហើយ ។
លោកចាងហ្វាង ៖ (ងាកទៅសួរចៅ-ស៊ុនថា) ចៅ-ស៊ុន អ្នកឯងឮឈ្មោះសំ-សាតឆ្លើយទេ ថាកាលមុនចោលគ្រាប់បែក អ្នកឯងទៅផ្ទះយ៉ានិងសៀង ។

ចៅ-ស៊ិន ៖ ឈ្មោះនេះខ្ញុំបាទឥតដែលស្គាល់ទេ ខ្ញុំបាទឥតដែលទៅទេ កាលខ្ញុំបាទនៅឯក្រុមព្រះនគរបាលជាតិ គេចាប់ឈ្មោះនេះមក ហើយបង្គាប់ឲ្យឆ្លើយដាក់ខ្ញុំបាទ ។

លោកចាងហ្វាង ៖ (ក៏មានប្រសាសន៍ទៅរកសំ-សាត) ថា ចៅ-ស៊ិននិយាយថាឥតដែលស្គាល់អ្នកឯងទេ ។

សំ-សាត ៖ ទានប្រោសប្រហែលហ្នឹងហើយ ។

លោកចាងហ្វាង ៖ ពីមុនអ្នកឯងថាប្រាកដជាហ្នឹងហើយ ឥឡូវប្រហែលវិញ តើពាក្យទាំងពីរនេះអ្នកឯងប្រកាន់យកមួយណា ? ។

សំ-សាត ៖ ទានប្រោស យក«ប្រហែល» ។

លោកមេធាវី ហ៊្សែរណាង់ដែស្ស សម-សុន ៖ ទៅចាប់មនុស្សនេះមកឃុំឃាត់បានជាឆ្លើយយ៉ាងនេះ ហើយឈ្មោះនេះត្រូវឃុំឃាត់ក៏ដោយសារគេឆ្លើយដាក់ដែរ!

លោកចាងហ្វាង ៖ គេចាប់អ្នកឯងមក គ្រាន់តែស៊ើបសួរ ហើយឲ្យទៅវិញ ឬឃុំទុកដែរ ? ។

សំ-សាត ៖ គេចាប់ខ្ញុំបាទយកមកឃុំអស់២៥ថ្ងៃ ។

លោកចាងហ្វាង ៖ (ហៅលោកតាន់-គិមតិក នាយក្រុមព្រះនគរបាលជាតិមកហើយសួរថា) លោកចាប់ឈ្មោះសំ-សាតនេះមក ដោយមានគេឆ្លើយដាក់ឬអ្វី

លោក តាន់-គិមតិក ៖ ខ្ញុំមានសេចក្ដីសង្ស័យឲ្យទៅចាប់យកមកស៊ើបសួរ លុះស៊ើបសួរទៅរកហេតុផលមិនឃើញ ទើបលែងឲ្យត្រឡប់ទៅវិញ ។

លោកមេធាវី ហ៊្សែរណាង់ដែស្ស សម-សុន ៖ ខ្ញុំឆ្ងល់ណាស់ មនុស្សខ្លះ ម៉េចក៏មានកុសលម្ល៉េះ គេចាប់យកមកឃុំតែ២៥ថ្ងៃក៏លែងទៅវិញ ? អកុសលអ្វី តែកូនក្ដីរបស់ខ្ញុំឈ្មោះឃួន-លុត និងឈ្មោះចៅ-ស៊ិន ។

ចំពោះឈ្មោះ ឃិម-សែម ។

លោកចាងហ្វាង ៖ ផ្ទះអ្នកឯងនៅឯណា ? រកស៊ីធ្វើការអ្វី ? ។

ឃិម-សែម ៖ ខ្ញុំបាទនៅវាលវង់ រកស៊ីរត់ស៊ីក្លូ ។

លោកចាងហ្វាង ៖ អ្នកឯងស្គាល់ឈ្មោះយ៉ា, សួន និងឈ្មោះសៀងច្បាស់ទេ

ឃិម-សែម ៖ ខ្ញុំបាទស្គាល់ច្បាស់ដែរ ។

លោកចាងហ្វាង ៖ អ្នកឯងឃើញឈ្មោះទាំង៣នាក់នេះ មកនៅវាលវង់យូរហើយឬ ? ប្រហែលប៉ុន្មានឆ្នាំហើយ ?

ឃិម-សែម ៖ ខ្ញុំបាទមិនដឹងដែរ ព្រោះខ្ញុំបាទមកនៅក្រោយគេ ។

លោកចាងហ្វាង ៖ មានដែលឃើញគេទៅរកឈ្មោះសួននិងសៀងទេ ?

ឃិម-សែម ៖ ខ្ញុំបាទមានដែលឃើញគេទៅរក តែខ្ញុំបាទសួរគេទៅជាមួយ គេ

ថាចៅកែស៊ីក្ល ។ អ្នកដែលទៅរកនោះ មានជីករទេះកង់មួយពណ៌ក្រហម ។ មុនដំបូងសួររកឈ្មោះយ៉ា ហើយក៏ទៅនិយាយការអ្វីនឹងសួន ហើយនិងសៀង តែខ្ញុំបាទស្តាប់មិនច្បាស់ទេ ព្រោះខ្ញុំបាទគ្រាន់តែឃើញមួយភ្លែត ក៏ទទួលទានដំណេកវិញទៅ ព្រោះពេលនោះខ្ញុំបាទកំពុងឈឺ ។ ដែលខ្ញុំបាទឃើញតែម្តងទេ នៅពេលមុនចោលគ្រាប់បែកប្រហែល២-៣ថ្ងៃ ។

លោកចាងហ្វាង ៖ អ្នកឯងស្គាល់ទេ មនុស្សត្រូវចោទទាំង៥នាក់នេះ ?

យិម-សែម ៖ មិនស្គាល់ទេ, ស្គាល់តែឈ្មោះយ៉ាមួយប៉ុណ្ណោះ ។

( ឯកសារដើមបាត់ពីរទំព័រ គឺទំព័រ៩២ និងទំព័រ៩៣ )

លោកចាងហ្វាង (ហៅលោកស៊ីចាន់មកសួរថា) លោកបានឮលោកផុននិយាយ នៅផ្ទះលោកទូច-យ៉ែមថា លោកសេង-ទិប និងលោកអ៊ុក-ស៊ុន គិតវាយឲ្យឆ្លើយគណៈសេរីភាពដែរឬទេ ?

លោក ចាន់-ស៊ី ៖ ខ្ញុំឮនិយាយមែន តែខ្ញុំមិនស្គាល់ឈ្មោះ មិនស្គាល់មុខគេទេ គ្រាន់តែឬសូរនិយាយ ។

លោក ផុន (ក៏ក្រោកទៅនិយាយទៀតថា) ឱ ! ខ្ញុំទើបនឹកឃើញ ។ មានមួយពេលនោះខ្ញុំទៅទទួលទានចំណីនៅភោជនីយដ្ឋានហិម៉ាលយ៉ា- ខ្ញុំមាននិយាយលេងពីស្រុកទេសនានា- និយាយហួរហែពីនេះពីនោះមកដល់រឿងចោលគ្រាប់បែកនេះ ។ ខ្ញុំនិយាយថា រឿងនេះពិបាកយល់ណាស់ ខ្លះថាអ្នកនេះ ខ្លះថាអ្នកនោះ មិនដឹងជាអ្នកណាទេ ។ មិនដឹងជាលោកស៊ី-ចាន់ នេះយ៉ាងម៉េចទេ បានជានិយាយយ៉ាងនេះ ។

លោកចាងហ្វាង ៖ មានអស់លោកណាត្រូវការសួរអ្វីទេ ?

លោកមេធាវីហ្វៀរណាង់ដែស្ស សម-សុន ៖ ទុកឲ្យគ្នាគេ២នាក់ឆ្លើយដាក់គ្នាចុះ

លោកចាងហ្វាង ៖ ដឹងជានរណាថានរណាទេ ម្នាក់ឆ្លើយដាក់ម្នាក់យ៉ាងនេះ ។

លោកមេធាវីហ្វៀរណាង់ដែស្ស សម-សុន ៖ ក្រែងគេខ្លាចធ្លាក់ងារស័ក្តិទេដឹងបានជាគេមិនឆ្លើយថា គេនិយាយមែន ?

ចំពោះលោក ហែម-សារី

លោកចាងហ្វាង ៖ លោកមានឮលោក ផុន និយាយនៅផ្ទះលោកទូច-យ៉ែមថាលោកសេង-ទិប និងលោក អ៊ុក-ស៊ុន គិតវាយឲ្យឆ្លើយដាក់ទៅលើគណៈសេរីភាពដែរឬទេ ?

លោក ហែម-សារី ៖ កាលនៅល្ងាចថ្ងៃ ១៨ សូយ៉េត វេលាម៉ោង៧ល្ងាច ខ្ញុំមានឮនិយាយមែន ។

លោក ផុន (ក្រោកមកនិយាយម្តងទៀតថា) ៖ មានទៅនិយាយលេងពីនេះពី

នោះនៅភោជនិយដ្ឋានហីម៉ាលយ៉ា ស៊ីផឹកជជែកគ្នានិយាយលេងពីស្រុកទេស ហើយនាំគ្នាញ៉ាំបបរទៅ ខ្ញុំឥតនិយាយថា លោកសេង-ទិប និងលោកអ៊ុក-ស៊ុន គិតវាយឲ្យឆ្លើយដាក់គណៈសេរីភាពទេ, ប្រហែលជាលោក ហែម-សារី នេះស្រវឹងម៉ាតែលទេដឹង ?

លោកចាងហ្វាង ៖ (បានហៅលោកអ៊ុក-ស៊ុន មកសួរទៀតថា) កាលនៅឯក្រុមព្រះនគរបាលជាតិ លោកបានសួរចម្លើយមនុស្សដែលជាប់ចោទទាំងអស់នោះ

លោក អ៊ុក-ស៊ុន ៖ ខ្ញុំមានសួរចម្លើយដែរ ។

លោកចាងហ្វាង ៖ លោកមានវាយទេពេលសួរនោះ ?

លោក អ៊ុក-ស៊ុន ៖ ខ្ញុំឥតមានវាយទេ សួរដោយស្រួលៗ ។

លោកចាងហ្វាង (ក៏សួរទៅអ្នកត្រូវចោទទាំងនេះថា) លោកនេះមានវាយទេ ?

ឃុន-លុត ៖ លោកនេះឥតមានវាយទេ សួរដោយស្រួល ។

ឡាំ-សុត ៖ ឥតមានវាយទេ ។

នូ-យ៉ា ៖ លោកនេះមានវាយដែរ ។

ចៅ-ស៊ុន ៖ លោកនេះបានវាយខ្ញុំបាទនឹងដំបងកៅស៊ូ ។

លោកចាងហ្វាង (សួរលោកអ៊ុក-ស៊ុនថា) ពេលដែលលោកសួរចម្លើយ ហើយមានសូត្រឲ្យចៅ-ស៊ុននិងឃុន-លុតស្តាប់ទេ ?

លោក អ៊ុក-ស៊ុន ៖ ខ្ញុំមានសូត្រឲ្យស្តាប់ ។

លោកចាងហ្វាង ៖ កាលនោះចៅ-ស៊ុន និងឃុន-លុតឆ្លើយដូចម្តេច ?

លោក អ៊ុក-ស៊ុន ៖ ឆ្លើយថាបានប្រព្រឹត្តមែន ។

ចៅ-ស៊ុន ៖ បានជាខ្ញុំបាទឆ្លើយ ព្រោះលោកវាយឲ្យឆ្លើយ ។

ចំពោះហែម-ហ៊ុន (ជាសុភាចារបុរស)

លោកចាងហ្វាង ៖ កាលដែលលោកហៅមនុស្សជាប់ចោទទាំងនេះមកសួរចម្លើយនោះ លោកមានឃើញស្លាកស្នាមទេ ?

លោក ហែម-ហ៊ុន ៖ មិនឃើញមានស្លាកស្នាមទេ ។

លោកចាងហ្វាង ៖ កាលសួរហើយ លោកមាននាំឈ្មោះ នូ-យ៉ា ទៅឯកន្លែងចោលគ្រាប់បែកដែរឬទេ ?

លោក ហែម-ហ៊ុន ៖ ខ្ញុំបាននាំទៅកន្លែងចោលគ្រាប់បែកដែរ ។ ឈ្មោះនូ-យ៉ានេះបានបង្ហាញរបៀបដែលខ្លួនចោលនោះសព្វគ្រប់ទាំងអស់ ល្មមឲ្យជឿបានថា ឈ្មោះនេះបានចោលមែន ។

លោកព្រះរាជបំរើ ៖ កាលដែលលោកសួរនោះ ឈ្មោះ នូ-យ៉ា បានឆ្លើយលាន់មាត់ថា សូមឲ្យយកកាំភ្លើងមកបាញ់ចោលតែម្តងទៅ ធ្វើម៉េចខ្ញុំបានជាខុសទៅ

ហើយ មែនទេ ?

លោក ហែម-ហ៊ុន ៖ (បញ្ជាក់) ឈ្មោះ នូ-យ៉ានេះបាននិយាយថា សូមឲ្យលោកយកកាំភ្លើងមកបាញ់ចោលតែម្តងទៅ ធ្វើម៉េចខ្ញុំបានជាខុសទៅហើយ, គេនៅសុខៗមិនគួរបើនឹងទៅចោលសម្លាប់គេទេ ។

លោកមេធាវី ហ្វ៊ែរណាង់ដែស្ស សម-សុន ៖ (សុំឲ្យសួរ) រឿងនេះលោកស៊ើបសួរហើយ ម៉េចក៏លោកបញ្ជូនទៅឲ្យក្រុមព្រះនគរបាលស៊ើបសួរវិញ ?

លោកចាងហ្វាង ៖ រឿងនេះស្រេចលើសុភាចារបុរសទេ គេចង់ឲ្យទៅអ្នកណាស៊ើបសួរក៏បាន ព្រោះជាកិច្ចប្រតិភូ (Délégation) របស់គេ ។

លោក ហែម-ហ៊ុន ៖ រឿងនេះកាលពីដំបូងឡើយ ខាងកុម្មិស្សែរទី២ គេសុំឲ្យចោទប្រកាន់លើមនុស្សមិនស្គាល់ឈ្មោះ ខ្ញុំក៏បានទៅពិគ្រោះនឹងឯ.ឧ. កុសល ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ថាគួរឲ្យទៅខាងក្រុមព្រះនគរបាលជាតិ គេអង្កេតជាមុនសិនឬអ្វី ? លោកក៏ថាមិនជាអ្វីទេ ដែដោយខ្ញុំយល់ឃើញ ថាគួរឲ្យទៅក្រុមព្រះនគរបាលជាតិសិន ទើបខ្ញុំឲ្យទៅ ។

លោកចាងហ្វាង (បានហៅលោកតាន់-គឹមតិកមកសួរទៀត)

លោក តាន់-គឹមតិក ៖ កាលខ្ញុំទៅសួរលោក សេង-ទិប ដឹងថាចាប់បានមនុស្សចោលគ្រាប់បែកហើយ ខ្ញុំទៅជំរាបលោកនាយករដ្ឋមន្ត្រីយ៉ែម-សំបូរ ។

លោកមេធាវីហ្វ៊ែរណាង់ដែស្ស សម-សុន ៖ លោកកុម្មិស្សែរទីពីរ, យប់នោះលោកមានគិតគួរពីរឿងមនុស្ស ដែលចាប់បាននោះអី, លោកទៅគិតឯណាផ្សេងទៅវិញ ។ មួយទៀតខ្ញុំឆ្ងល់ណាស់, លោកសុភាចារបុរសបានទទួលរឿងនេះហើយ ម៉េចក៏មិនទុកស៊ើបសួរខ្លួនឯងទៅ ចាំឲ្យក្រុមព្រះនគរបាលជាតិស៊ើបសួរធ្វើអ្វីវិញ?

លោកព្រះរាជបំរើ ៖ រឿងនេះស្រេចលើឯ.ឧ. យោមរាជ, លោកមានអំណាចដាក់ឲ្យទៅខាងណាស៊ើបសួរក៏បាន ។ មួយទៀតបានជាសុភាចារបុរសចាត់ឲ្យទៅក្រុមព្រះនគរបាលជាតិអង្កេតជាមុននោះ ព្រោះសុភាចារបុរសមិនអាចដើរទៅចច្រប់កៀនផ្ទះកៀនច្រកល្ហក ដើម្បីម្បីស៊ើបការណ៍នោះ មានតែខាងក្រុមព្រះនគរបាលជាតិទើបធ្វើដូច្នោះបាន ។ លុះក្រុមព្រះនគរបាលជាតិស៊ើបសួរហើយ គេបញ្ជូនសំណុំរឿងនោះមក ទើបសុភាចារបុរសយកសេចក្តីនោះមកពិចារណាមើលថា តើសេចក្តីអង្កេតនោះគួរយកជាការណ៍បានឬទេ ។ បើយល់ឃើញថាគួរជឿក៏ទុក បើយល់ឃើញថាមិនគួរជឿក៏បដិសេធចោលទៅ, មិនមែនចេះតែធ្វើតាមទាំងអស់នោះទេ ។ ឯរឿងនេះ បានជាគេធ្វើលិខិតដាក់អនាម (inconnu) ព្រោះគេរកមិនទាន់ឃើញជាក់ ។

លោកមេធាវី ហ្វ៊ែរណាង់ដែស្ស សម-សុន ៖ រឿងនេះលោកកុម្មិស្សែរធ្វើសំ

បុត្រក្លែងមក លោកចេះតែថាយកជាការទៅ ។ មនុស្សគេដេញប្រផាប់ចាប់ប្រភឹង បានយកមកឲ្យហើយ លោកនៅតែថាអនាមទៀត ។

លោកចាងហ្វាង ៖ ណ្ហើយ ! នាំជជែកឲ្យតែវែងឥតអំពើ ។

លោកមេធាវី ហ្វៀរណាង់ដែស្ស សម-សុន ៖ រឿងនេះខ្ញុំសុំបដិសេធចោល ដោយឃើញថាខុសនឹងផ្លូវច្បាប់ទទេ ។ តាមគតិច្បាប់ថា ក្រុមព្រះនគរបាលជាតិគ្មានអំណាចស៊ើបសួរមនុស្សត្រូវចោទទេ មានអំណាចស៊ើបសួរតែសាក្សីប៉ុណ្ណោះ ។

លោកព្រះរាជបំរើ ៖ រឿងនេះបើទុកជាថាមិនត្រឹមត្រូវតាមច្បាប់ក៏ដោយ មិនត្រូវបដិសេធចោលក្នុងពេលនេះទេ, ត្រូវឲ្យសាលាឧក្រិដ្ឋជំនុំជំរះសិន បើលោកមេធាវី ហ្វៀរណាង់ដែស្ស សម-សុន សុំបដិសេធចោល ចាំសុំទៅសាលាសាលវិនិច្ឆ័យចុះ ។

ចំពោះលោកស្រី គិម-ស៊ីរី ។

លោកចាងហ្វាង ៖ លោកស្រីមានយោបល់អ្វីទៀតទេ ?

លោកស្រី គិម-ស៊ីរី ៖ ទេ ។

លោកចាងហ្វាង ៖ រឿងនេះលោកហ្វៀរណាង់ដែស្ស សម-សុន ដែលជាមេធាវីនៃព្រះអង្គម្ចាស់ សុទ្ធាវង្ស នរិន្ទតេជ១, ឃួន-លុត១, ចៅ-ស៊ុន១ បានសុំឲ្យញែកកូនក្តីរបស់លោកចេញពីរឿងឈ្មោះ នូ-យ៉ា ព្រោះឈ្មោះទាំងនេះមិនបានសមគំនិតជាមួយឈ្មោះ នូ-យ៉ា ទេ, ឈ្មោះនូ-យ៉ា បានសមគំនិតនឹងពួកណាមួយ ហើយមកឆ្លើយដាក់ឈ្មោះទាំងនេះទៅវិញ ។ រឿងនេះតុលាការយល់ថា មានជាប់ទាក់ទងនឹងគ្នា និងកាត់ផ្តាច់ពីគ្នាមិនបានទេ ។

លោកមេធាវី ហ្វៀរណាង់ដែស្ស សម-សុន ៖ រឿងនេះខ្ញុំត្រូវធ្វើឲ្យអស់ការណ៍

លោកចាងហ្វាង ៖ លោកមិនត្រូវតវ៉ាឲ្យព្រះអង្គម្ចាស់សុទ្ធាវង្ស នរិន្ទតេជទេ ព្រោះព្រះអង្គម្ចាស់សុទ្ធាវង្ស នរិន្ទតេជមិនបានចូលមក, លោកមានសិទ្ធិតវ៉ាឲ្យបានតែឈ្មោះពីរនាក់ប៉ុណ្ណោះ ។

លោកមេធាវីហ្វៀរណាង់ដែស្ស សម-សុន ៖ តវ៉ាឲ្យពីរនាក់បានក៏ដូចជា៣នាក់ដែរ ។ រឿងនេះ សុំឲ្យតុលាការសំរេចសេចក្តីដូចខ្ញុំសុំ ។

លោកចាងហ្វាង ៖ រឿងនេះក្នុងពេលនេះ ស្រេចលើខ្ញុំនិងចៅក្រមប្រឹក្សារបស់ខ្ញុំ២នាក់ប៉ុណ្ណោះ ។ បើលោកត្រូវការតវ៉ាយ៉ាងដូចម្តេច ត្រូវតវ៉ាទៅសាលាវិនិច្ឆ័យចុះ ។

លោកមេធាវី ហ្វៀរណាង់ដែស្ស សម-សុន ៖ ដូច្នេះខ្ញុំសុំប្តឹងជំទាស់ ។

លោកចាងហ្វាង ៖ រឿងនេះលោកមេធាវី ហ្វៀរណាង់ដែស្ស សម-សុន បានសុំតវ៉ាញែកឈ្មោះបីនាក់ គឺព្រះអង្គម្ចាស់សុទ្ធាវង្ស នរិន្ទតេជ១, ឃួន-លុត១,

ថៅ-ស៊ុន១ ចេញពីរឿងឈ្មោះនូ-យ៉ា ។ រឿងនេះយើងមិនយល់ព្រមតាមសេចក្ដីសុំរបស់មេធាវីនេះទេ ។

(ក្នុងពេលនោះ លោកហ្វែរណាង់ដែស្ស សម-សុន បានយកញត្តិមួយ ដែលសុំឲ្យញែករឿងកូនក្ដីរបស់លោក ពីរឿងឈ្មោះនូ-យ៉ា ជូនលោកចាងហ្វាង ។ ឲ្យក្រឡាបញ្ជីចុះក្នុងសេចក្ដីរាយការណ៍) ។

លោកមេធាវី ហ្វែរណាង់ដែស្ស សម-សុន ៖ (បានមានប្រសាសន៍ថា) គឺជាការគាប់ប្រសើរណាស់ ដែលមានហេតុជាសំខាន់ បានលេចឡើងកាលពីម្សិលមិញ ដោយមានលោក កែម-ឡុង និងជា-ឡុង បានឆ្លើយនៅចំពោះមុខតុលាការ ថាខ្លួនបានសួរចម្លើយនូ-យ៉ា មុនដំបូងបង្អស់នៅថ្ងៃ១៥-១-៥០ ពេលម៉ោង១៥និង៣០នាទី ។ ដោយមានចុះហត្ថលេខាលេខយ៉ាងត្រឹមត្រូវ ព្រមទាំងបានប្រគល់ឲ្យទៅលោកសេង-ទិបជាស្រេចហើយផង តែលោកសេង-ទិប បានក្លែងយកលិខិតឯទៀតមកជំនួស ហើយបំបាត់លិខិតមុនចោល ដាក់ថ្ងៃខែពេលម៉ោងដូចលិខិតមុន ដើម្បីយកសេចក្ដីនោះមកចោទប្រកាន់កូនក្ដីខ្ញុំបាទ ថាចូលដៃនឹងឈ្មោះនូ-យ៉ានេះទៅវិញ ។ ខ្ញុំសុំប្ដឹងចោទលើលោកសេង-ទិប, លោកតាន់-គិមតិក និងគូកនមិនស្គាល់ឈ្មោះ ពីបទក្លែងលិខិតនោះ ។

លោកចាងហ្វាង ៖ (លោកមេធាវី ហ្វែរណាង់ដែស្ស សម-សុន ត្រូវប្ដេជ្ញាទទួលខុសត្រូវចំពោះរឿងនេះ លើខ្លួនលោកទាំងអស់) ។

លោកមេធាវី ហ្វែរណាង់ដែស្ស សម-សុន ៖ បាទ, ខ្ញុំទទួល ។

(នៅទីបំផុតនៃប្រសាសន៍របស់លោកចាងហ្វាងនេះ ក្រឡាបញ្ជីបានសូត្រញត្តិរបស់លោកមេធាវី ហ្វែរណាង់ដែស្ស សម-សុន ហើយលោកមេធាវីនេះចូលទៅចុះហត្ថលេខាលើសេចក្ដីនៃញត្តិនោះ) ។

(បន្ទាប់ពីការជូនញត្តិនៃលោកមេធាវី ហ្វែរណាង់ដែស្ស សម-សុន នេះមកទើបលោកមេធាវី អ៊ឹម-ផុន ថ្លែងយោបល់) ។

### សេចក្ដីថ្លែងបរិយាយរបស់មេធាវី អ៊ឹម-ផុន
### សរុបហេតុ

មេធាវីខ្ញុំយល់ឃើញថា សេចក្ដីដោះសាររបស់ឈ្មោះ នូ-យ៉ា ពុំសមហេតុផលគ្រប់ខទេ ទោះបីបើមានការបង្ខិតបង្ខំខ្លះក៏ដោយ ។

១- សាក្សីឈ្មោះ ង៉ែត-ហៀន បានឃើញឈ្មោះនេះអង្គុយនៅមុខមន្ទីរចាត់ការគណបក្សប្រជាធិបតេយ្យ មុនពេលចោលគ្រាប់បែក ។ នៅពេលដែលចោលទៀត លោក ង៉ែត-ហៀន ឃើញឈ្មោះនេះដដែលរត់ ។ នៅឱកាសជំនុំជំរះនេះក្នុងក្រុមអ្នកជាប់ឃុំ៥នាក់ លោកង៉ែត-ហៀនបានចង្អុលចំលើឈ្មោះនូ-យ៉ាតែម្ដង

ត្រង់ឲ្យឈ្មោះថាលោកង៉ែត-ហៀនធ្លាប់ស្គាល់ ឬធ្លាប់ឃើញឈ្មោះនេះពីដើមមកក៏ទេដែរ ព្រោះលោកង៉ែត-ហៀនតាំងពីត្រូវគ្រាប់កាលណា ពុំដែលបានដើរទៅណាមកណារួចទេ ។ មិនតែប៉ុណ្ណោះ មានសាក្សីក្រៅទៀតជាច្រើន ដូចជាឈ្មោះតាន់-គីស៊ុក និងទាហានបារាំងម្នាក់ បានដេញចាប់ឈ្មោះនេះទាល់តែបាន ហើយនៅពេលដែលចាប់នោះ ឈ្មោះនូ-យ៉ា មានទាំងបេរ៉េមួយនៅនឹងខ្លួនផង ។ សាក្សីឈ្មោះហេ-មុយឆៃ ឲ្យការណ៍ថា ឃើញមនុស្សស្លៀកខ្មៅពាក់ខ្មៅរត់ប៉ះខ្លួននៅផ្លូវប៊ូទ្បស ដល់ផ្លូវហ្វីយី និងម៉ូរីសឡុង, គេចាប់បានមនុស្សនោះកំពុងតែហត់បែកញើសនិយាយពុំកើតផង ។ ត្រង់នេះឲ្យឃើញថា ឈ្មោះនូ-យ៉ាបានរត់មែន សេចក្ដីដោះសារបស់នូ-យ៉ាថា ខ្លួនជិះស៊ីក្លូប្រាថ្នាទៅទិញថ្នាំនៅផ្សារកណ្ដាលនោះ ពុំសមហេតុផលទេ ។ ក្រៅពីភស្តុតាងនៅមានឈ្មោះត្រឹង-តុង និងជាម-ឃុន បានឲ្យការណ៍ថា កាលនៅថ្ងៃចោលគ្រាប់បែក បានឃើញមនុស្សស្លៀកខ្មៅ ពាក់បេរ៉េខ្មៅរត់ត្រង់នេះសមប្រកប, កាលដែលគេចាប់ឈ្មោះនូ-យ៉ាបានភ្លាម ឃើញឈ្មោះនេះមានបេរ៉េមែន ។

២- ចម្លើយឈ្មោះនូ-យ៉ា នៅមន្ទីរកុម្មិស្សែរទីពីរ កាលពីថ្ងៃទី១៥ មករា ឲ្យការណ៍ថា គ្រាប់បែកដែលខ្លួនយកទៅបោះ គឺគ្រាប់បែកក្រឡាកាត់ ។ តាមសំបុត្រពេទ្យលោក ម៉ាក-ម៉េណា នៅថ្ងៃទី១៨ ខែដដែល ក្រោយឈ្មោះនូ-យ៉ាឆ្លើយនៅកុម្មិស្សែរទី២ចំនួន៣ថ្ងៃ បានឲ្យការណ៍ថា កំទេចគ្រាប់បែកដែលបានយកពីរបួសលោក ង៉ែត-ហ៊ាន ឃើញថាជាគ្រាប់បែកក្រឡាកាត់ៗ ប្រាកដៗ ត្រង់នេះនឹងជឿថា អ្នកសួរចម្លើយវាយបង្ខំឲ្យឆ្លើយទៅដូច្នេះ ពុំសមបើថាវាយ ឲ្យឆ្លើយដាក់ឈ្មោះនេះឈ្មោះនោះជាការគួរ ។

៣- នៅមន្ទីរស៊ើបសួរសាលាលុយុន ពីថ្ងៃទី១៦ មករា ឈ្មោះនូ-យ៉ាបានឆ្លើយថា កាលបោះគ្រាប់បែកមិនដឹងជាមានមនុស្សប៉ុន្មាន នៅទីកន្លែងណាធ្វើអ្វីខ្លះ ព្រោះបាំងនឹងឡប់ខ្សែ ។ នៅមន្ទីរចាត់ការគណបក្សប្រជាធិបតេយ្យ មានឡប់ខ្សែមែន ។ ត្រង់នេះសឲ្យឃើញថា ឈ្មោះនូ-យ៉ា ពិតបានចោលមែនបានជាដឹងថាមានឡប់ខ្សែ; នឹងថាលោកសុភាចារបុរសបង្គាប់ឲ្យឆ្លើយថាដូច្នេះក៏ទេដែរ ព្រោះនូ-យ៉ាបានឲ្យការណ៍ថា នៅមន្ទីរស៊ើបសួរគ្មាននរណាបង្ខិតបង្ខំខ្លួនទេ ឬថាឈ្មោះនេះឆ្លើយតាមដែលខ្លួនឆ្លើយនៅផ្ទះកុម្មិស្សែរទីពីរក៏ពុំបាន ព្រោះនៅក្នុងចម្លើយនោះ ពុំមានឃើញចម្លើយអំពីឡប់ខ្សែទេ ។

៤- នៅថ្ងៃទី១៦ មករា ឈ្មោះនូ-យ៉ា បានទៅបង្ហាញបែបបទដែលខ្លួនចោលគ្រាប់បែក និងផ្លូវដែលខ្លួនរត់ សមប្រកបនឹងចម្លើយខ្លួន ព្រមទាំងចម្លើយសាក្សីដែលបានដេញឈ្មោះនូ-យ៉ា រហូតដល់ចាប់បាន; ត្រង់នេះនឹងថាគេបង្ខិតបង្ខំឲ្យនាំ

ផ្លូវឈ្មោះនូ-យ៉ា ពុំសម ព្រោះកាលនោះមានលោកសុភានិងលោកព្រះរាជអាជ្ញាផង ។

៥- នៅថ្ងៃទី៣ កក្កដា គ.ស.១៩៥០ ចំពោះសាលាក្រុមចោទ ឈ្មោះនូ-យ៉ា ថាគេធ្វើបាបខ្លួនឲ្យឆ្លើយតាមមានរបូតពាក្យថា គេថាឲ្យឆ្លើយតាមទៅព្រះករុណានឹងលើកទោស និងថាកាលឆ្លើយនៅមន្ទីរសុភាចារបុរស ដែលឆ្លើយតាមមកនោះ មកពីគេសន្យាថា នឹងទិញនំបុ័ងឲ្យទទួលទាន ។

មូលហេតុដូចពណ៌នាមកនេះ មេធាវីខ្ញុំយល់ថាមានពិរុទ្ធពេញទីទៅលើឈ្មោះនូ-យ៉ា ហើយសុំឲ្យតុលាការផ្ដន្ទាទោសឈ្មោះនេះយ៉ាងធ្ងន់ តែកុំឲ្យដល់ទៅប្រហារជីវិត ព្រោះបើឈ្មោះនេះស្លាប់ទៅហើយ នឹងនាំរឿងឃាតកម្មដែលស្មុគស្មាញនេះរលត់ទៅដែរ មិនអាចនឹងរកអ្នកដើមគំនិតក្នុងបទឧក្រិដ្ឋនេះឃើញ ។ ចំណែកអ្នកជាប់ចោទដទៃទៀត ដែលមានរូបមកនេះ មេធាវីខ្ញុំមិនបានចោទប្រកាន់ផងទេ ព្រោះខ្លាចពានទៅលើមនុស្សសុចរិតដែលត្រូវគេមួលបង្កាច់។ ប៉ុន្តែយោបល់របស់មេធាវីខ្ញុំនេះ ស្រេចទៅលើសេចក្ដីវិនិច្ឆ័យរបស់តុលាការចុះ ។

ម្យ៉ាងទៀតក្នុងរឿងក្ដីនេះ មេធាវីខ្ញុំសុំទារជម្ងឺចិត្តតែមួយរៀលប៉ុណ្ណោះទេ តាមសេចក្ដីសុំរបស់លោកស្រីគីម-សិរី ជាភរិយារបស់លោកអតីតប្រធានរដ្ឋសភា ។

(បន្ទាប់ពីសេចក្ដីថ្លែងរបស់លោក អ៊ឹម-ផុន មក, លោក ថាច់--ធួន ជាព្រះរាជបំរើ ក៏បានថ្លែងយោបល់ចោទប្រកាន់ដូចតទៅនេះ) ៖

តាមសំណុំរឿង និងតាមសេចក្ដីដែលបានឃើញដោយនៅចំពោះមុខតុលាការ ឃើញថារឿងនេះមាន២រឿង, មានត្រូវចោទប្រកាន់៣ខ គឺប្រព្រឹត្តធ្វើឃាដ លោកឧកញ៉ា អៀវ-កើស១, មានបំណងធ្វើឃាតលើរូបលោកង៉ែត-ហៀន ដោយបានគិតទុកជាមុន១, ស្មគ្របក្សពួកជាក្រុមសម្ងាត់ សំរាប់សម្លាប់ឥស្សរជននៅក្រុងភ្នំពេញ១ ។

រឿងធ្វើឃាដលោកអ្នកឧកញ៉ាអៀវ-កើស និងបំណងធ្វើឃាដលោកង៉ែត-ហៀននេះ លោកមេធាវី អ៊ឹម-ផុន បានអធិប្បាយរៀបរាប់សព្វគ្រប់ល្មមស្ដាប់បានដែរហើយ ។ ត្រង់កន្លែងនេះ ខ្ញុំសូមបញ្ចូលជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ។ រឿងនេះឃើញថាមានពិរុទ្ធធួនល្មម តើឈ្មោះនូ-យ៉ា ថាជាអ្នកបានធ្វើមនុស្សឃាដ លើរូបលោកអ្នកឧកញ៉ាអៀវ-កើស និងមានបំណងធ្វើមនុស្សឃាដលើរូបលោកង៉ែត ហៀន ដោយបានគិតទុកជាមុន ។ បទល្មើសនេះ បានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញកាលពីថ្ងៃទី១៤ មករា គ.ស.១៩៥០ ។

បទល្មើសនេះតាមមាត្រា..........................................................................៥០៥, ៥០៦

យល់ឃើញថា ឈ្មោះនូ-យ៉ា ត្រូវមានពិរុទ្ធពេញទី ព្រោះបានគិតទុកជាមុន ។ បទ

ល្មើសនៅទីដដែលនេះ តាមបទបញ្ញត្តិនៃមាត្រា៧៧... ក្រមព្រហ្មទណ្ឌថា ត្រូវមានទោស ។

ឥឡូវនេះ ខ្ញុំសូមបញ្ជាក់ពាក្យលោក អ៊ឹម-ផុន ដែលពោលអំបាញ់មិញបន្តិច ព្រោះបើខ្ញុំមិនពោលបញ្ជាក់ទៅ នឹងនាំឲ្យប្រជាជនអ្នកស្ដាប់ ស្មានថាខ្ញុំមិនចេះធ្វើការ ។ ខ្ញុំសូមបញ្ជាក់ថា អំពីរឿងឈ្មោះនូ-យ៉ា ដែលថាមានដីកាសាលាបារាំងរកចាប់ខ្លួន ដោយបានប្រព្រឹត្តចោរកម្មនិងបទមនុស្សឃាដដោយក្លាហាននោះ ខ្ញុំបានចាត់ការសរសេរសំបុត្រ១ច្បាប់ទៅខាងសាលាបារាំងហើយ, រឿងនេះក៏បានចាត់ការរួចស្រេចហើយ ។

លុះបានបញ្ជាក់ពាក្យនេះហើយ លោកថា ពួកគូកនរបស់នូ-យ៉ា ដែលធ្វើឃាដលោកអ្នកឧកញ៉ាអៀវ-កើស និងបំណងធ្វើឃាដលោកង៉ែត-ហៀននោះ គឺជាប់ឃុំ៨នាក់ ដូចបាននាំយកមកនៅទីនេះស្រាប់ គឺឈ្មោះ ឃួន-លុត១, ចៅ-ស៊ុន១, ឡាំ-សុត១, ហាន-ច្រិច១ ។ អ្នកបាត់ខ្លួន៧នាក់...

( ឯកសារដើមបាត់២ទំព័រ គឺទំព័រ១១២ និងទំព័រ១១៣ )

...ចម្លើយដែលខ្លួនបានឆ្លើយនៅមុខលោកកុម្មិស្សែរទីពីរ និងនៅក្រុមព្រះនគរបាលជាតិនោះ ពិតជាត្រឹមត្រូវហើយ ។

ដូច្នេះឃើញថា គោលបំណងរបស់អ្នកទាំងអស់នេះ មិនប្រសើរសោះឡើយ ព្រោះថារឿងធ្វើឃាដនេះ តាមចម្លើយឈ្មោះនូ-យ៉ា ថាអ្នកទាំងនេះមិនមែនមានបំណងសម្លាប់តែលោកអ្នកឧកញ៉ាអៀវ-កើសម្នាក់ទេ គឺបំរុងនឹងសម្លាប់ជនម្នាក់ដែលនៅខាងជើងផ្ទះលោកកុម្មិស្សែរធំដែរ, ថាបានទៅពិនិត្យឃ្លាំមើលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលស្ដេចទៅឯចំការមនផង ។ ថា មានផ្ទះមួយទៀតនៅខាងកើតដំណាក់ព្រះអង្គម្ចាស់ នរិន្ទតេជ ក៏បំរុងនឹងសម្លាប់ដែរ ។ គិតទៅរឿងនេះកើតមុនដែលចោលគ្រាប់បែកនោះ ប្រហែលជា៧-៨ខែមកហើយ កើតនៅក្នុងគ.ស.១៩៤៩ នេះ ។ រឿងនេះតាមចម្លើយឈ្មោះនូ-យ៉ាឆ្លើយ ឃើញថាក្បោះក្បាយណាស់ ។

ចំណែកអ្នកដែលឈ្មោះ (រុន) ចៅ-ស៊ុន និង ឃួន-លុត កាលនៅក្រុមព្រះនគរបាលជាតិ បានឆ្លើយទទួលសារភាពថា បានប្រាស្រ័យទាក់ទងជាមួយព្រះអង្គម្ចាស់ នរិន្ទតេជ ដល់មកម្សិលមិញនេះឆ្លើយថា ធ្លាប់នៅក្នុងដំណាក់ព្រះអង្គម្ចាស់នរិន្ទតេជ, ឯចៅ-ស៊ុនថា បាននៅយាមដំណាក់នោះផង, ឃើញថាអ្នកទាំងពីរនេះ ប្រាស្រ័យទាក់ទងនឹងព្រះអង្គម្ចាស់នរិន្ទតេជ ។

ចៅ-ស៊ុន កាលឆ្លើយនៅក្រុមព្រះមគរបាលជាតិ និងនៅមុខសុភាចារបុរសថា បានបង្កើតក្រុមមួយ ដើម្បីធ្វើឃាដឥស្សរជននៅភ្នំពេញ ហើយថាបានបង្កើតនេះ

នេះស្ងាត់ណាស់ ឥតមានអ្នករាជការណាដឹងទេ, គូកនមានហើយ គ្រឿងអាវុធក៏មានស្រេចអស់ហើយ ។ ដល់មកក្នុងទីនេះ អ្នកទាំងពីរនាក់ឆ្លើយប្រកែកដាច់អហង្ការ ថាខ្លួនឥតមានចូលដៃជាមួយឈ្មោះនូ-យ៉ា ដែលបានធ្វើឃាតកម្មនេះទេ ។

ឈ្មោះ ហាន-ច្រិច នេះ ទំនងជាមានទាក់ទងជាមួយពួកនេះដែរ ដោយឈ្មោះនូ-យ៉ា បានឆ្លើយនៅកុម្មិស្សែរសង្កាត់ទី២ ថាមានឈ្មោះ លុត, ច្រិច ជាដើម បានរួមគំនិតជាមួយ ។ ឈ្មោះហាន-ច្រិចនេះ កាលឆ្លើយនៅមុខសភា...

( ឯកសារដើមបាត់ពីរទំព័រ គឺទំព័រទី១១៦ និងទំព័រ១១៧ )

... រឿងនេះឃើញមានទាក់ទងគ្នា, ការដែលក្រសួងអយ្យការ បានចោទប្រកាន់លើឈ្មោះនូ-យ៉ា និងគូកនទាំងប៉ុន្មាននាក់ គឺបទស្មគ្រគ្រធ្វើជាពួកក្រុមនិងធ្វើឃាតកម្មនៅក្រុងភ្នំពេញ ក៏បានឃើញហេតុដូចយើងបានពណ៌នាមកអំបាញ់មិញនេះឯង ។

ហេតុដែលឈ្មោះនូ-យ៉ាបានប្រព្រឹត្តនេះ ជាផលរបស់ក្រុមសម្ងាត់នេះឯង ។ គិតទៅឃើញថា មានក្រុមសម្ងាត់មួយដូចយើងបានពណ៌នាមកហើយ, មានគ្នានិងមានអាវុធក៏ច្រើន ។ ដូច្នេះហើយបានជាក្រុមអយ្យការ លើកយករឿងនេះមកឲ្យតុលាការពិចារណាមើលអ្នកដែលប្រព្រឹត្ត និងអ្នកដែលសមគំនិត ដូចមានឈ្មោះដែលយើងបានរាប់ពីខាងលើមកហើយ គឺសុទ្ធតែជាអ្នកសមគំនិតពីបទសម្លាប់ឯ.ឧ. អៀវ-កើស និងបំណាងសម្លាប់លោកង៉ែត-ហៀន ។ មួយទៀត, សូមឲ្យតុលាការពិចារណាមើលផងដដែលនេះ ពីបទបង្កើតបក្សពួកមួយនៅភ្នំពេញ តាំងពីឆ្នាំ១៩-៤៩ ។ រឿងនេះសុំឲ្យតុលាការធ្វើទោសនូ-យ៉ាជាទម្ងន់ ។ ឯមនុស្សត្រូវចោទឯទៀត ស្រេចលើតុលាការចុះ ។

❑ ❑

❑

# សេចក្តីសន្និដ្ឋាន

មុនដំបូងបង្អស់ ខ្ញុំសូមបង្អោនកាយគោរពចំពោះ ដួងវិញ្ញាណក្ខន្ធ ឯ.ឧ.អៀវ-កើស ដែលបានរងគ្រោះថ្នាក់ក្នុងឃាតកម្ម យ៉ាងឃោរឃៅដ៏ពន្លឹក ។

ខ្ញុំសូមឱនកាយគោរព ចំណោះលោកស្រី គីម-ស៊ីរី ជាភរិយាសព ឯ.ឧ.អៀវ កើស ហើយខ្ញុំសូមរំលែកទុក្ខអំពីលោកស្រី យ៉ាងឈ្មោះចំពោះអស់ពីដួងចិត្ត មកដឹកលទុកក្ខហប្ទ័យវត្ថុរបស់ខ្ញុំ ក្នុងឱកាសនេះថែមទៀត ។

ដោយលោកស្រី គិម-ស៊ីរី មិនបានមកនៅវេលានេះ ខ្ញុំសុំលោកអ្នកណាជាសាលោហិតរបស់លោកស្រី ដែលបានមក នាំសំដីខ្ញុំទៅជំរាបលោកឲ្យផង ។

សូមជំរាបតុលាការ,

សូមតុលាការអនុញ្ញាត ឲ្យខ្ញុំសារស័ព្ទសើរើអំពីដើមកំណើតនៃ លទ្ធិយុវប្រជាធិបតេយ្យខ្មែរ ដើម្បីជាប្រទីបពន្លឺសំរាប់កំចាត់បង់ នូវដុំនែងងឹតដែលជាហេតុការណ៍កំបាំងក្នុងរឿងក្ដីនេះ ។

ករណីយកិច្ចនៃមេធាវីការពារចុងចោទ តាមធម្មតាគ្រាន់តែដោះសារឲ្យកូនក្ដីរបស់ខ្លួនរួចខ្លួនពីទុក្ខទោសតែប៉ុណ្ណោះ ។

ចំណែកខាងខ្ញុំ ដែលជាតិប្រឹក្សានយោបាយរបស់គណ:រាស្ត្រសេរីភាព ដែលមានព្រះអង្គម្ចាស់សុទ្ធាវង្ស នរិន្ទតេជ ជាប្រមុខ និងលោក ឃួន-លុត ជាអតីតតំណាងរាស្ត្រនៃគណ:នេះ, ទ្រង់និងលោកនេះជាប់ចោទ, ហេតុនេះបានជាខ្ញុំ ត្រូវតែខិតខំដោយផ្លូវសុចរិត, យុត្តិធម៌ ដើម្បីជួយបំភ្លឺតុលាការជាតិ ប្រយោជន៍នឹងរកឲ្យឃើញ នូវពួកអ្នកសមគំនិតពិតៗ ។

ពួកអ្នកសមគំនិតទាំងនេះ ទោះបីក្រុមដើមបណ្ដឹងរដ្ឋប្បវេណីក្ដី គណបក្សប្រជាធិបតេយ្យក្ដី គណរាស្ត្រសេរីភាពដែលត្រូវប៉ះពាល់ក្ដី សុទ្ធតែខំរកមុខឲ្យឃើញ ដើម្បីបង្ហាឲ្យជនបរទេស ដែលនៅក្នុងប្រទេសកម្ពុជាឯករាជ្យ មានសេចក្ដីសង្ឃឹមជឿទុកចិត្តលើតុលាការជាតិខ្មែរផង ។

❑ ❑

❑

# ប្រវត្តិនៃលទ្ធិយុវប្រជាធិបតេយ្យខ្មែរ

កាលពីចុងឆ្នាំ១៩៤៦ នោះ មានការបើកឱកាសឲ្យបោះឆ្នោតជាសកល ដើម្បីជ្រើសតាំងសភាតំណាងរាស្ត្របណ្តោះអាសន្ន តាមព្រះរាជបំណងនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។

នេះជាជំហានជឿនដំបូងរបស់ប្រជារាស្ត្រខ្មែរ, វរជនបាននាំគ្នាចាប់ឆ្នោតដោយសេចក្តីស្រឡាញ់វិជ្ជាឧត្តមគតិរៀងៗខ្លួនគឺ ៖

ស្រឡាញ់គណបក្សប្រជាធិបតេយ្យ របស់អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ-យុត្តិវង្ស ឬស្រឡាញ់គណៈរាស្ត្រសេរីភាព របស់ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ។

ប្រជារាស្ត្រវិញមិនមែនដូច្នោះទេ គឺគេចាប់ឆ្នោតរូបក្បាលដំរីកាន់ផ្កាឈូក៣ ឬគេចាប់ឆ្នោតរូបប្រាសាទ ។

កាលណោះ គណបក្សប្រជាធិបតេយ្យបាន៥០មណ្ឌល, គណៈរាស្ត្រសេរីភាពបាន១៤, ឯកច្ឆន្ទបាន៣, គណៈចំរើនជាតិគ្មានសោះ ។

ក្នុងគ្រានោះ ពិតមែនតែសម្តេចក្រុមព្រះ ស៊ីសុវត្ថិ-មុនីរេត ទ្រង់ជាប្រមុខនៃរដ្ឋាភិបាល មានអំណាចពេញទី តែឥតគណបក្ស ទើបអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ-យុត្តិវង្ស ទីប្រឹក្សានយោបាយនៃគណបក្សប្រជាធិបតេយ្យ ដែលបានឆ្នោតភាគច្រើន, នោះស្រាប់តែព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះនរោត្តម-សីហនុ ទ្រង់ឲ្យរៀបចំរដ្ឋាភិបាលជាថ្មីឡើង ។

ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ជាប្រមុខគណៈរាស្ត្រសេរីភាព ដែលមានឆ្នោតតិច ទ្រង់មិនព្រមទទួលធ្វើការជាមួយនឹងរដ្ឋាភិបាលថ្មីនោះ មិនចូលជាសេចក្តីទំនាស់ទេ ។

ដល់ពេលបោះឆ្នោតក្នុងឆ្នាំ១៩៤៧ គណបក្សប្រជាធិបតេយ្យបាន៥៤មណ្ឌល, គណៈរាស្ត្រសេរីភាពបាន២០, គណៈដទៃទៀត គឺគណៈចំរើនជាតិ, គណៈខេមរប៉ុណ្ណការ, គណៈរួមជាតិ គ្មានបានមួយមណ្ឌលសោះ ។

ទើបព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ព្រះមេត្តាប្រោសឲ្យគណបក្សប្រជាធិបតេយ្យ ចាត់តាំងគណៈរដ្ឋមន្ត្រីជាសភា ( សមាជិករដ្ឋមន្ត្រីសុទ្ធតែពួកប្រជាធិបតេយ្យទាំងអស់ ) ក្រោមអធិបតីភាពនៃ ឯ.ឧ. ឈាន-វ៉ំ ។

គណៈរាស្ត្រសេរីភាព ឥតមានតវ៉ាជំទាស់អំពីរឿងនេះតែបន្តិចបន្តួចក៏គ្មាន ។

គ្រានោះ ឯ. ឧ. យ៉ែម-សំបូរ ជាតំណាងរាស្ត្រប្រជាធិបតេយ្យ ធ្វើជារដ្ឋលេខាធិការនិងនាយកក្រុមព្រះនគរបាលជាតិ បានរករឿងហេតុអំពីមន្ត្រីជាន់ខ្ពស់ខ្លះក្នុងគណបក្សរបស់ខ្លួន ។

ហេតុដូច្នេះហើយ, បានជាមានការមិនស្រុះស្រួលគ្នាក្នុងគណបក្សប្រជាធិបតេយ្យ ទើប ឯ. ឧ. ឈាន-វ៉ម បានសុំលាចេញពីតំណែង ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់តម្រូវ ឯ. ឧ. ប៉ែន-នុត ជាទីប្រឹក្សានយោបាយនៃគណបក្សប្រជាធិបតេយ្យ ពេលនោះនៅធ្វើជាចៅហ្វាយក្រុងភ្នំពេញនៅឡើយ ឲ្យចាត់តាំងរដ្ឋាភិបាលឡើង, ឯ. ឧ. ប៉ែន-នុត មិនបាននឹកនាដល់ ឯ. ឧ. យ៉ែម-សំបូរ ។

ហេតុដូច្នេះហើយ, បានជា ឯ. ឧ. យ៉ែម-សំបូរ និយាយពាក្យទ្រគោះ បោះពាក្យសំដីមិនជាទីគប្បីចំពោះ ឯ. ឧ. ប៉ែន-នុត ដែលជាហេតុនាំឲ្យគំនិតយោបល់ខ្វែងគ្នាក្នុងក្រុម ឯ. ឧ. ប៉ែន-នុត, អៀវ-កើស ហើយកើតមិនចុះសំរុងគ្នាឡើងក្នុងក្រុម ឯ. ឧ. អៀវ-កើស និងក្រុម ឯ. ឧ. យ៉ែម-សំបូរ ។ ឯ. ឧ. យ៉ែម-សំបូរ បានបំបែកគណៈ ហើយបង្កើតឲ្យមានពួកក្រុមប្រឆាំងក្នុងគណៈឡើង ។

រួចតមក មិនបានយូរប៉ុន្មាន ក៏បានផ្តួលរដ្ឋាភិបាល ឯ. ឧ. ប៉ែន-នុត ដោយបានជំនួយ២០ឆ្នោតអំពីពួកសមាជិករដ្ឋសភាខាងសេរីភាព ។

ដោយ ឯ. ឧ. អៀវ-កើស បានជំទាស់ បណ្តាលឲ្យ ឯ. ឧ. យ៉ែម-សំបូរ រើសសមាជិករដ្ឋមន្ត្រីលើកទី១មិនបានសំរេច ។

ទើបអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ-ឥន្ទរាវង្ស ក៏ពុំអាចតាំងគណៈរដ្ឋមន្ត្រីបានសំរេចទៀត ។

តមក ឯ. ឧ. អៀវ-កើស បានជំទាស់នឹងការជ្រើសតាំងរដ្ឋមន្ត្រី ឯ. ឧ. យ៉ែម សំបូរម្តងទៀត លុះត្រាតែព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់សំរុះសំរួល កុំអី ឯ. ឧ. យ៉ែម-សំបូរ រើសសមាជិករដ្ឋមន្ត្រីមិនបានសំរេចទៀត ។

ក្រោយកាន់កាប់អំណាចបានក្នុងរវាងពីរបីខែ ឯ. ឧ. យ៉ែម-សំបូរ ជាមេគណបក្សប្រជាធិបតេយ្យដែលបែកចេញទៅ បានសុំដកអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រខាងគណបក្សប្រជាធិបតេយ្យខ្លះ ដើម្បីធ្វើប្រទេសឲ្យរាបសារល្អ ឬដើម្បីរំសាយសេចក្តីព្យាបាទរបស់ខ្លួនក៏ពុំដឹង ។

ដោយការប្រកាន់គណបក្ស សមាជិកសភាភាគច្រើនបានបដិសេធដាច់អហង្ការ មិនព្រមទទួលតាមពាក្យសុំរបស់ ឯ. ឧ. យ៉ែម-សំបូរ ។

ឯគណៈរាស្ត្រសេរីភាព ដែលមានសមាជិកភាគតិច បានតាំងខ្លួនជាអព្យាក្រិត

ឮថា ឯ. ឧ. យ៉ែម-សំបូរ បានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សុំអំណាចពេញទី ដើម្បីចាប់ចងពួកឥស្សរជននិងពួកប្រជាធិបតេយ្យធំៗ ដែលមិនមែនជាពួកបំបែកគណៈ ។

តាមពាក្យចចាមអារាម គេនឹងចាប់មន្ត្រីធំម្នាក់ ដែលជាហេតុនាំឲ្យលោកស្រីម្នាក់ ត្រូវជាមាតារបស់មន្ត្រីធំនោះទទួលអនិច្ចកម្មទៅ ព្រោះក្នុងពេលនោះលោកស្រី

ដោយហេតុសេចក្ដីការពារទុកជាមុន បានជាមានសមាជិកគណបក្សប្រជាធិបតេយ្យមួយក្រុម មាន ឯ. ឧ. ហាក់-ម៉ុងសេង ជាដើម បានធ្វើញតិមួយបន្ទោសដល់រដ្ឋាភិបាល ជូនទៅរដ្ឋសភា ដើម្បីរំលំរដ្ឋាភិបាល ឯ. ឧ. យ៉ែម-សំបូរ ។

ឯ. ឧ. យ៉ែម-សំបូរ បានដឹងមុន ទើបក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង អំពីពេលមុនថ្ងៃជំនុំរដ្ឋសភា សូមឡាយព្រះហត្ថក្នុងព្រះរាជក្រឹត្យ ដែលទុកដូចជារន្ទះ ដើម្បីបាញ់រំលាយរដ្ឋសភានៅថ្ងៃទី១៨ កញ្ញា ឆ្នាំ១៩៤៩ តាមបញ្ញត្តិប្រការ៣៨ ដោយឥតមានលក្ខណក្រឹត្យទុក ។

ឯ. ឧ. អៀវ-កើស បានទទួលធ្វើជានាយករដ្ឋមន្ត្រីបណ្ដោះអាសន្នដោយស្វ័យប្រវត្តិ ដើម្បីរង់ចាំការបោះឆ្នោតជាថ្មី ដែលត្រូវចាត់ចែងក្នុងរយៈកាលកំណត់២ខែ ។ ឯ. ឧ. បានចាត់តាំង ឯ. ឧ. សុន-វីនសៃ ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ប៉ុន្តែអស់ឯ. ឧ. និងអស់លោកចៅហ្វាយខេត្តដែលបានឲ្យអញ្ជើញចូលមកក្រោយពេលដែលរដ្ឋសភារលាយទៅហើយនោះ បានជូនយោបល់មូលមាត់គ្រប់គ្នាថា ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ពុំអាចធ្វើទៅបាន ដោយមានសេចក្ដីអសន្តិសុខទូទៅ ។

ពេលនោះឯង ហាក់ដូចជាមានគេប្រើអ្នករាជការម្នាក់ ឲ្យដើរទៅបញ្ចុះបញ្ចូលអស់ ឯ. ឧ. និងអស់លោកចៅហ្វាយខេត្តមុនពេលជំនុំ ។

តាមការពិត ក្នុងសម័យនោះ អសន្តិសុខមានមែន តែមានដោយអន្លើៗទេ ។

តាំងពីនោះមក ស្ថានការណ៍របស់ប្រទេស កាន់តែដុនដាបទៅជាលំដាប់ ។ រដ្ឋាភិបាលក៏បានដឹង ទុកជាមិនបាច់ពិគ្រោះសួរចៅហ្វាយខេត្តក៏ដឹងបានដែរ ។ ការពិគ្រោះសួរនេះ គ្រាន់តែជាគំរប់ការប៉ុណ្ណោះ ។

ដោយបានទទួលដំណឹងពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ថាទ្រង់នឹងទទួលការខុសត្រូវក្នុងការជ្រើសតាំងរដ្ឋាភិបាលថ្មី, នោះ ឯ. ឧ. អៀវ-កើសក៏បានក្រាបបង្គំទូល សូមព្រះរាជានុញ្ញាតលាឈប់ពីតំណែងនាយករដ្ឋមន្ត្រីបណ្ដោះអាសន្ន ទើបព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ប្រគល់តំណែងនេះទៅ ឯ. ឧ. យ៉ែម សំបូរ ដែលជាអ្នកផ្ដើមហេតុរំលាយរដ្ឋសភា ។

ឯ. ឧ. យ៉ែម-សំបូរ មានបំណងចង់ប្រគល់អំណាចជំនុំសំរេច ទៅក្រុមប្រឹក្សាព្រះរាជាណាចក្រ ដែលជាសភាទីប្រឹក្សា ។ ការធ្វើដូច្នេះ ដើម្បីឲ្យក្រុមប្រឹក្សាព្រះរាជាណាចក្រ ធ្វើការជំនួសរដ្ឋសភាដែលរលាយទៅហើយនោះ ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានសុំឲ្យមេគណបក្សនិមួយៗ ចាត់ប្រតិភូបីនាក់ ឲ្យចូលទៅរួបរួមជាមួយនិងគណៈកម្មការ ដើម្បីកែប្រែច្បាប់រដ្ឋធម្មនុញ្ញថ្ងៃទី៦ ឧសភា ឆ្នាំ១៩៤៧ ។

សង្គមពួកមន្ត្រីរាជការខ្មែរ (L'asfac) ដែលពុំមែនជាគណបក្សនយោបាយ ក៏បានសុំចូលទៅជំនុំជាមួយនឹងគណៈកម្មការបាន ដោយពុំបានពិគ្រោះសួរគណៈកក្មាធិការជាមុន ហើយបានចាត់បញ្ជូនប្រតិភូ ទីប្រឹក្សាព្រះរាជអាណាចក្រ សុទ្ធតែជាសមាជិកនៃគណៈរួមជាតិ និងគណៈចំរើនជាតិ ។

ការសុំចូលជំនុំនេះ ដើម្បីឲ្យកម្លាំងដល់រដ្ឋាភិបាលយ៉ែម-សំបូរ ក្នុងករណីណាដែលជំនុំទៅ មិនបានចុះសំរុងគ្នា ត្រូវបញ្ចេញមតិ ។

គណបក្សធំៗដូចជា ប្រជាធិបតេយ្យ, សេរីភាព, ខេមរប៉ុណ្ណការ បានជំទាស់នឹងគណៈកម្មការ ពីកែប្រែរដ្ឋធម្មនុញ្ញនេះ ។

នៅឱកាសជំនុំលើកទី២ (ថ្ងៃទី១១ មករា ១៩៥០) នេះខ្ញុំជាប្រធានគណៈប្រតិភូនៃគណៈរាស្ត្រសេរីភាព បានសូត្រញត្តិជំទាស់នឹងសេចក្តីកែប្រែរដ្ឋធម្មនុញ្ញ ។ ញត្តិនេះបានទទួលសេចក្តីយល់ព្រមទាំងស្រុង ពីប្រតិភូនៃគណបក្សប្រជាធិបតេយ្យ និងគណបក្សខេមរប៉ុណ្ណការ, ឯ. ឧ. ចាន់-ណាក នៃគណបក្សរួមជាតិ ជាទីប្រឹក្សានៃព្រះរាជអាណាចក្រ ជាងតីតរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីបច្ចុប្បន្ននៃក្រសួងយុត្តិធម៌ក៏បានយល់ព្រមផងដែរ ។

ក្រោយការជំនុំលើកទី២នេះ ពួកប្រតិភូគណបក្សប្រជាធិបតេយ្យ និងគណបក្សខេមរប៉ុណ្ណការ បានសំរេចជាដាច់ខាត មិនព្រមចូលជំនុំក្នុងលើកក្រោយៗទៀតទេ ។ គឺពួកប្រតិភូទាំងនោះបានផ្តើនឲ្យរដ្ឋាភិបាលយ៉ែម-សំបូរ ។

សូមជំរាបតុលាការ,

ការថ្លែងប្រវត្តិសង្ខេបនេះ បង្ហាញឲ្យឃើញជាក់ស្តែងថា តាំងពីបង្កើត លទ្ធិប្រជាធិបតេយ្យខ្មែរឡើង (បង្កើតគណបក្ស) ដរាបមកទល់នឹងថ្ងៃ ឯ. ឧ. អៀវ-កើស ត្រូវគេធ្វើឃាតនេះ (នៅថ្ងៃទី១៨-១-៥០) ឯ. ឧ. អៀវ-កើស និងព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ គណបក្សប្រជាធិបតេយ្យ និងគណៈរាស្ត្រសេរីភាពក្តី ពុំដែលមានហេតុទាស់ទែងគំនិតគ្នាឲ្យបានជាធំដុំ ដល់ទៅពិឃាតគ្នាសោះឡើយ ។

ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ទ្រង់មានសទ្ធាជ្រះថ្លា, ទ្រង់សីលប្រាំបី ទ្រង់មិនសព្វព្រះទ័យឲ្យនិយាយកុហកបញ្ឆោត ដើរបោកប្រាស់គេទេ ។ ទ្រង់មានក្តីស្រឡាញ់ ហើយគោរពព្រះវរមាតាទ្រង់រកអ្វីមកប្រៀបពុំបាន ។

ប្រសិនបើព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ត្រូវការប្រព្រឹត្ត ឬឲ្យគេប្រព្រឹត្តបទឧក្រិដ្ឋ ដូចជាគេបានចោទទ្រង់នោះ ទ្រង់មុខជាមិនប្រគល់ការនេះ ឲ្យទៅគូលីត្រីចក្រយាន (ស៊ីក្លូ) ដែលទ្រង់មិនស្គាល់ មិនទុកព្រះទ័យនោះទេ គួរណាស់តែទ្រង់ចាត់ពួកក្រុមរក្សាព្រះអង្គណាមួយ ដែលទ្រង់បានទុកព្រះទ័យស៊ប់ស្ងួន ដើម្បីកុំឲ្យខូចខ្វាយការសម្ងាត់នេះ ។

ព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ តាមសម្លោកខ្មែរក្ដី, សម្លោកបារាំងក្ដី, មិនមានលក្ខណៈណាមួយដែលបញ្ជាក់អំពីភិនភាគរបស់មនុស្ស ចិត្តសាហាវឃោរឃៅសោះឡើយ ។

ចំណែកទ្រង់ គ្មានព្រះភក្ត្រា (មុខ) ឥលាដរួញ (ថ្ងាស់) ឧណ្ណាលោមក្រួចសើច (ចិញ្ចើម) ។

ឯ. ឧ. អៀវ-កើសក្ដី, ព្រះអង្គម្ចាសសុទ្ធាវង្ស-នរិន្ទតេជក្ដី, អត្តភាពលំនាំស្រដៀងគ្នា មានបុកពាសណ្ដាប់ធ្នាប់ស្លូតបូត ។

ព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ ដែលទ្រង់មានសេចក្ដីស្រឡាញ់និងគោរពកោតខ្លាចព្រះវរមាតាទ្រង់ដូច្នេះ ទ្រង់មិនអាចធ្វើឲ្យប្ដីគេព្រាត់ប្រាស់ប្រពន្ធ, ធ្វើឲ្យឪពុកគេព្រាត់ប្រាស់កូន, ធ្វើឲ្យកូនគេព្រាត់ប្រាស់ឪពុក ។

មនុស្សដែលពិឃាត ឯ. ឧ. អៀវ-កើស ចំជាមនុស្សមានចិត្តឃោរឃៅឥតធម៌សប្បុរស សូម្បីមាតាបិតាខ្លួនក៏គ្មានសេចក្ដីស្រឡាញ់ គឺមនុស្សអកត្តញ្ញូ ។

ព្រះអង្គម្ចាស់ សុទ្ធាវង្ស-នរិន្ទតេជ វិញ បើទុកជាជនណា ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ តែគ្មានសាលក្រមកាត់ទោសជាដាច់ខាតទេ, មុខជាទ្រង់មិនអាចហ៊ានប្រើឲ្យសម្លាប់គេទេ ដូចជាពួក ឯក-សម និងគួកន ជាដើម ។

ឯពួកខាងប្រជាធិបតេយ្យ ដំបូងមានយោបល់មិនស្របគ្នា, បន្ទាប់មកមានយោបល់មិនព្រមព្រៀងគ្នា, ក្រោយបង្អស់កើតបែកសាមគ្គីរវាងគណបក្ស ដូចអស់លោកជ្រាបស្រាប់ ។

នេះជាសេចក្ដីសង្ខេបអំពីនិដ្ឋិតកម្ម ដែលលូតលេចជាក់ស្ដែងឡើង ក្នុងរវាងក្រុម ឯ. ឧ. អៀវ-កើស និងក្រុម ឯ. ឧ. យ៉ែម-សំបូរ ។

## និដ្ឋិតកម្មនិងអាកប្បកិរិយារបស់ ឯ. ឧ. យ៉ែម-សំបូរ

១១- ឯ. ឧ. យ៉ែម-សំបូរ បានពោលពាក្យទ្រគោះបោះបោកទៅលើ ឯ. ឧ. ប៉ែន-នុត ជាទីប្រឹក្សានយោបាយនៃគណបក្សប្រជាធិបតេយ្យ ។

១២- ឯ. ឧ. យ៉ែម-សំបូរ បានបំបែកគណបក្សប្រជាធិបតេយ្យ ។

១៣- ឯ. ឧ. យ៉ែម-សំបូរ បានផ្ដួលរដ្ឋាភិបាលឯ. ឧ. ប៉ែន-នុត ជាគូបរបក្ខរបស់ខ្លួន ។

១៤- ឯ. ឧ. យ៉ែម-សំបូរ បានសុំដកអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រពួកខ្លះនៃគណបក្សប្រជាធិបតេយ្យ ។

១៥- ឯ. ឧ. យ៉ែម-សំបូរ បានសុំអំណាចពេញទី ប៉ុន្តែព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់បដិសេធ ។

១៦- ឯ. ឧ. យ៉ែម-សំបូរ ជាអ្នកផ្ដើមហេតុរំលាយរដ្ឋសភា ។
១៧- ឯ. ឧ. យ៉ែម-សំបូរ ជាអ្នកផ្ដួចផ្ដើមកែប្រែច្បាប់រដ្ឋធម្មនុញ្ញ ។

## និន្ទិតកម្មនិងអាកប្បកិរិយារបស់ ឯ. ឧ. អៀវ-កើស

១១- ឯ. ឧ. អៀវ-កើស បានជំទាស់បណ្ដាលឲ្យ ឯ. ឧ. យ៉ែម-សំបូរ ជ្រើសរដ្ឋមន្ត្រីលើកទី១មិនសំរេច ។

១២- ឯ. ឧ. អៀវ-កើស បានជំទាស់នឹងការចាត់តាំងរដ្ឋាភិបាលយ៉ែម-សំបូរលើកទី២ម្ដងទៀត លុះត្រាតែព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់សំរុះសំរួលទើបឯ. ឧ. យ៉ែម-សំបូរ ចាត់តាំងរដ្ឋាភិបាលបានសំរេច ដោយសារ១០ឆ្នោតខាងពួកប្រជាធិបតេយ្យ ដែលជាអំណោយទាំងបង្ខំរបស់ឯ. ឧ. អៀវ-កើស ថែមទៅលើ២០ឆ្នោត របស់ពួកសមាជិកតំណាងរាស្ត្រសេរីភាព ។

១៣- រដ្ឋសភាអនុម័តដាច់អហង្ការ មិនព្រមឲ្យដកអភ័យឯកសិទ្ធិ របស់សមាជិករដ្ឋសភា តាមសេចក្ដីសុំរបស់លោក ឯ. ឧ. យ៉ែម-សំបូរ ។

១៤- មានតំណាងរាស្ត្រគណបក្សប្រជាធិបតេយ្យ១ក្រុម បានសុំតាំងញត្តិបន្ទោសមួយជូនទៅមន្ទីររដ្ឋសភា ដើម្បីប្ដូររដ្ឋាភិបាលយ៉ែម-សំបូរ ។

១៥- គណៈប្រតិភូប្រជាធិបតេយ្យដែលមានឯ. ឧ. អៀវ-កើសជាដើម ក៏ដូចជាគណៈប្រតិភូសេរីភាព ដែលមានខ្លួនខ្ញុំជាដើម និងគណៈប្រតិភូខេមរប៉ុណ្ណការដែលមានលោកលន់-នល់ជាដើម បានជំទាស់និងការកែប្រែរដ្ឋធម្មនុញ្ញ ។

## និន្ទិកម្ម ដែលគេបានលើកទម្លាក់ដាក់ទម្ងន់ ទៅលើឯ. ឧ. អៀវ-កើស

មានគណៈប្រតិភូនៃពួកនិស្សិតខ្មែរនៅប្រទេសបារាំង បានចូលក្រាបថ្វាយបង្គំគាល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នឹងជំរាបសួរឯ. ឧ. យ៉ែម-សំបូរ ដើម្បីនឹងក្រាបបង្គំទូល សួរអំពីហេតុនៃការរំលាយរដ្ឋសភា ។ ដើម្បីកាត់ឲ្យខ្លី, ឯ. ឧ. យ៉ែម-សំបូរ បានសុំឲ្យគណៈប្រតិភូពួកនិស្សិត ចូលទៅជួបគ្នានៅក្នុងបន្ទប់របស់លោក ព្រោះថាក្រោយដែលបានជជែកតវ៉ាគ្នាយ៉ាងខ្លាំង ដល់ទៅជាបប្លុលដាល់គ្នាតាមរីធីខ្មែរ ។

## និន្ទិកម្មដែលបានលើកទម្លាក់ដាក់ទម្ងន់ទៅលើនាងអៀវ-បណ្ណការ និងអៀវ-វុឌ្ឍិការជាបុត្រឯ. ឧ. អៀវ-កើស នៅគ្រាដែលឯ. ឧ. អ៊ុន-នៅ ដោយមិនទាន់ត្រឡប់ពីប្រទេសបារាំង

ដោយហេតុការណ៍ផ្សេងៗរបស់ពួកកូនសិស្សនៅក្រុងភ្នំពេញ ដែលនាំគ្នាធ្វើបាតុកម្មយ៉ាងស្ងប់ស្ងាត់តាមផ្លូវទាំងឡាយក្នុងក្រុង ។ ការធ្វើបាតុកម្មនេះបានបណ្ដាលឲ្យមានការទាស់ទែងគ្នាយ៉ាងខ្លាំង ដល់ទៅកើតប្រទូស្តរ៉ាយគ្នា មកតែអំពីការមិនប៉ិនប្រសប់នៃក្រុមព្រះនគរបាលក្រុង ។

# កាត់ចោលដោយមិនបានថ្លែង
# បរិយាយចំពោះតុលាការ

សូមជំរាបតុលាការ

ឥឡូវនេះ ខ្ញុំនឹងសារស័ព្ទដល់ត្រង់កន្លែងដែលគួរឈឺចាប់ដូចតទៅនេះ ៖

កាលពីថ្ងៃសៅរ៍ទី១៨ មករា ១៩៥០ ជាកាលបរិច្ឆេទដែលគួរចាំទុកនូវប្រវត្តិនៃលទ្ធិយុវប្រជាធិបតេយ្យខ្មែរ ពួកសមាជិកប្រជាធិបតេយ្យ បានទៅជំនុំគ្នានៅទីដំណាក់ការលេខ៦៦ វិថីពិកេត៍ ដើម្បីសន្ទនាប្រាស្រ័យជាមួយនឹងពួកប្រតិភូ ដែលទៅជំនុំកែប្រែច្បាប់រដ្ឋធម្មនុញ្ញ ហើយនិងកំណត់កាលបរិច្ឆេទ និងទីកន្លែងធ្វើសន្និសិទរបស់ឯ. ឧ. អៀវ-កើស អំពីរឿងធ្វើដំណើរទៅកាន់ទ្វីបអឺរ៉ុប ។

កាលជំនុំគ្នានៅពេលម៉ោង១៩ ប៉ុន្តែដោយហេតុមានមង្គលការនៅទីក្រុង ទើបតែប្រែកំណត់នេះទៅវិញ (ប្រហែលជាពួកភេរវជននិងក្រុមធ្វើឃាតកម្មមិនបានដឹង) ត្រូវបន្ថយកែប្រែពេលជំនុំជាថ្មី កំណត់ម៉ោង១៧ មិនមែនម៉ោង១៩តាមកំណត់ដើម ។

កាលបើកឱកាសប្រជុំឡើង ឯ. ឧ. អៀវ-កើសបានប្រាប់លោក អ៊ឹម-ផុន អតីតតំណាងរាស្ត្រខាងគណបក្សប្រជាធិបតេយ្យឲ្យអានញត្តិរបស់គណៈសេរីភាពនៅពេលនេះ លោកធ្វើជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ។

ខ្ញុំមានសេចក្ដីត្រេកអរណាស់ ប៉ុន្តែមិនមែនមកអំពីកិច្ចការស្នាដៃរបស់ខ្ញុំទេ គឺជាការបញ្ជាក់ឲ្យឃើញថា គណបក្សប្រជាធិបតេយ្យនិងគណៈរាស្ត្រសេរីភាព មិនមែនប្រព្រឹត្តដូចសត្វឆ្កែនិងឆ្មា ដូចជាគេគិតស្មានមកនោះទេ ។

លុះជំនុំរួចស្រេចហើយ ពួកសមាជិកនាំគ្នាចេញទៅអស់ហើយ, ពេលនោះស្រាប់តែលេចលោកង៉ែត-ហ៊ាន អតីតតំណាងរាស្ត្រចូលទៅជួបឯ. ឧ. អៀវ-កើស ជាពិសេស ។

ឯ. ឧ. អៀវ-កើស ក៏ត្រឡប់ចូលទៅមន្ទីរជំនុំវិញ ហើយបានសន្ទនាជាមួយនឹងលោកង៉ែត-ហ៊ាន និងឯ. ឧ. ហាក់-ម៉ុងសេង ៗបានចេញទៅមុនមួយស្របក់ ។

ស្រាប់តែលោកទាំងពីរនៅក្នុងបន្ទប់ បានឮវត្ថុអ្វីមួយរមៀលមកលើកម្រាលឥដ្ឋជិតជើងលោក ។

លោកង៉ែត-ហ៊ាន ថាឃើគេចោលដបអី ? ក៏បានស្ទុះចេញទៅមើលតាមបង្អួច លោកបានឃើញមនុស្សពីរនាក់រត់ចេញទៅ ម្នាក់ស្លៀកខ្មៅទាំងអស់ ម្នាក់ទៀតស្លៀវអាវកាគី ។

ឯ. ឧ. អៀវ-កើសអង្គុយនៅហ្នឹងកន្លែង ថាកូនក្មេងចោលអី ក៏ភើចកំរាលតុក៏ឈ្ងោកមើលទៅក្រោម ស្រាប់តែគ្រាប់បែកផ្ទុះឡើងត្រូវខ្លួនលោក ។

លោកង៉ែត-ហ៊ាន ដែលនៅជិតបង្អួចចម្ងាយពីរម៉ែត្រពីគ្រាប់បែកផ្ទុះ ក៏ត្រូវជើងម្ខាងបាក់ទៅ (ពិការជានិច្ច) ។

គេនិយាយថា កុំតែលោកង៉ែត-ហ៊ានឃើតយូរ នាំឲ្យឯ. ឧ. អៀវ-កើស បង្អែបង្អង់ទាល់តែពេលម៉ោងជីវិតអន្តរាយ កុំអីឯ. ឧ. អៀវ-កើស គ្មានគ្រោះថ្នាក់ដល់មរណៈសោះ ។ ព្រោះហេតុនេះហើយបានជាគេបង្គាប់ឲ្យឆែករុករឹភ្លាម នៅផ្ទះលោកង៉ែត-ហ៊ាន ។

ចំណែកខាងខ្លួនខ្ញុំយល់ថា ៖ ប្រសិនបើមិនផ្លាស់កំណត់ពេលប្រជុំទេ ឬប្រសិនបើពួកភេរវជនបានដឹងមុននូវការកែប្រែពេលម៉ោង នោះពួកសមាជិកទាំងអម្បាលមាណនៃគណបក្សប្រជាធិបតេយ្យ ឬចំនួនច្រើនដែលជំនុំការជាមួយគ្នាមុខជាបានទទួលគ្រោះថ្នាក់ ដូចជាឯ. ឧ. អៀវ-កើស និងង៉ែត-ហ៊ាន ជាមិនខាន ។

ក្រុមធ្វើឃាតកម្មនេះ មិនមែនព្យាយាមចង់សម្លាប់តែ ឯ. ឧ. អៀវ-កើស ប៉ុណ្ណោះទេ (បើគេចង់សម្លាប់តែខ្លួនលោកមួយ មុខជាគេទៅចោលគ្រាប់បែកនៅមន្ទីរផ្ទះលោក ឬក្នុងរថរបស់លោក) គឺថាគេប៉ងសម្លាប់ពួកប្រជាធិបតេយ្យណាដែលមិនមែនជាពួកបែកចេញទៅហើយបានទៅជួបជុំគ្នាក្នុងថ្ងៃទី១៤ មករា ១៩៥០

❑

❑ ❑

# ចាប់បានអ្នកធ្វើឃាតកម្មម្នាក់

ឥឡូវសូមនិយាយពីមនុស្សធ្វើឃាតកម្មពីរនាក់ ដែលលោកង៉ែត-ហ៊ានបានឃើញវានៅអង្គុយលើចិញ្ចើមថ្នល់ម្ខាង ក្នុងពេលដែលលោកចូលទៅដល់ ហើយបានឃើញវាម្តងទៀតតាមចន្លោះបង្អួច នៅពេលដែលគ្រាប់បែកផ្ទុះឡើង ។

ចុះជនពីរនាក់នោះ ជនណាមួយដែលជាអ្នកចោលគ្រាប់បែក ?

តាមលោក តាន់-គឹមតិក នាយក្រុមនគរបាលជាតិ ថាមិនបានដឹងប្រាកដជាឈ្មោះណាមួយទេ ដែលជាអ្នកចោលគ្រាប់បែក (សេចក្តីរាយការណ៍លេខ ១៧ P.S. ចុះថ្ងៃទី១៤-១-៥០) (លេខសំណុំរឿង៨៦) ។

ក្នុងមនុស្សពីរនាក់នោះ មានមនុស្សម្នាក់ស្លៀកពាក់ខ្មៅពាក់អាវកាគីដែលបាត់

ខ្លួននោះ ប្រហែលជាដើរកាត់សួនផ្កាតាមផ្លូវពិកេត៍ និងផ្លូវដឺវែរណឺរិល ហើយគេចបាត់ទៅ ដោយឥតគេមានយកចិត្តទុកដាក់សោះ ។ ប្រហែលជាវា និងគូកនវាពនាក់ទៀត ដើរសំដៅទៅរករថយន្តម៉ាកដូត ដែលចតនៅផ្លូវដឺវែរឈឺរិក ខាង-មុខសាលានរោត្តម ខណៈនេះទ្វារសាលាបិទហើយ ។

ម្នាក់ទៀតដែលស្លៀកពាក់ខ្មៅមានបេរេខ្មៅ រត់ចេញពីទីនោះពេញទំហឹងជើងចេញពីផ្លូវពិកេត៍ ហើយទៅតាមផ្លូវបីយោត៍ រួចរត់កាត់រុក្ខវិថីប៉ូលូសហ្គូសរថយន្តម៉ាកស៊ីត្រូអែន១១សេះ ដែលនៅចតមុខរោងកាហ្វេ ភោជនិយដ្ឋានឃីហោ ដុង-គិញពេលនោះបិទទ្វារ ។ រួចវារត់កាត់ចន្លោះផ្លូវ ហើយរត់កាត់រុក្ខវិថីប៉ូលូស ចូលទៅផ្លូវដុកទ័រកាលម៉ែត ។

ខ្ញុំមិនយល់ថាហេតុដូចម្ដេច តាមធម្មតាប៉ូលិសក្រុមព្រះនគរបាលជាតិ និងប៉ូលិសក្រុងយាមនៅមុខដំណាក់ការប្រជាធិបតេយ្យច្រើនពន់ពេក ហើយនៅថ្ងៃជំនុំនោះ គ្មានប៉ូលិសណាមួយសោះ ។

ពុថាតាំងពី៦. ៥. អៀវ-កើសអញ្ជើញមកពីប្រទេសបារាំងថ្ងៃណា មានក្រុមសម្ងាត់ព្រះនគរបាលជាតិតាមប្រកិតជានិច្ច ។

ថៅកែ លឹម-ឆៃហ៊ាន ផ្ទះលេខ៧១ ផ្លូវពិកេត៍ បានឃើញមនុស្សម្នាក់រត់ ក្រោយដែលបានពុស្ទូរផ្ទះ ក៏ស្រែកឡើងថា «ចាប់, ចាប់» ។

ថៅកែ តាន់-គីស៊ុត ផ្ទះលេខ៧៥ ផ្លូវដដែលមិនបានពុស្ទូរផ្ទះ ក៏នឹកស្មានថាជាចោរឆក់ឥវ៉ាន់ក៏រត់ចុះពីលើឡៅមកយ៉ាងប្រញាប់ ក៏ចាប់ទោចក្រយានយន្តជិះដេញតាមមនុស្ស ដែលរត់ទៅឆ្ងាយហើយ ។ ដល់ទៅផ្លូវបំបែក ក៏បានជួបនឹងទាហានជើងទឹកបារាំងម្នាក់ឈ្មោះ ម៉ារគ័រ-ណូឯល-ហ្វ្រង់ស្វា (Margueur Noël-François) ដែលដើរមកពីផ្លូវប៉ាស្ទ័រ ។ ទាហាននោះចង្អុលប្រាប់ទិស ដែលមនុស្សរត់ទៅនោះ ថៅកែតាន់-គីស៊ុត ឲ្យទាហានបារាំងនោះឡើងជិះទោចក្រយានយន្តពីខាងក្រោយខ្លួន ។

មនុស្សរត់នោះ បានរត់កាត់ផ្លូវម៉ូរិស្សឡង ហើយរត់ចូលទៅក្នុងច្រកផ្ទះ១ (ឡឿងហែម) ។ អ្នកជិះទោចក្រយានយន្តក៏ឈប់ ទាហានក៏ចុះមកដីដេញតាមមនុ-ស្សរត់ ។ នៅពេលនោះអ្នកជិះទោចក្រយានយន្ត ទៅតាមផ្លូវកាពិតេន ដេមូឡាំង ផ្លូវដូ ហឺវឃី ជាទីដែលចាប់មនុស្សរត់បាន គឺបានដល់ទៅពេលដែលទាហានយកដៃសង្កត់ស្មាមនុស្សអ្នករត់ឡើងជិះស៊ីក្លូ ទាំងហត់ដង្ហក់ ហើយស៊ីក្លូជិតចេញទៅផង ។

ក្នុងខណៈនោះ មានមនុស្សជិះទោចក្រយានម្នាក់ ដែលគេមិនស្គាល់ឈ្មោះចូលមកជិតស៊ីក្លូ តាំងច្រត់ដៃលើស៊ីក្លូនោះ ។ ថៅកែតាន់-គីស៊ុតបានសួរអ្នកនោះថា

«អ្នកឯងជាគិញឬអ្វី ?»...ឆ្លើយថាទេ ប្រសិនជាថា «មែន» ថៅកែតាន់-គីស៊ុតប្រហែលជាប្រគល់មនុស្សដែលចាប់បាននោះឲ្យ ហើយប្រហែលជាមនុស្សដែលចាប់បាននោះ មិននៅក្នុងគុកដូចសព្វថ្ងៃនេះទេ ។

កុំតែមានសាក្សីពនាក់ ដែលទេវតាប្រទានឲ្យមក គឺថៅកែ លឹម-ឆៃ, ថៅកែតាន់-គីស៊ុត និងម៉ារត៍-ណូឯល ហ្វ្រង់ស្វា នោះអ្នករត់នោះប្រហែលជារត់រួចបាត់ទៅហើយ ដូចជាពួកគូកនរបស់ខ្លួន ។

## អំពីការពិនិត្យ និង ដឹកនាំអ្នកត្រូវរបួស

លោកង៉ែត-ហ៊ាន ឡើងជិះសីក្លូទៅមន្ទីរពេទ្យព្រះកេតុមាលាខ្លួនឯង ។

ឯ. ឧ. អៀវ-កើស ដែលត្រូវរបួសជាទម្ងន់ គេលើកដាក់ឲ្យដេកផ្ងាចង្រ្កាង លើចិញ្ចើមថ្នល់ផ្ទាល់នឹងដី នៅខាងមុខសំណាក់ប្រជាធិបតេយ្យ ។

លោកសេង-ទីប កុម្មិស្ស៊ែរទី២ ក៏បានមកជាមួយនឹងប៉ូលិស ។

របៀបពិនិត្យរបួសរបស់លោកសេង-ទីប ដូចមានខាងក្រោមនេះ ៖

លោកសេង-ទីបមិនចូលទៅក្នុងមន្ទីរសំណាក់ការផង, ពេលនោះលោកសេងទីបឈរយកដៃច្រត់ចង្កេះសម្លឹងមើលឯ. ឧ. អៀវ-កើស ដែលដេកស្តូកស្តឹងឥតវិញ្ញាណហើយនិយាយថា ៖

«អីនេះ ?» ហាក់ដូចជាមិនស្គាល់អ្នករងគ្រោះសោះ ក្នុងចំណោមនោះមានម្នាក់ឆ្លើយតបថា «ដូចលោកបានឃើញស្រាប់ !» ។

មានជនម្នាក់និយាយសុំលោកសេង-ទីប ដឹកយកឯ. ឧ. អៀវ-កើស ក្នុងរថយន្តផ្ទាល់ខ្លួនលោកទៅមន្ទីរពេទ្យ ។

លោកសេង-ទីបបដិសេធមិនព្រមដឹកតាមសុំ ហើយនិយាយថា មិនបានទេ «ប្រឡាក់រទេះឡានរបស់ខ្ញុំ» ។

ឱព្រះម្ចាស់ថ្លៃអើយ ! កុម្មិស្ស៊ែរប៉ូលិស ជាសិស្សចាស់នៃសាលាហាត់ប្រាណជាន់ខ្ពស់ ផាំងផៀក បដិសេធមិនទទួលយកអាសារជួយអ្នកត្រូវរបួសធ្ងន់ដល់ម្លោះ

ខ្ញុំសូមអនុញ្ញាតនិយាយជាសាធារណ:ទូទៅក្នុងទីនេះ ជាតំណាងតាងនាមនៃក្រុមគ្រួសាររបស់ឯ. ឧ. អៀវ-កើស ថា ៖

សូមអរគុណជាពន្លឹក ចំពោះលោក មេសារ (Méchard) និងលោកអនុសេនិយឯក ឡឺសាស (Lesage) ដោយបានទទួលដឹកយកឯ. ឧ. អៀវ-កើស ដែលមានរបួសធ្ងន់ ដាក់ក្នុងរថយន្ត ហ្ស៊ីប ទៅមន្ទីរពេទ្យដោយឥតមានអង្វរសុំ ។

ឥឡូវខ្ញុំសូមនិយាយបកទៅមន្ទីរកុម្មិស្ស៊ែរផ្នែកទី៧វិញ ។

- ឃើញមាន លោកសេង-ទីប ជាកុម្មិស្ស៊ែរផ្នែកទី២ ។

- លោកតាន់-កែមឡុង ជាភូឈ្លួយកុម្មិស្សែរផ្នែកទី២ ។
- លោកជា-ឡុង ជាអ្នកត្រួតរង កុម្មិស្សែរផ្នែកទី២ ។
- លោកតាន់-គឹមតិក ជានាយក្រុមព្រះនគរបាលជាតិ ។
- លោកអ៊ុក-ស៊ុន ជានាយក្រុមប៉ូលិសពិសេស ។
- លោក ពូសូល (Pujol) ជានាយក្រុមក្រសួងសម្ងាត់នៃហ្វត៍កុម្មិស្សារិយារបស់សាធារណរដ្ឋបារាំង ។

ការដែលចាប់មនុស្សរត់នោះបានមកហើយ ទុកចោលនៅថ្នាក់ក្រោមជាច្រើនម៉ោង មានមនុស្សជាច្រើនរយនាក់កកកុញនៅលើចិញ្ចើមផ្លូវថ្នល់ និងជុំវិញមន្ទីរកុម្មិស្សារិយាដើម្បីចាំស្ដាប់ ហើយពាំនាំដំណឹងយកទៅផ្សាយ ។

តាមធម្មតា តែកាលណាគេចាប់មនុស្សត្រូវចោទ មកដល់មន្ទីរកុម្មិស្សែរ គេសួរយកចម្លើយភ្លាមៗ ចុះហេតុអ្វីបានជាក្នុងរឿងធំសំបើមយ៉ាងហ្នឹងដូចជាគេទីទេ មិនហ៊ានសួរយកចម្លើយមនុស្សត្រូវចោទភ្លាមវិញ ។

ដែលចាប់បាននោះ គេទុកចោលប្រហែលជា២ម៉ោង ទើបបាននាំមនុស្សរត់ដែលគេចាប់បាន ឡើងទៅថ្នាក់លើ ។

ចុះយកឡើងទៅធ្វើអ្វី ?

ចុះមនុស្សរត់នោះ គេបានសួរចម្លើយ ក្នុងយប់ថ្ងៃសៅរ៍ ១៤-១-៥០ ដែរឬ ? គ្មានសេចក្ដីកត់ហេតុយកចម្លើយ ។

ចុះក្នុងព្រឹកថ្ងៃអាទិត្យ គេបានសួរយកចម្លើយដែរឬ ? ក៏គ្មានសេចក្ដីកត់ហេតុយកចម្លើយ ។

## អំពើឃាតកម្ម ង. ខ្វ. អៀវ-កើស និងចំណាចផ្ញើយឃាតកម្មលោកង៉ែត-ហ៊ាន

ចម្លើយសាក្សីរបស់លោក តាន់-គីស៊ុត, លោក ម៉ារគ័រ (ណូឯល-ហ្វ្រង់ស្វា) លោកង៉ែត-ហ៊ាន

តាមចៅកែតាន់-គីស៊ុត, លោកម៉ាគ័រ-ណូឯល-ហ្វ្រង់ស្វា និងលោកង៉ែត-ហ៊ានថា ៖ នូ-យ៉ា ពិតជាមនុស្សដែលរត់ក្រោយគ្រាប់បែកផ្ទុះឡើង ហើយគេដេញចាប់បានក្នុងពេលដែលវាឡើងជិះស៊ីក្លូ កំពុងហាត់ដង្ហក់ ស៊ីក្លូប្រុងនឹងបរចេញទៅ

### ចម្លើយសាក្សី លោកតាន់កែមឡុង

លោកតាន់-កែមឡុង ជាភូឈ្លួយកុម្មិស្សែរផ្នែកទី២ បានឆ្លើយនៅថ្ងៃទី៦-៧-៥០ដូច្នេះ ៖

ថាលោកសេង-ទីប បានសួរយកចម្លើយឈ្មោះនូ-យ៉ា ជាមួយនិងលោកជា-ឡុង ជាអ្នកត្រួតរងក្រុមប៉ូលិសក្រុង ជាទីលេខានុកា (សេចក្ដីកត់ហេតុចុះថ្ងៃអាទិ-

ត្យ ១៥-១-៥០ ម៉ោង១៥និង៣០នាទី) ។

ថាក្រោយដែលបានអានសេចក្តីកត់ហេតុនោះហើយ ទើបលោកសេង-ទឹប, ជា-ឡុង និងមនុស្សត្រូវចោទបានចុះហត្ថលេខា លើសេចក្តីកត់ហេតុសួរយកចម្លើយនោះ ។

ធម្មតាយើងដឹងថា ៖ សេចក្តីកត់ហេតុ ដែលលោកតាន់-កែមឡុង បានធ្វើរួចជាស្រេចហើយនោះ ជួនកាលលោកតាន់-កែមឡុង បានចុះហត្ថលេខាដោយខ្លួនឯង ជួនកាលទុកឲ្យលោកសេង-ទឹប ចុះហត្ថលេខា ដោយលោកសេង-ទឹបមិនប្រសប់ការ ។

តែលោកតាន់-កែមឡុងថា ដោយសាររឿងនេះជារឿងធំ បានជាលោកទុកឲ្យលោកសេង-ទឹបចុះហត្ថលេខា មិនបានដឹងថាលោកសេង-ទឹប បានធ្វើសេចក្តីកត់ហេតុឡើងវិញជាថ្មី នោះគឺដើម្បីដោះសារការពារចៅហ្វាយនាយរបស់ខ្លួនទេ ។

ថាដល់ហួសម៉ោង១៨ទៅ ទើបគេត្រៀមនាំខ្លួននូ-យ៉ា ដែលត្រូវចោទទៅប្រគល់ឲ្យទៅក្រុមព្រះនគរបាលជាតិ ។

ថាឈ្មោះនូ-យ៉ាបានឆ្លើយយ៉ាងរួសរាន់ ឥតបង្វែ, ឥតបញ្ចេះ ពីព្រោះវាបាននិយាយថា «កុំបាច់ធ្វើទុក្ខបុកម្នេញដល់ខ្លួនខ្ញុំ ៗនឹងនិយាយតាមការពិតទាំងអស់» ។

កាលដែលលោកចាងហ្វាងសាលាឧទ្ធរណ៍ ជាអ្នកស៊ើបសួរ បានអានសេចក្តីតត់ហេតុ ដែលនូ-យ៉ាបានឆ្លើយថា ខ្លួនវាបានបោះគ្រាប់បែក ឈ្មោះសៀងចាំមើលផ្លូវ ។ លោកតាន់-កែមឡុង បានសុំមើលសេចក្តីកត់ហេតុនោះ លោកបានប្រែត្រឡប់សេចក្តីកត់ហេតុចុះឡើងច្រើនលើក បែបឆ្ងល់គ្រវីក្បាល ហើយមានប្រសាសន៍ថា ក្នុងរឿងនេះ ត្រូវសួរលោកជា-ឡុង ដើម្បីឲ្យបានច្បាស់ប្រាកដ ។

ដោយខ្ញុំសុំឲ្យសួរ លោកតាន់-កែមឡុង ឲ្យការណ៍ថា ៖ នូ-យ៉ាឆ្លើយថា ពួកខ្លួន៥នាក់ ម្នាក់អ្នកបោះគ្រាប់បែក, ខ្លួនជាអ្នកចាំផ្លូវនៅលើចិញ្ចើមថ្នល់ម្ខាង, បីនាក់នៅក្នុងសួនច្បារ (ផ្កា) ។

ថាកាលខ្លួនស្តាប់សួរចម្លើយ មិនបានឮនូ-យ៉ាឆ្លើយដាក់ ចៅ-ស៊ុន និងព្រះអង្គម្ចាស់សុទ្ធារង្ស-ធិរិទ្ធតេជទេ ។

លោកអ៊ឹម-ផុន ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានសុំឲ្យសួរលោកតាន់-កែមឡុងថា «ចុះនូ-យ៉ាបានឆ្លើយដាក់ដល់ឈ្មោះលោកអ្នកធំណាមួយឬទេ ? ពី-ព្រោះនូ-យ៉ា គ្មានប្រយោជន៍ផ្ទាល់ខ្លួនក្នុងរឿងនេះ ។ នោះលោកតាន់-កែមឡុងឆ្លើយថាទេ ។

## ចម្លើយសាក្សីរបស់លោកសេង-ទឹប

លោក សេង-ទឹប ជាកុម្មិស្ស៊ែរផ្នែកទី២ បានឆ្លើយនៅថ្ងៃទី៦-៧-៥០ ៖

ថាលោកតាន់-កែមឡុង បានសួរយកចម្លើយមុនលោក ក្នុងពេលដែលលោកមិននៅ ហើយគ្មានបង្គាប់ពីលោកផង ហេតុដូច្នោះហើយបានជាលោកសើរើធ្វើឡើងវិញទាំងអស់ ពីព្រោះលោកជានាយក ។

ថាខ្លួនលោកមិនបានអានសេចក្ដីកត់ហេតុ សួរយកចម្លើយរបស់លោកតាន់-កែមឡុងធ្វើទេ ។

ថាលោកភ្លេចសេចក្ដីកត់ហេតុនោះ លោកនឹកមិនឃើញទេ បានទុកដាក់នៅកន្លែងណា ដាក់ក្រោមប៊ុយរូលោក ឬដាក់ក្នុងហោប៉ៅអាវលោក ។

ថាលោកតាន់-កែមឡុង មិនបានស្ដាប់ការសួរយកចម្លើយមនុស្សត្រូវចោទដែលលោកបានធ្វើជាមួយនឹងលោកតាន់-គឹមតិក ជានាយក្រុមព្រះនគរបាលជាតិទេ ។

ចុះលោកតាន់-គឹមតិក មកធ្វើអ្វីនៅទីនោះ ?

ដោយមានបង្គាប់ពីអ្នកណា ?

ចុះមានច្បាប់អ្វីដែលតម្រូវ ឲ្យលោកជាមេក្រុមព្រះនគរបាលជាតិ មកមន្ទីរកុម្មីស្សែរផ្នែកទី២ ដើម្បីសួរយកចម្លើយអំពីឈ្មោះនូ-យ៉ា ?

គឺមានតែលោកកុម្មិស្សែរធំទេ ដែលជានាយក្រុមប៉ូលិសក្រុង មិនមែនលោកនាយក្រុមព្រះនគរបាលជាតិទេ ។

តាមខដែលខ្ញុំសុំឲ្យសួរនោះ លោកសេង-ទឹបឆ្លើយថា លោកធ្វើសេចក្ដីកត់ហេតុចុះថ្ងៃទី១៥-១-៥០វិញ ពីម៉ោង២០ ដល់ម៉ោង២៤ ។

ថាលោកមិនបានសួរចម្លើយនូ-យ៉ា នៅថ្ងៃទី១៤-១-៥០ទេ ដោយជាប់រវល់ធ្វើអង្កេត-ពិនិត្យ ។

ថាមិនបានចាំ ថានៅពេលយប់នោះ លោកបានទៅផ្ទះឯ. ឧ. យ៉ែម-សំបូរ ដែរឬទេ ដូចជាមិនបានទៅទេ ។

តាមខដែលខ្ញុំសុំឲ្យសួរថា «ឈ្មោះនូ-យ៉ាបានឆ្លើយដាក់ឈ្មោះ ចៅ-ស៊ុន, ឃួន-លុត និងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ មែនឬទេ ?

លោកសេង-ទឹបឆ្លើយថា ឲ្យមើលសេចក្ដីកត់ហេតុ ។

តាមខដែលខ្ញុំសុំឲ្យសួរថា «ឯ. ឧ. យ៉ែម-សំបូរ បានអញ្ជើញទៅមន្ទីរកុម្មិស្សែរផ្នែកទី២ ក្នុងយប់ថ្ងៃទី១៤-១-៥០ឬទេ ? លោកអ្នកស៊ើបសួរមិនព្រមអនុញ្ញាតឲ្យឆ្លើយ ។

## ចម្លើយសាក្សីរបស់លោក ជា-ឡុង

ស. ឆ. លោកតាន់-កែមឡុង បានសួរចម្លើយរួចហើយ ក៏ជូនសេចក្ដីកត់ហេតុនោះទៅលោកសេង-ទឹប ៗមិនចុះហត្ថលេខាលោកនៅតែស្ងៀម គ្មានធ្វើអ្វីអស់វេ

លាមួយម៉ោងកន្លះ ។

ស. ឆ. ក្នុងពេលដែលលោកតាន់-កែមឡុង ឬលោកសេង-ទឹប សួរយកចម្លើយនោះ តើមានការបង្ខិតបង្ខំអ្វីទេ ។

ស. ឆ. សេចក្តីកត់ហេតុ ដែលលោកសេង-ទឹប មិនព្រមចុះហត្ថលេខានោះ លោកទុកនៅដៃរបស់ខ្លួនលោក ។

ស. ឆ. នូ-យ៉ា បានឆ្លើយដាក់អ្នកសមគំនិតគប់គិតគ្នា៨នាក់ ដែលមិនចាំឈ្មោះ

ខ្ញុំបាទសុំឲ្យសួរលោកជា-ឡុងថា «កាលដែលលោកតាន់-កែមឡុង សួរចម្លើយឈ្មោះ នូ-យ៉ា ៗបានឆ្លើយបានឆ្លើយដាក់ឈ្មោះ ចៅ-ស៊ុន, ឃួន-លុត និងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជឬទេ ? នោះលោកជា-ឡុងឆ្លើយថា ឈ្មោះ នូ-យ៉ា មិនបានឆ្លើយដាក់ឈ្មោះ ចៅ-ស៊ុន, ឃួន-លុត និងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជទេ ។

តាមខដែលខ្ញុំសុំឲ្យសួរថា «ចុះហេតុអ្វីបានជាឈ្មោះ នូ-យ៉ា ឆ្លើយដាក់ដូច្នោះ នៅពេលដែលលោក សេង-ទឹប សួរយកចម្លើយ ?» ។

លោកជា-ឡុងបានឆ្លើយថា លោកសេង-ទឹបបានប្រាប់វាឲ្យនិយាយតាមត្រង់

បើដូច្នេះ កាលលោកតាន់-កែមឡុងសួរចម្លើយឈ្មោះនូ-យ៉ា នោះលោកមិនបានប្រាប់ថាឲ្យនិយាយតាមការពិតឬអ្វី ?

ស. ឆ. លោកនាយក្រុមព្រះនគរបាលជាតិ ក៏បានសួរយកចម្លើយដែរ ។

## ចម្លើយតទល់គ្នា

លោកជា-ឡុងថាលោកតាន់-កែមឡុង បានប្រគល់រឿងឲ្យទៅលោកសេង-ទឹប ៗអង្គុយនៅក្នុងប៉ុយរូឥតបានចេញទៅណាទេ បានដកចម្លើយ នូ-យ៉ា ចេញមក ។

លោកសេង-ទឹប ថាមិនមែនទេ ខ្ញុំបានចេញទៅក្រៅ ។

លោកតាន់-កែមឡុង ថាដូចចម្លើយរបស់លោកសេង-ទឹប ។

លោកជា-ឡុង ថាដូចចម្លើយគេដែរ ។

តាមខដែលខ្ញុំសុំសួរ «ដោយសេចក្តីកត់ហេតុដែលនៅក្នុងសំណុំរឿង ជាសេចក្តីកត់ហេតុដែលលោកសេង-ទឹបបានធ្វើជាថ្មីឡើងវិញ ឯសេចក្តីកត់ហេតុដែលលោកធ្វើទាំងមូលនោះច្រឡំបាត់ទៅហើយ, តើនូ-យ៉ា កាលណោះបានឆ្លើយដាក់ឈ្មោះ ចៅ-ស៊ុន, ឃួន-លុត និងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជដែរឬទេ ?

នោះលោកតាន់-កែមឡុងឆ្លើយថា នូ-យ៉ា ពុំបានឆ្លើយដាក់ទេ ។

## ចម្លើយរបស់ នូ-យ៉ា

តាមលិខិតស៊ើបសួរក្នុងសំណុំរឿង ឃើញថាសេចក្តីកត់ហេតុ ធ្វើនៅថ្ងៃអាទិត្យទី១៥-១-៥០ ម៉ោង១៥ និង៣០នាទី ជាសេចក្តីកត់ហេតុយកចម្លើយ នូ-យ៉ា លើកទី១ ដែលថានូ-យ៉ា ឆ្លើយទទួលសារភាពអំពីបទល្មើសចោទលើខ្លួន ហើយឆ្លើយដាក់ឈ្មោះសៀង ជាគូដៃដែលជាមួយគ្នា និងឈ្មោះរុន, ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ។

នៅមន្ទីរស៊ើបសួរ ថ្ងៃទី១៦-១-៥០ នូ-យ៉ានៅតែឆ្លើយទទួលសារភាព ហើយឆ្លើយដាក់ឈ្មោះនាងថែមទៀត ។

នៅមន្ទីរក្រុមព្រះនគរបាលជាតិ ថ្ងៃទី១៩-១-៥០ នូ-យ៉ាឆ្លើយដាក់ឈ្មោះសួន, ឃួន, លុត, អ៊ុំមុំ, អ៊ុក-សាយ, អ៊ុំយូវ, មៀច-ឆែម និងហ៊ាន-ច្រិច ។

ខ១- ដែលលោកង៉េត-ហ៊ាន ឃើញនូ-យ៉ាអង្គុយជាមួយនិងគូកនម្នាក់ លើចិញ្ចើមផ្លូវម្ខាងខាងមុខសំណាក់ការគណបក្សប្រជាធិបតេយ្យ មុនពេលដែលកើតបទឧក្រិដ្ឋឡើងក្តី ។

ខ២- ដែលលោកង៉េត-ហ៊ាន និងថៅកែលឹម-ឆៃហ៊ាន បានឃើញនូ-យ៉ា រត់ក្រោយពេលដែលគ្រាប់បែកផ្ទុះឡើងក្តី ។

ខ៣- ដែលនូ-យ៉ា រត់អស់ទំហឹងជើងមិនឈប់ទៅតាមផ្លូវពិកេត៍, ផ្លូវប៊ិយោត៍ រុក្ខវិថីប៉ូលូស និងរុក្ខវិថីប៉ូលលូស ផ្លូវដុកទ័រកាលម៉េត ផ្លូវម៉ូរិស្សឡុង ចូលទៅច្រកផ្ទះ មានទាំងថៅកែតាន់-គីស៊ុត និងលោកម៉ារគ័រ (Margueur) ដេញតាមប្រកិតហើយចាប់បាន ក្នុងផ្លូវដូ-ហីវ-ឃី នៅពេលដែលឈ្មោះនេះឡើងអង្គុយលើត្រីចក្រយាន (ស៊ីក្លូ) កំពុងហាត់ដង្ហក់ក្តី ។

ខ៤- ដែលនូ-យ៉ាមិនមានប្រកែក នៅទីដែលគេចាប់បានខ្លួនក្តី នៅពេលដែលគេនាំខ្លួនទៅដល់មន្ទីរកុម្មិស្សារិយ៉ាក្តី ។

ខ៥- ដែលឈ្មោះនូ-យ៉ា ឆ្លើយទទួលពីបទដែលគេចោទលើខ្លួន នៅចំពោះមុខលោកតាន់-កែមឡុងក្តី (សេចក្តីកត់ហេតុដែលបាត់) នៅចំពោះមុខលោកសេង-ទឹប និងលោកតាន់-គឹមតិកក្តី (សេចក្តីកត់ហេតុដែលធ្វើឡើងវិញ) និងនៅចំពោះមន្ទីរចារបុរស ទុកជាមានភស្តុតាងពេញបរិបូណ៌លើរូបវា នោះស្រេចនៅលើខ្លួននូ-យ៉ាចុះ ។

ឯចម្លើយរបស់នូ-យ៉ា ដែលឆ្លើយដាក់ចៅ-ស៊ុន, ឃួន-លុត និងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ក្នុងសេចក្តីកត់ហេតុដែលធ្វើឡើងវិញ ចម្លើយនេះមិនមែនជាចម្លើយចេញពីចិត្តគំនិតនាំឲ្យមានមន្ទិលសង្ស័យ ។

ក) ពីព្រោះសេចក្តីកត់ហេតុចុះថ្ងៃទី១៤-១-៥០គ្មាន ឯចម្លើយរបស់នូ-យ៉ាឲ្យការណ៍នៅពេលដែលស៊ើបសួរបំពេញ ថាគេបានសួរចម្លើយខ្លួនរហូតដល់ពេល

អាធ្រាត្រ ។

ខ) ពីព្រោះសេចក្តីកត់ហេតុចុះថ្ងៃទី១៥-១-៥០ ម៉ោង១៥-៣០នាទី ដែលលោកតាន់-កែមឡុង ធ្វើនោះបាត់ទៅ ។

គ) នៅមន្ទីរសើុបសួរក្នុងថ្ងៃទី១៦-១-៥០ នូ-យ៉ា នៅតែប្រកាន់សំដីតាមចម្លើយនៅថ្ងៃទី១៥-១-៥០ (១៩៣)

ឃ) ពីព្រោះនៅពេលពាក់កណ្តាលអាធ្រាត្រ ក្រោយពេលដែលសួរចម្លើយនូ-យ៉ា នៅមន្ទីរកុម្មិស្សែរផ្នែកទី២នោះ គេបានបញ្ជូននូ-យ៉ា ទៅមន្ទីក្រុមព្រះនគរបាលជាតិ ដើម្បីឲ្យឈប់សំរាកក្នុងគុកងងឹត ។

ង) ពីព្រោះមុននឹងបញ្ជូនខ្លួននូ-យ៉ា ទៅសាលាលុកឃុន ប្រហែលជាគេនិយាយប្រាប់វាថា ដល់សួរចម្លើយរួចហើយ គេនឹងនាំវាមកមន្ទីរក្រុមព្រះនគរបាលជាតិវិញ ។

ច) ព្រោះនូ-យ៉ា ថាលោកតាន់-គឹមតិក បានជូនខ្លួនទៅដល់ទ្វារបន្ទប់សើុបសួរ ។

គួរតែឆ្ងល់ថា ហេតុអ្វីចម្លើយរបស់នូ-យ៉ា ចេះតែផ្លាស់ប្តូរកែប្រែ ។ គឺមកអំពីតែគេបង្គាប់ឲ្យឆ្លើយឲ្យការមិនពិត បានជាមិនចាំសំដីរបស់ខ្លួន ៖

ដូចជាអំពីរឿងប្រគល់គ្រាប់បែក

ដំបូង នូ-យ៉ាថា ទៅដល់ផ្ទះឈ្មោះរុន ៗមិននៅ, ឈ្មោះសៀងក៏បញ្ចេញគ្រាប់បែកពីហោប៉ៅរបស់ខ្លួនប្រគល់ឲ្យវា ។

បន្ទាប់មក នូ-យ៉ា ថាឈ្មោះរុន បានប្រគល់គ្រាប់បែកពីរទៅឲ្យឈ្មោះសៀង ៗឲ្យមួយមកវា ទុកមួយលើខ្លួនគេ ។

ក្រោយបង្អស់ នូ-យ៉ា ថាឈ្មោះរុន ប្រគល់គ្រាប់បែក១មកវាផ្ទាល់ខ្លួន នូវគ្រាប់បែក១ទៀត ឲ្យទៅឈ្មោះសៀង ។

ដូចជាអំពីរឿងបើកប្រាក់ឲ្យចាយ

ដំបូង នូ-យ៉ា ថាបានទទួលតែ ៥០០រៀល ៥លើក ក្នុងមួយលើក១០០រៀល។

បន្ទាប់មក នូ-យ៉ា ថា៥ថ្ងៃ១០០រៀល... បើ៥ថ្ងៃ១០០រៀល ក្នុង១ខែកន្លះ ត្រូវជា៤៥ថ្ងៃរួមជា៩លើក ៩០០រៀល ។

## ចម្លើយរបស់ ចៅ-ស៊ុន

តាមលិខិតសើុបសួរ ឃើញថាចៅ-ស៊ុនហាក់ដូចជាទទួលសារភាពនៅមន្ទីរក្រុមព្រះនគរបាលជាតិ តែនៅមន្ទីរសើុបសួរប្រកែកថា មិនបានស្គាល់ឈ្មោះយ៉ា, ឈ្មោះសៀង, ឈ្មោះនាង, ឈ្មោះសួន (១៩០-១៩១) ។

## នៅពេលស៊ើបសួរបំពេញ

ចៅស៊ុនឆ្លើយថាចម្លើយរបស់ខ្លួន ត្រង់ដែលឆ្លើយដល់ឈ្មោះយ៉ា, សៀង, នាង និងសួន ហើយថាឈ្មោះទាំងនេះថាជាពួកឥស្សរៈហើយ និងសួរខ្លួនថារដ្ឋសភា មន្ទីរសំណាក់ការគណបក្សទាំងឡាយ នៅឯណាខ្លះ នោះគឺជាចម្លើយដែលគេបង្គាប់ឲ្យឆ្លើយ ។

ដល់សួរថា ហេតុអ្វីក៏ខ្លួនឆ្លើយទទួលសារភាពនៅមន្ទីរក្រុមព្រះនគរបាលជាតិ ដល់មកឆ្លើយនៅមន្ទីរស៊ើបសួរត្រឡប់ជាប្រកែកទៅវិញ ដល់ត្រឡប់ទៅមន្ទីរក្រុមព្រះនគរបាលជាតិវិញមិនប្រកែកទៀត ?

ដែលទទួលសារភាពនៅមន្ទីរក្រុមព្រះនគរបាលជាតិ ប្រកែកនៅមន្ទីរស៊ើបសួររួចទទួលសារភាពនៅមន្ទីរក្រុមព្រះនគរបាលជាតិវិញ រឿងនេះមិនគួរឲ្យងឿងឆ្ងល់ទេ ។

គួរតែលោកដែលធ្វើអង្កេតនេះ សួរទៅលោកសុភាចារបុរស ថាហេតុអ្វីបានជាខ្លួនត្រូវការបញ្ជូនខ្លួនមនុស្សជាប់ចោទទៅឲ្យមន្ទីរក្រុមព្រះនគរបាលជាតិវិញ ។

តាមខដែលខ្ញុំសុំឲ្យសួរថា «ចូរអ្នកនិយាយឲ្យការ អំពីការសួរចម្លើយអ្នកតាំងពីថ្ងៃទី១៧-១-៥០ នោះ ចៅ-ស៊ុនឆ្លើយឲ្យការដូច្នេះថា កាលទៅដល់នៅថ្ងៃទី១៧-១-៥០ ម៉ោង៧និង៣០នាទី គេបានសំរាតខោអាវដាក់គុកងងឹតភ្លាម ថាដល់ម៉ោង៨និង៣០នាទី គេសួរចម្លើយតែពុំបានកត់ទុកទេ ។

ថាដល់ម៉ោង១១និង៣០នាទី ទើបលោកអ៊ុក-ស៊ុន នាំខ្លួនដើរកាត់មុខគុកងងឹតចុះឡើង ហើយសួរខ្លួនថា តើស្គាល់មនុស្សដែលខ្លួនមើលឃើញក្នុងគុកងងឹតនោះឬទេ ។

ថាដល់ម៉ោង១៥ គេយករូបថតមួយមកបង្ហាញ រួចសួរថាស្គាក់នូ-យ៉ាទេ ? ខ្លួនឆ្លើយថា «ទេ» ។

ថាសួរចម្លើយខ្លួន រហូតដល់ម៉ោង៣ជិតភ្លឺ ។

ថាដល់ខ្លួនសុំទទួលទានដំណេក ដោយអស់កម្លាំងណាស់ នោះលោកតាន់-គឹមតិក និងលោក អ៊ុក-ស៊ុនប្រាប់ខ្លួនថា ត្រូវឲ្យសន្យាថានឹងឆ្លើយទទួលតាមខដែលសួរ ។

ថាដោយខ្លួននៅប្រកែក ទើបលោកតាន់-គឹមតិក ធាក់២ជើង, លោកអ៊ុក-ស៊ុនវាយនិងដំបងកៅស៊ូ ។

ថាក្រោយដែលបានសំរាកបន្តិច គេសួរចម្លើយខ្លួនដល់ម៉ោង៥ភ្លឺ ។

ថានៅថ្ងៃទី១៨-១-៥០ ពេលម៉ោង១៥គេនាំខ្លួនទៅសាលាលុកឃុនដើម្បីឲ្យចម្លើយ ។

ថាសួររួច គេនាំខ្លួនទៅក្រុមព្រះនគរបាលជាតិវិញ សួរយកចម្លើយទៀតតាំងពីម៉ោង២០ ដល់ម៉ោង៤ភ្លឺ ។

ថាពីម៉ោង២០ ដល់ម៉ោង២៣ ខ្លួនពុំបានទទួលសារភាពទេ ដល់ម៉ោង២ គេនិយាយប្រាប់ខ្លួនថាឯងគ្រាន់តែជាមេកធាង គេរកតែឫសនិងគល់ទេ ។

ថាគេសូត្រប្រាប់ចម្លើយ ដែលត្រូវឆ្លើយតាម ។

ថាគេសួរពីម៉ោង២ ដល់ម៉ោង៤ភ្លឺ តែពុំបានឲ្យចុះហត្ថលេខា ក្រោយពាក្យចម្លើយនោះទេ ។

ថានៅថ្ងៃទី១៩-២០-២១ មករា ១៩៥០ គេបានអានពាក្យចម្លើយឲ្យខ្លួនស្តាប់ តែមិនបានឲ្យចុះហត្ថលេខាទេ ។

ថាក្នុងថ្ងៃទី២២-១-៥០ គេឲ្យចុះហត្ថលេខាលើពាក្យចម្លើយ៥ឬ៦តែម្តង ។ នៅពេលនោះ ថាខ្លួនបានសុំឲ្យគេអានពាក្យចម្លើយឲ្យស្តាប់ គេឆ្លើយថាឥតប្រយោជន៍ទេ ។

## សូមជំរាបតុលាការ

ចុះលោកយល់ឃើញដូចម្តេច អំពីការសួរចម្លើយដែលបានធ្វើក្នុងរយៈពេលពីម៉ោង១៥ ទៅម៉ោង៥ភ្លឺ ពីម៉ោង២០ ទៅម៉ោង៤ភ្លឺ តើលោកបានស្រង់ឬទេ ហេតុអីគេមិនឲ្យចុះហត្ថលេខាភ្លាមលើសេចក្តីកត់ហេតុ ក្រោយដែលអានឲ្យស្តាប់ ទាល់តែថ្ងៃក្រោយមកទើបឲ្យចុះហត្ថលេខា ហើយមិនអានឲ្យស្តាប់ ?

ដូច្នេះតើ ! ពីព្រោះគេត្រូវការចម្លងឲ្យបានស្អាតឡើង ក្រោយពីបានកែប្រែរួចហើយ ។

សូមឲ្យលោកពិនិត្យមើល មុខជាលោកនឹងជឿមិនខាន ។ នេះមកតែពីព្រោះសេចក្តីកត់ហេតុ ដែលឲ្យចុះហត្ថលេខា និងសេចក្តីកត់ហេតុដែលអានឲ្យស្តាប់នោះ មិនមែនដូចគ្នាទេ ។

ថានៅថ្ងៃទី២ មិនា ១៩៥០ គេសួរយកចម្លើយខ្លួន អំពីសម្លៀកបំពាក់ ។

ថា១០ថ្ងៃក្រោយទៀត គេយកសំរេចរបស់ក្រុមសង្គហៈព្រះរាជវង្សានុវង្ស ដែលអនុញ្ញាតឲ្យចោទប្រកាន់លើព្រះអង្គម្ចាស់សុទ្ធាវង្ស-ធនិទ្ធតេជ ទៅបង្ហាញឲ្យមើល ។

ហេតុអ្វីបានជាគេត្រូវការឲ្យដំណឹងនេះ ? គឺដើម្បីបង្ហាញឲ្យឃើញថា ក្រុមព្រះនគរបាលជាតិ អាចធ្វើតាមអំពើចិត្តបានទៅលើរូបអ្នកណាៗក៏បាន ។

តាមខដែលខ្ញុំឲ្យសួរថា «កាលដែលឯងនៅក្នុងគុកងងឹតនោះ គេធ្វើដូចម្តេចខ្លះ ? នោះ ចៅ-ស៊ុន ឆ្លើយថា គេសំរាតខោអាវយកអស់ ឲ្យនៅតែខ្លួនទទេ ហើយដាក់ខ្នោះផង ត្រាតែបានទទួលសារភាពកាលណា ទើបបានគេឲ្យខោមកវិញ ។

ថាខ្លួនគេនៅក្នុងគុកឯងឌិតតាំងពីថ្ងៃទី១៧ មករា ១៩៥០ ទៅទល់នឹងថ្ងៃដែលបញ្ជូនទៅដាក់គុកធំ (២០ឧសភា) ១២៤ថ្ងៃ ។

តាមខដែលមេធាវី គង់-ម៉ង់ ជាសហភាតរៈរបស់ខ្ញុំសុំឲ្យសួរថា អ្នកឯងបានជំរាបលោកនាយក្រុមព្រះនគរបាលជាតិ ថាខ្លួនមានមេធាវីដែរឬទេ ? នោះចៅ-ស៊ុន ថា «បាទ, មាន» ។ តែលោកនាយក្រុមព្រះនគរបាល ឆ្លើយតបមកខ្លួនថា «មនុស្សនោះ ជួយអ្នកឯងដូចម្ដេចបាន មានតែព្រះករុណានិងខ្ញុំ (លោកតាន់-គិមតិក) ។

## តាមលិខិតស៊ើបសួរ

## ចម្លើយរបស់ ឃួន-លុត

ឃើញនៅថ្ងៃទី២៣ មករា ១៩៥០ នៅថ្ងៃដំបូងដែលចាប់ឃួន-លុត នោះឃួន-លុត បានប្រកែកនៅក្រុមព្រះនគរបាលជាតិ ថាខ្លួនមិនបានស្គាល់ឈ្មោះ សៀង, សួន និង យ៉ា ទេ ។

នៅថ្ងៃដដែលថា ឃួន-លុត ឲ្យការថា នៅពេលដែលខ្លួនជិះស៊ីក្លូក្នុងទីក្រុង បានសួរទៅគូលីស៊ីក្លូ (ឈ្មោះសួន) ថា ឲ្យជួយរកមនុស្ស៤នាក់ មកជួយធ្វើការឃោសនា ក្នុងការបោះឆ្នោតរើសតំណាងរាស្ត្រ ។ នោះថ្ងៃក្រោយមក ឈ្មោះនេះបាននាំឈ្មោះសៀង, នាង មកជួបនឹងខ្លួន ។

នៅថ្ងៃទី២៤ មករា ១៩៥០ នៅមន្ទីរស៊ើបសួរ ឃួន-លុតបានប្រកែកថា មិនស្គាល់ឈ្មោះ យ៉ា ទេ ។

នៅថ្ងៃទី២៦, ២៧, ២៨ មករា ១៩៥០ ថាឃួន-លុតឆ្លើយថា ខ្លួនបានចូលទៅក្នុងពួកក្រុមធ្វើឃាតកម្មជាមួយនឹងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ។

ថាខ្លួនបានឲ្យប្រាក់ទៅឈ្មោះ សួន, យ៉ា, នាង និងសៀង មួយខែ៥០០រៀល ក្នុងរវាង២ខែ ត្រូវជា៤,០០០រៀល គឺជាប្រាក់របស់ខ្លួនទាំងអស់ ។ ថាព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជនឹងសងខ្លួនវិញ ២,០០០រៀល (លេខ១៨៨, ១៨៩) ។

ថាឃួន-លុតឲ្យការថា ខ្លួនបានឲ្យទៅនូ-យ៉ា២០០រៀល តែឈ្មោះនូ-យ៉ា នេះមិនបានឆ្លើយឲ្យការថា បានទទួលប្រាក់ពីឃួន-លុត ឬពីឈ្មោះណាមួយក្នុង១លើក២០០រៀលនោះទេ ។

## នៅពេលស៊ើបសួរបំពេញ

ស. ឆ. ឃួន-លុតឆ្លើយថា គេសួរចម្លើយខ្លួននៅថ្ងៃទី២៣ មករា ១៩៥០ គឺនៅពេលដែលទៅដល់មន្ទីរក្រុមព្រះនគរបាលជាតិភ្លាម ពីម៉ោង១១ទៅដល់ម៉ោង១៣ម្ដង ពីម៉ោង២១ទៅដល់ម៉ោង២៣ម្ដងទៀត តែចម្លើយរបស់ខ្លួនគេមិនបានកត់ត្រាទុកទេ ។

ថានៅថ្ងៃនោះ គេមិនបានវាយខ្លួនទេ ។

ថានៅថ្ងៃទី២៤ មករា ១៩៥០ ម៉ោង២១ក្រោយពេលដែលពន្លត់ភ្លើងអស់ ស្រាប់តែមានមនុស្ស៣នាក់មកវាយខ្លួនក្នុងទីងងឹតឈឹងនោះ ហើយនិយាយថាបើមិនព្រមឆ្លើយដាក់ដល់....នឹងវាយទាល់តែស្លាប់ ។

ថានៅពេលម៉ោង២២មានអ្នកយាមម្នាក់ មកបញ្ចេញខ្លួនពីគុកងងឹត ហើយនាំខ្លួនឡើងទៅលើឡៅ នោះលោកនាយក្រុមព្រះនគរបាលជាតិ (តាន់-គិមតិក) និងលោកភូឈួយ (អ៊ុក-ស៊ុន) សួរខ្លួនថា ស្គាល់ឈ្មោះ សៀង, សួន និងយ៉ាទេ ? ថាដល់ខ្លួនឆ្លើយថាមិនស្គាល់ ទើបមានភ្នាក់ងារ៤នាក់ មកនាំខ្លួនឲ្យចុះទៅក្រោមវិញ ពេលនោះគេពុំពុំបានកត់ត្រាចម្លើយខ្លួនទេ ។

ថានៅថ្ងៃទី២៥-១-៥០ គេពុំបានសួរចម្លើយខ្លួន មិនបានវាយខ្លួនទេ ។

ថានៅថ្ងៃទី២៦-១-៥០ ពេលម៉ោង២១ មានបីនាក់វាយបង្ខំបង្គាប់ ឲ្យឆ្លើយដូចអ្នកឯទៀត ។

ថាក្រោយកន្លះម៉ោង មានបីនាក់ ម្នាក់នោះធំខ្មៅ បានមកបញ្ចេញខ្លួនពីគុកងងឹត ហើយនាំខ្លួនឡើងទៅប៊ុយរ៉ូលោកនាយក្រុមព្រះនគរបាលជាតិ ។

ថាដោយខ្លួនធុននឹងសេចក្ដីឈឺចាប់ពុំបាន ក៏ឆ្លើយថាខ្លួនស្គាល់... ។

ថាគេសួរចម្លើយខ្លួនដល់ម៉ោង២ ទើបគេយកទៅដាក់ក្នុងគុកងងឹតវិញ ទៅទល់នឹងថ្ងៃដែលដេកពេទ្យ (២៧-៤-៥០) ។

ថាខ្លួនបានឲ្យការណ៍ថា បានចូលនឹងពួកក្រុមធ្វើឃាតកម្មជាមួយនឹងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ។

ថាឈ្មោះសួនបានសុំខ្លួនទៅសំរេចកិច្ចនោះ ។

ថាព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ បានទទួលដំណឹងអំពីការប្រុងប្រៀបថាបានព្រមព្រៀង, ថាបានមានបន្ទូល, ឲ្យទៅពិគ្រោះសួរនឹងចៅ-ស៊ុន ។

ថាចម្លើយទាំងអម្បាលមាណនេះ ឆ្លើយដោយគេបញ្ចេះ, គេបង្ខំ ។

ថានៅយប់ថ្ងៃទី២៧-១-៥០ ពេលម៉ោង២១ គេសួរចម្លើយខ្លួនទៀត តែមិនចាំ ។ ពេលនោះគេប្រាប់ថា ពុំមែនជាប្រាក់របស់ខ្លួន គឺជាប្រាក់របស់ព្រះអង្គម្ចាស់ ។

ថាខ្លួនក៏ថាដូច្នោះមែន ឲ្យរួចតែពីមាត់ទៅ ។

ថានៅពេលថ្ងៃ គេសួរខ្លួនតែម្ដង គឺនៅថ្ងៃទី២៣-១-៥០ ឯការសួរលើកដទៃទៀត គេសួរតែក្នុងពេលម៉ោង២១យប់ ។

ថាខ្លួនឈឺខ្លាំង តាំងពីថ្ងៃទី៧ ដល់ថ្ងៃទី២៧-៤-៥០ ទើបបានអនុញ្ញាតឲ្យដេកពេទ្យ ។

ថាកាលណោះ ខ្លួនបានស្រែកប្រហែលជាមានគេឮ ។

សូមជំរាបតុលាការ

ខ្ញុំសូមបញ្ជាក់ព្រះតេជគុណាថា ឃួន-លុត ដោយហេតុគេធ្វើទុក្ខបុកម្នេញក្នុងគុកងងឹតក្រុមព្រះនគរបាលជាតិ សព្វថ្ងៃនៅតែទុរុនទុរា ប្រហែលជានឹងទុរុនទុរាយូរទៅទៀត ។ ដែលលោកតាន់-គិមតិក ឆ្លើយតបដោយអះអាងនឹងលោកមេធាវី គង់-ម៉ង់ ថាខ្លួនបានពិនិត្យរូបមនុស្សជាប់ឃុំ ដោយខ្លួនឯង មិនឃើញមានស្លាកស្នាមអ្វីទេ ហើយថាពាក្យដែលសុំឲ្យពេទ្យពិនិត្យនោះ ជាការឥតប្រយោជន៍ (៧៤-១៨៨-១៨៩) ។

ស្រាប់តែក្រុមព្រះនគរបាលជាតិបានប្ដឹងមកលោកសុភាចារបុរសថា ឃួន-លុតឈឺជាទម្ងន់ តាមសំបុត្រលេខ ១.៦៦៥ P.S. ចុះថ្ងៃទី២២-៤-៥០ ។

លោកគ្រូពេទ្យនាយក្រុមព្យាបាលខាងក្រៅ បានសំរេចថា អ្នកមានជម្ងឺត្រូវឲ្យចូលដេកពេទ្យ ត្បិតកើតរោគខ្សត់ឈាមជាទម្ងន់ និងរោគប្រគ្រីវ ។ (១៩៧-១៩៨-២០០) ។

តើជម្ងឺដែលកើតឡើងក្នុងគុកងងឹតនោះបណ្ដាលមកពីហេតុអ្វី ? បើកាលដែលគេចាប់ ឃួន-លុត កាលណោះ នៅជានាទេ (ធំធាត់ទេតើ) ។

៦. ឱ. កុសល មុនពេលដែលឈប់ពីតំណែងរដ្ឋាភិបាលក្រសួងយុត្តិធម៌ បានបង្គាប់ឲ្យយកឃួន-លុត មកបញ្ចូលក្នុងគុកវិញ ។

នោះលោកគ្រូពេទ្យដែលថែរក្សាជម្ងឺ នៅមន្ទីរពេទ្យព្រះកេតុមាលា មិនស្ដាប់គំនិតមនសិការក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ក៏បានចេញសំបុត្រអនុញ្ញាតឲ្យឃួន-លុតជាអ្នកជម្ងឺអកុសល ឲ្យដាក់ (ប្រង់កា) សែងចេញពីមន្ទីរពេទ្យ ។ (២០៨)

ដោយសារមានពាក្យសុំរបស់ខ្ញុំ លេខ៣ ចុះថ្ងៃទី១៦ ឧសភា ១៩៥០ បញ្ជាក់ថា ប្រសិនបើលោកគ្រូពេទ្យដែលថែរក្សាជម្ងឺយល់ឃើញថា មិនបាច់ឲ្យឃួន-លុតជាកូនក្ដីរបស់ខ្ញុំចូលពេទ្យវិញនោះ ខ្ញុំសុំឲ្យក្រុមប្រឹក្សាសុខាភិបាលពិនិត្យ ហើយសំរេចជាការដាច់ខាតអំពីរឿងសុំឲ្យឃួន-លុត ត្រឡប់ទៅដេកពេទ្យវិញ ។

វិធានការរបស់លោក កុសល ជាអគ្គលេខាធិការគណបក្សដំកើងប្រជាជាតិជាអំពើឥតមនុស្សធម៌សោះឡើយ ។

ឃួន-លុត បានផ្ញើពាក្យដោះសារ ដែលខ្លួនសរសេរជូនទៅលោកអ្នកឧកញ៉ារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដាក់ក្នុងស្រោមសំបុត្រការខ្ទង់ឈ្មោះខ្ញុំ នោះខ្ញុំបានយកសំបុត្រនោះទៅជូនផ្ទាល់ដៃ ។

ពាក្យដោះសារដូចមានខាងក្រោមនេះ

---

ខ្ញុំប្របាទម្ចាស់ឆ្លើយប្រកែក តាមចំណាំខ្ញុំប្របាទម្ចាស់ ដោយមិនដឹងហេតុមិន

ដឹងផល ដែលមិនដឹងនោះ នោះលោកចាងហ្វាងក្រុមសម្ងាត់ និងលោកភូឈ្មួយក្រុមសម្ងាត់ លោកពុំព្រមឲ្យស្មៀនកត់តាមពាក្យ តាមចំណាំខ្ញុំប្របាទម្ចាស់សោះ លោកទាំងពីរនាក់បង្គាប់ប្រាប់បង្ខំឲ្យឆ្លើយទទួលស្គាល់ឈ្មោះ អាយ៉ា១ អាសួន១ អាសៀង១ អានាង១, ខ្ញុំប្របាទម្ចាស់និងព្រះអង្គម្ចាស់នរិន្ទតេជ ឲ្យឆ្លើយថាជាពួកក្រុមធ្វើឃាតកម្ម ឲ្យឆ្លើយថាមេគំនិត បើកប្រាក់ឲ្យអាទាំង៤នាក់, ដោយខ្ញុំបាទប្រកែក ក៏យកខ្ញុំប្របាទម្ចាស់ទៅដាក់ខ្នោះដៃ ក្រពាត់ទៅក្រោយខ្នងទាំងពីរ សំរាតខោអាវទាំងអស់ ដាក់ចោលក្នុងសាលបូល (គុកងងឹត) ចំនួន៤យប់៤ថ្ងៃ បង្អត់បាយបង្អត់ទឹក យប់លត់ភ្លើង ចូលទៅវាយដំជិះជាន់ ចាប់សរសៃពោះហើមដៃ ហើមទាំងខ្លួន ចុកចាប់ឈឺស្ទើរបែកថ្លើមប្រមាត់ធ្លាយដើមទ្រូង ហូរអាចម៍ហូរនោម ចេញក្អួតពីមាត់ ឈឺនោះឈឺពន់ពេកណាស់ ទ្រាំអត់ពុំបានឡើយ ។

លុះត្រាតែឆ្លើយទទួលថា ស្គាល់អា៤នាក់ខាងលើនេះ ហើយនិងឆ្លើយដាក់ព្រះអង្គម្ចាស់នរិន្ទតេជ ទើបលែងធ្វើបាប បានដោះខ្នោះ ឲ្យស្លៀកខោ យកទៅដាក់ក្នុងសាលបូលវិញដដែល ។

ទានប្រោសខ្ញុំប្របាទម្ចាស់ឆ្លើយនេះ គឺឆ្លើយឲ្យរួចពីសេចក្ដីឈឺចាប់ទ្រាំពុំបានប៉ុណ្ណោះ ។

## សូមជំរាបមកតុលាការ

ខ្ញុំសូមបញ្ជាក់ព្រះតេជព្រះគុណាថា ឃួន-លុតជាកូនក្ដីរបស់ខ្ញុំជាប់ឃុំឃាំងក្នុងទីស្ងាត់តែឯង (គុកងងឹត) ពីថ្ងៃទី២៣ មករា ១៩៥០ ទៅដល់ថ្ងៃទី២៦ មេសា ១៩-៥០ ត្រូវជា៩៤ថ្ងៃ ទាស់ខុសនឹងបញ្ញត្តិមាត្រា១២៩. ១៣០ ក.ភ.ព.ទ. ។

## ការសួរតទល់

នៅកាលតទល់នោះ មនុស្សជាប់ចោទឈ្មោះនូ-យ៉ា, ចៅ-ស៊ុន, ឃួន-លុត នៅតែប្រកាន់តាមចម្លើយរឿងខ្លួន អំពីរឿងវាយដំ ។ ឯលោកសេង-ទីប, តាន់-គិមតិក និងអ៊ុក-ស៊ុន ក៏នៅតែប្រកែក ។

រឿងនេះស្រេចនៅតុលាការពិនិត្យពិចារណាតាមការទៅចុះ, ព្រោះអំពើសេចក្ដីវាយដំនេះ គឺសេចក្ដីពិត ខ្ញុំមិនធ្លាប់បង្កើតរឿងដូច ម៉ាក់គីយ៉ាវែល (Machiaviel) ទេ ការនោះគឺខ្ញុំដឹងអំពីអ្នកធ្វើការក្នុងក្រសួងក្រុមព្រះនគរបាលជាតិ តែអ្នកទាំងនោះសុំកុំឲ្យចេញឈ្មោះគេ, សូមតុលាការឈ្វេងយល់ចុះ អ្នកធ្វើការក្នុងក្រុមព្រះនគរបាលជាតិ ធ្វើម្ដេចនឹងហ៊ានមកធ្វើសាក្សីក្នុង៥ដែលកំហុសលើចៅហ្វាយ ដែលកំហុសទៅលើក្រុមព្រះនគរបាលជាតិទាំងមូល ។

## អំពីស្ម័គ្របក្សពួកជាក្រុមធ្វើឃាតកម្ម

(មាត្រា២១-២៩០ ភ.ព.)

គេលើកទម្លាក់ដាក់ទម្ងន់ ៖

ដោយហេតុមានចម្លើយរបស់ នូ-យ៉ា ឆ្លើយដាក់ចៅ-ស៊ុន, ឃួន-លុត, និងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ គឺចម្លើយដោយគេបង្ខំបញ្ចេះ ។

ដោយហេតុចៅ-ស៊ុននិងឃួន-លុតឆ្លើយទទួលនិងឆ្លើយដាក់ព្រះសុទ្ធាវង្ស-នរិន្ទតេជ ។ ឯចម្លើយដែលឆ្លើយទទួលនិងឆ្លើយដាក់នេះ ដោយគេវាយបង្ខំដោយគេឃុំឃាំង នៅក្នុងទីស្ងាត់តែឯង ហួសកំណត់ច្បាប់ ។

ហេតុនេះក្រោយពេលដែលស៊ើបសួរបំពេញរួចជាស្រេច ទើបលោកព្រះរាជបំរើចោទថែម លើមនុស្សជាប់ចោទអំពីបទស្មគ្រគបក្សពួក ជាក្រុមធ្វើឃាតកម្ម ។

ក- ចម្លើយរបស់នូ-យ៉ា ត្រង់ដែលថាដើរមួយវង់ធំ តាមផ្លូវផ្សេងៗក្នុងទីក្រុងភ្នំពេញ ដើម្បីឲ្យសំគាល់ទុកជាមុន ចំពោះនាទីដែលខ្លួនត្រូវសំរេចទោសប្រហារជីវិតតៗគ្នាជាលំដាប់ តាមមុនក្រោយ ដែលថាតាមសំរេចរបស់ក្រុមធ្វើឃាតកម្ម មានព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជជាមេ ។

តែនូ-យ៉ា បានឲ្យការណ៍ជាក់ច្បាស់ថា គេពុំបានប្រាប់ឈ្មោះប្រាប់មុខក្រសួងរបស់មនុស្សដែលត្រូវសម្លាប់ ថែមទាំងមិនបានចង្អុលបង្ហាញរូបនោះផង ។ ដូចជា ៖

ខ- ១) អំពីឃាតកម្មឯ. ឧ. អៀវ-កើស ថាឈ្មោះ សួន បង្ហាញផ្ទះពីរជាន់មួយនៅត្រង់ជ្រុងមហាវិថី ឌូដា ដឺឡាក្រេ និងវិថី ពិកេត៍ (គឺផ្ទះរាជការរបស់ប្រធានរដ្ឋសភា) ។

ស្រាប់តែនូ-យ៉ា ឬគូកនរបស់ឈ្មោះនេះ បោះគ្រាប់បែកនៅក្នុងផ្ទះមួយ ចម្ងាយពីទីនោះ គឺក្នុងសំណាក់ការមិនមែនបោះនៅទីកន្លែង ដែលឈ្មោះសួនបានបង្ហាញនោះទេ ។

ខ- ២) អំពីការឃាតកម្ម ឯ. ឧ. យ៉ែម-សំបូរ ថាឈ្មោះនាង បានបង្ហាញផ្ទះពីរជាន់មួយ នៅខាងជើងមន្ទីរកុម្មិស្ស៊ែរ៍ធំ គឺផ្ទះដែលមានតូបប៉ូលិសចាំយាម (ទាហានឯកទេស) ។

ខ- ៣) អំពីការធ្វើឃាតកម្មសម្ដេចក្រុមព្រះស៊ីសុវត្ថិ-មុនីរ៉េត (នៅខាងមុខរោងកុនស៊ីណេ-លុក្ស) ។

ថាឈ្មោះសួន បង្ហាញផ្ទះមួយនៅខាងកើតដំណាក់ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ (?) ថានៅខាកើតបំផុត (?) ហើយថានៅខាងលិចរោងកុន (?) ។

ឯខាងកើតដំណាក់ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ គ្មានផ្ទះមន្ត្រីណាមួយទេ ខាងលិចរោងកុន ប៉ុហ្ស៍ ក៏គ្មានដែរ ។

គួរតែសម្គាល់ឃើញថា ចម្លើយនូ-យ៉ានេះ មិនស្របនឹងចម្លើយរបស់ខ្លួនដែ-

លបានឆ្លើយអំពីមុនមក ដែលថាខ្លួនមិនស្គាល់ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ មិនស្គាល់ដំណាក់របស់ទ្រង់ទេ ។

ខ- ៤) អំពីការធ្វើឃាតកម្មសម្តេចព្រះវរាជជននីនាថ និងសម្តេចព្រះបរមរាជបិតា ថាឈ្មោះសួនបាននាំនួ-យ៉ា ទៅជិតផ្សារកាប់គោ ហើយប្រាប់វាថា នឹងឈប់ចាំនៅទីនេះ (ផ្លូវ៩កញ៉ាអុំ) ដើម្បីចោលគ្រាប់បែកក្នុងរថយន្តមួយ ក្នុងពេលដែលបើកកាត់ទីនេះ ។

ខ- ៥) អំពីការធ្វើឃាតកម្មព្រះករុណាព្រះអង្គម្ចាស់ជីវិតលើត្បូង ថាឈ្មោះសួននាំខ្លួនទៅត្រង់ចំការមន ហើយថាសីហនុមានស្ត្រីម្នាក់ត្រូវតែសម្លាប់ត្រង់ណោះ ឬនៅតិរិវិថីនរោត្តម ជិតដងកើ ។

នួ-យ៉ា ថាខ្លួនមិនបានស្គាល់សីហនុទេ ។

អ្នកបង្គាប់បញ្ជាឲ្យឆ្លើយដូចខាងលើនេះ ពូកែពិតមែន ដោយចង់ឲ្យព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ សុគតពេកណាស់ទៅ គេមិនខ្លាចប៉ះពាល់ដល់ព្រះចេស្តាបារមី ព្រះករុណាជាអង្គម្ចាស់ជីវិតលើត្បូង ។

គ្មានខ្មែរណាមួយហ៊ានហៅចេញព្រះនាមព្រះករុណាទេ ប្រជាជនសាមញ្ញតែងតែពោលថា ៖

ព្រះករុណា ឬព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, មិនដែលហ៊ានហៅថា សីហនុកំបុតៗដូច្នោះទេ ។

គេពុំបានសួរនួ-យ៉ាបញ្ជាក់ថា ដែលបានដើរមួយជុំធំនោះ តើក្នុងពេលព្រឹក ឬពេលរសៀល ឬពេលយប់ ដើរតែមួយលើក ឬច្រើនលើក ដើរជើង ឬជិតទោចក្រយាន ឬត្រីចក្រយាន ឬរថយន្ត ។

ថាកាលណោះ មានអ្នកនាំផ្លូវ២នាក់ឈ្មោះ សួន និងឈ្មោះនាង ។

ខ្ញុំចូលចិត្តឲ្យនួ-យ៉ា នៅតែប្រកាន់ចម្លើយទទួលសារភាព និងចម្លើយដែលឆ្លើយដាក់កូនក្តីរបស់ខ្ញុំ ដើម្បីឲ្យខ្ញុំដាក់ខសួរយ៉ាងលំអិត ដើម្បីបង្ហាញឲ្យឃើញថា ចម្លើយដែលឆ្លើយដាក់កូនក្តីខ្ញុំ ពិតជាចម្លើយបង្គាប់បញ្ជា ។

ចុះឥឡូវធ្វើដូចម្តេច ? ការតទល់សួរមិនកើត ។

ខ- ចម្លើយរបស់ ចៅ-ស៊ិន ៗប្រហែលជាឆ្លើយថា

ក) បានទៅជួបនឹងអនុសេនិយត្រី អ៊ូ-ធិញ និង សាវ៉ាង ដែលរត់ចេញពីរាជការទាហាន ។

ខ) បានចូលពួកធ្វើឃាតកម្ម ដែលមានព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ដើម្បីធ្វើឃាតកម្មដូចតទៅនេះ ៖

១- ៦. ៩. អៀវ-កើស

២- ឯ. ឧ. យ៉ែម-សំបូរ
៣- ព្រះអង្គម្ចាស់ក្រុមហ្លួង ស៊ីសុវត្ថិ-មុនីពង្ស
៤- សម្តេចក្រុមព្រះ ស៊ីសុវត្ថិ-មុនីរ៉េត
៥- សម្តេចព្រះវររាជជននីនាថ
៦- សម្តេចព្រះបរមរាជបិតា

ចៅ-ស៊ុន ប្រហែលជាឆ្លើយឲ្យការណ៍ថា ខ្លួនបានស្គាល់ពួកក្រុមធ្វើឃាត មួយក្រុមទៀតដែលមាន ៖

១- លោក អ៊ិត-ស៊ាប
ឯ. ឧ. អ៊ិត-ស៊ាម
ឯ. ឧ. ហាក់-ម៉ុងសេង
លោក អ៊ិត-ម៉ុងស៊ុន
លោក ឃិន-ឆែ
លោក អ៊ូ-ធិញ
លោក ពុត-ឆាយ

គួរពិចារណាថា ចៅ-ស៊ុន ជាអង្គរក្សរបស់ព្រះអង្គម្ចាស់សុទ្ធាវង្ស-ធរិទ្ធតេជ ជាប្រមុខគណៈរាស្រ្តសេរីភាព តើនឹងអាចស្គាល់ពួកក្រុមធ្វើឃាតកម្ម ខាងគណបក្សប្រជាធិបតេយ្យបានដែរឬទេ ? បើឈ្មោះចៅ-ស៊ុនមិនដែលទៅមកទាក់ទងនឹងគណបក្សប្រជាធិបតេយ្យសោះ ។

អស់លោកក្រុមព្រះនគរបាលយុត្តិធម៌ ដែលចង់ធ្វើឲ្យឃើញថា ខ្លួនបានខិតខំធ្វើការខ្លាំងពេក, ចង់រកឲ្យឃើញភស្តុតាង លើកូនក្តីរបស់ខ្ញុំខ្លាំងពេក នោះត្រឡប់ទៅជារកភស្តុតាងអ្វីគ្មាន ។

អ្នកដែលចេះដឹង គេមិនជឿអំពើដែលពួតផ្សេងជាដុំផ្លុំឆេះជាភ្លើងដូច្នោះសោះឡើយ ។

សម្តេចក្រុមព្រះស៊ីសុវត្ថិ-មុនីរ៉េត មួយថ្ងៃទ្រង់មានព្រះបន្ទូលនិងខ្ញុំថា ទ្រង់មិនជឿទេ ។

ទ្រង់មានព្រះបន្ទូលកំប្លែងលេងថា «បើប្រសិនណាជាទ្រង់ជឿ ទ្រង់ស្តេចយាងទៅសួររឿងហេតុផ្ទាល់ព្រះអង្គម្ចាស់សុទ្ធាវង្ស-ធរិទ្ធតេជ ។

បើទ្រង់ឆ្លើយថាពុំមែនទេ ក៏ហើទៅ ទ្រង់មិនធ្វើទេ

បើទ្រង់ឆ្លើយថាមែន សម្តេចនឹងដាល់ព្រះអង្គម្ចាស់មួយប្រហត្ថ ចំកញ្ចប់ព្រះឱស្ឋទ្រង់» ។

ខ្ញុំជឿជាក់ថា ព្រះតេជព្រះគុណាជាតុលាការ ក៏មិនជឿរឿងហេតុដែលគេប្រឌិត

បង្កើតរឿងនេះដូចជាសម្ដេចក្រុមព្រះស៊ីសុវត្ថិ-មុនីរ៉េតដែរ ។

យោបល់មហាជនយ៉ាងដូចម្ដេច ? អស់លោកក៏បានជ្រាបស្រាប់ហើយ ។

ការស៊ើបសួរបំពេញ

ចៅ-ស៊ុនឆ្លើយថា ខ្លួនមិនបានជួបនឹងលោកអ៊ូ-ធិញ, លោក សារ៉ាំង ។

ថាអស់លោកទាំងនេះ មិនបានសុំឲ្យខ្លួនជួយរកគ្រឿងអាវុធគ្រាប់បែក ដើម្បីបណ្ដេញបារាំងនោះទេ ។

ថាចម្លើយមុនៗរបស់ខ្លួន ដែលឆ្លើយដាក់ដល់លោកទាំងនេះ ដោយខ្លាចគេវាយដំ ។

គ- ចម្លើយរបស់ឃួន-លុត ថាខ្លួនបានឆ្លើយថា ខ្លួនជាមួយនិងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ បានចូលពួកក្រុមធ្វើឃាតកម្ម ហើយថាបានចេញប្រាក់ពីហោប៉ៅអាវខ្លួនអស់៤០០០រៀល ។

នៅពេលស៊ើបសួរបំពេញ ឃួន-លុតប្រកែកវិញ ។

ចម្លើយរបស់ឃួន-លុត ដែលខុសខ្វែងពីចម្លើយនូ-យ៉ា មិនអាចពិនិត្យយកជាការពិតបានទេ ដោយហេតុនូ-យ៉ា ជាអ្នកឆ្លើយដាក់គេជាដំបូង ត្រឡប់ជាប្រកែកវិញ ។

យើងសុំនិយាយអំពីផ្លូវច្បាប់តុលាការវិញ

កាលដែលកកើតឡើងជាស្ម័គ្របក្សពួក ជាក្រុមបាន លុះត្រាតែមានលក្ខណៈទាំងបីដូចមានខាងក្រោមនេះ ៖

១- ត្រាតែមានបង្កជាពួកក្រុមហើយ ឬបានព្រមព្រៀងតាំងឡើងជាស្រេច ។

២- ត្រាតែមានបង្កជាពួកក្រុមហើយ ឬមួយបានព្រមព្រៀងតាំងឡើងជាស្រេច តាមគោលបំណងដែលបានរៀបចំទុកប្រព្រឹត្តបទឧក្រិដ្ឋ ។

៣- ត្រាតែមានចេតនាទុច្ចរិត ។

អំពីការបង្កជាពួកក្រុម ការព្រមព្រៀងគ្នា តាំងឡើងជាស្រេច

នូ-យ៉ា ជាអ្នកដែដល់ ឬជាអ្នកសមគំនិត ដោយទំនុកបំរុងក្នុងបទឃាតកម្មឯ. ឧ. អៀវ-កើស (គឺជាអ្នកចោលគ្រាប់បែក ឬជាអ្នកចាំមើលផ្លូវ) មិនដែលទៅមកកាន់ផ្ទះចៅ-ស៊ុន (គឺផ្ទះឯ. ឧ. នាល-ផ្លេង) មិនដែលទៅមកផ្ទះលោកឃួន-លុត និងដំណាក់ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ។

នូ-យ៉ា មិនដែលមានប្រស្រ័យគ្នាទៅវិញទៅមក ពីព្រោះមិនដែលស្គាល់គ្នាសោះ បើដូច្នេះមិនមែន ជាស្ម័គ្របក្សពួកក្រុម ឬបានព្រមព្រៀងគ្នា តាំងឡើងជាស្រេចនោះទេ ។

ចម្លើយរបស់នូ-យ៉ា ដែលបានឆ្លើយដាក់ចៅ-ស៊ុន, ឃួន-លុត, និងព្រះអង្គម្ចា

ស់សុទ្ធាវង្ស-នរិន្ទតេជ ជាកូនក្តីរបស់ខ្ញុំ នោះជាចម្លើយដែលគេបញ្ចេះ បង្ខំឲ្យឆ្លើយទេ ។

សំដីទាំងឡាយដូចមានខាងក្រោមនេះ «ថាត្រូវតែបង្ខំឲ្យឆ្លើយដាក់គណៈសេរីភាព» ជាសំដីដែលលោកសេង-ទីប និងលោកអ៊ុក-ស៊ុន នៅមន្ទីរកុម្មិស្ស៊ែរផ្នែកទី ២ និងកុម្មិស្ស៊ែរពិសេសមានប្រសាសន៍នៅពេលដែលពិសារភោជនាហារក្នុងភោជនីយដ្ឋានហេមពាន... ចំពោះមុខលោកផុន ជាប៉ូលិសសេដ្ឋកិច្ច ៗបានពាំនាំយកមកនិយាយប្រាប់លោកហែម-សារី, ទូច-ស៊ីចាន់ ក៏បណ្តាលឲ្យឃើញថា ចម្លើយរបស់នួ-យ៉ា ដែលឆ្លើយដាក់ដល់ឈ្មោះ ថៅ-ស៊ុន, ឃួន-លុត, និងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ប្រាកដជាចម្លើយ ដែលគេបញ្ចេះ គេបង្ខំឲ្យឆ្លើយ ។

ចម្លើយរបស់ថៅ-ស៊ុន និងឃួន-លុត ដែលឆ្លើយដាក់ដល់ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ រួចក្រោយមកឆ្លើយប្រកែកទៅវិញ នោះជាចម្លើយដែលគេបានធ្វើទុក្ខបុកម្នេញបង្ខិតបង្ខំ «គេឃុំឃាំងក្នុងទីស្ងាត់តែម្នាក់ឯង ហួសកំណត់ច្បាប់ គ្មានសេចក្តីយល់ព្រមអំពីក្រសួងអយ្យការ, គ្មានបង្គាប់អំពីសុភាចារបុរស ទាស់ខុសនឹងបញ្ញត្តិមាត្រាលេខ១២៩, ១៣០ ក.ភ.ព.ទ.» ។

ចេតនាប្រុងប្រៀប ឬចេតនាប្រព្រឹត្តបទឧក្រិដ្ឋ

ពួកកូនក្តីរបស់ខ្ញុំមិនមានបំណងនឹងសងសឹក មិនមានខ្វល់ខ្វាយប្រព្រឹត្តទុច្ច-រិត ។

ដូចខ្ញុំបានសារស័ព្ទមកហើយថា ៖

រវាងឯ. ឧ. អៀវ-កើស និងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជក្តី រវាងគណបក្សប្រជាធិបតេយ្យ និងគណៈរាស្ត្រសេរីភាពក្តី មិនដែលមានហេតុទាស់ទែងខ្វែងគំនិតគ្នា ឲ្យបានជាធំដុំ ដល់ទៅពិឃាតគ្នាសោះឡើយ ។

ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ មិនបានជួយឲ្យកម្លាំងក្នុងការរំលាយរដ្ឋសភា ដើម្បីឲ្យឯ. ឧ. អៀវ-កើស ផុតរបូតពីតំណែងប្រធានរដ្ឋសភានោះទេ ។

ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ មិនបានជំទាស់ មិនឲ្យឯ. ឧ. អៀវ-កើស កាន់តំណែងនាយករដ្ឋមន្ត្រី រហូតទៅដល់ពេលបោះឆ្នោតជ្រើសតំណាងរាស្ត្រថ្មីនោះទេ ។

ចេតនាទុច្ចរិត

គ្មានការបង្កជាពួកក្រុម គ្មានការព្រមព្រៀងគ្នាតាំងឡើងជាស្រេច គ្មានគោលបំណង ទើបមិនបាច់ឆ្លើយក្នុងខសួរទី៣នេះទេ ។

សូមជំរាបតុលាការ

នៅឱកាសជំនុំជំរះមានលេចហេតុ ៖

ក) ក្រោយដែលសួរតទល់ លោកតាន់-កែមឡុង និងលោកជា-ឡុង
ឃើញសេចក្ដីកត់ហេតុ ចុះថ្ងៃទី១៥-១-៥០ ពេលម៉ោង១៥និង៣០នាទី ដែល
លោកតាន់-កែមឡុង ធ្វើពីម៉ោង១៥និង៣០នាទី ទៅដល់ម៉ោង១៨ មានលោក
ជា-ឡុងអមផង ។

សេចក្ដីកត់ហេតុនោះ ក្រោយសូត្រឲ្យស្ដាប់ បានចុះហត្ថលេខាជាមួយនូ-យ៉ា, សេចក្ដីកត់ហេតុនេះ ធ្វើរួចជាស្រេចពេញលេញត្រឹមត្រូវ ។

ពេលនោះនូ-យ៉ាឆ្លើយដាក់គូកន៤នាក់ គឺឈ្មោះ ឃុត១, ឃិន១, ប៉ុន១, និងហ៊ាន១ មិនមែនឆ្លើយដាក់ចៅ-ស៊ុន, ឃួន-លុត និងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជទេ ។

ឃើញថាសេចក្ដីកត់ហេតុ ចុះថ្ងៃទី១៥-១-៥០ ដែលដាក់ថា ធ្វើពីម៉ោង១៥និង៣០នាទី ដែលដាក់ក្នុងសំណុំរឿងនោះ ជាសេចក្ដីកត់ហេតុ ដែលលោកសេង-ទីប, លោកតាន់-គិមតិក មានលោក ជា-ឡុង អមផង, ធ្វើឡើងវិញពីម៉ោង២០ ដល់ម៉ោង២៤ ជំនួសសេចក្ដីកត់ហេតុដែលបំបាត់ ។

ឃើញថា ដែលលោកសេង-ទីប និងលោកតាន់-គិមតិក ផ្លាស់ប្ដូរអង្គហេតុសេចក្ដីអង្កេតស៊ើបសួរយ៉ាងនេះ គឺប្រព្រឹត្តបទក្លែងលិខិតសាធារណៈ ដែលមានបញ្ញត្តិមាត្រា២១, ២៥៨, ក.ព.ទ. ត្រូវឲ្យមានទោសឧក្រិដ្ឋថ្នាក់ទី២ (គុកអស់មួយជីវិត) ។

ខ) លោកង៉ែត-ហ៊ាន ឲ្យការណ៍ថា មនុស្សដែលរត់ (គឺមនុស្សដែលអង្គុយលើចិញ្ចើមផ្លូវ គឺស្គាល់ដោយសំលៀកបំពាក់) ។

សាក្សីឈ្មោះ ជាម-យុន ឲ្យការណ៍ថា មនុស្សដែលរត់នោះ អ្នកជិះទោចក្រ-យាន និងមនុស្ស២នាក់ទៀតដេញ ថាមនុស្សដែលរត់រូបរាងធំខ្មៅ ។

សាក្សី ហៃ-មុយឆែ ថា មនុស្សដែលគេចាប់បាន ដង្ហក់ហត់បែកញើសនិយាយមិនកើត ។

លោកតាន់-កែមឡុង ឲ្យការណ៍ដោយមាំមួនថា នូ-យ៉ាមិនបានឆ្លើយដាក់ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ និងមនុស្សជាប់ចោទ ដែលមានរូបនៅនេះ ។

គ) ក្រោយសួរចម្លើយពួកយាមគុកងងិតស្ងាត់ នៅមន្ទីរក្រុមព្រះនគរបាលជាតិ ឃើញថាគ្មានឈ្មោះណាមួយបានដឹងអំពីរឿង ធ្វើទុក្ខបុកម្នេញ, នោះតើព្រះតេជព្រះគុណធ្វើដូចម្ដេច ឲ្យគ្នាហ៊ានឆ្លើយឲ្យការណ៍ពីចៅហ្វាយនាយ ដែលនៅក្នុងងារនៅឡើយ ។

ឃ) ឃើញថា សាក្សីជាច្រើននាក់ ដែលជាអ្នកនៅផ្ទះជិតខាងនូ-យ៉ា បានឲ្យការណ៍ថា ឃើញចៅ-ស៊ុន ទៅផ្ទះនូ-យ៉ា, សាក្សីទាំងនេះសុទ្ធតែ ត្រូវគេចាប់យក

មកដាក់គុកងងឹត វាយដំធ្វើទុក្ខធ្វើបាប រួចដោះលែងយកមកឲ្យធ្វើជាសាក្សី ឆ្លើយដាក់លើថៅ-ស៊ុន តែនៅពេលនោះ គ្រោះជាគ្មានឈ្មោះណា ឲ្យការម៉ឹងម៉ាត់សោះឡើយ ។

## សេចក្ដីសង្ខេប

ឯ. ឌ. កុសល ជាអគ្គលេខាធិការនៃគណបក្សដំកើងប្រជាជាតិ កាលណោះធ្វើជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានបង្គាប់ឲ្យលោកសុភាចារបុរស ចាត់ឲ្យក្រុមព្រះនគរបាលជាតិសួរចម្លើយមនុស្ស ត្រូវចោទមិនទុកស៊ើបសួរខ្លួនឯង នេះជាសេចក្ដីល្មើសនឹងបញ្ញត្តិច្បាប់បច្ចុប្បន្ន អំពីការចាត់ចែងឲ្យស៊ើបសួរ ។

តាមលទ្ធិច្បាប់ ដាឡូស ថ្មី (Répertoyre Dalloge) ឆ្នាំ១៩៤៧ ទំព័រ៥៦០ ។

ប្រការ២ អំពីបទឧក្រិដ្ឋ ។

១៧-ក).........................................................................................

ខ- ១) សុភាចារបុរសនឹងចាត់ឲ្យសួរចម្លើយបាននោះ ចាត់បានតែថៅក្រម ។

តាមលទ្ធិច្បាប់ ដូណ្ណឺយឺ ដឺ វ៉ាប្រិ (Donnedieu De Vabres) ឆ្នាំ១៩៤៧ ទំព័រ ៧៤៨ លេខ១៣០២ ។

បញ្ញត្តិចុះថ្ងៃទី២៥ មិនា.............................................................................
ដែលបើកសិទ្ធិឡើងវិញ ឲ្យចាត់ក្រុមព្រះនគរបាលយុត្តិធម៌ ឲ្យធ្វើអង្កេតស៊ើបសួរបានគ្រប់ជំពូក វៀរលែងតែសួរយកចម្លើយមនុស្សត្រូវចោទ ។

តាមក្រមពិភាក្សាឧក្រិដ្ឋរបស់ អេចែន ការប៉ង់ចេរ (Etienne Carpentier) ចុះថ្ងៃទី១ វិច្ឆិកា ១៩៤៧ ទំព័រ៩ លេខ៩ ។

ខ- ២) សុភាចារបុរសអាចចាត់ក្រុមព្រះនគរបាលយុត្តិធម៌បាន វៀរលែងតែពីការយកចម្លើយរបស់មនុស្សត្រូវចោទ (ក.ភ.ឧ.ស. ៩-១០៣-៤៦៤) ។

ដើម្បីឲ្យឃើញថា ត្រូវការចាត់ឲ្យក្រុមព្រះនគរបាលជាតិសួរយកចម្លើយមនុស្សត្រូវចោទខ្លាំងណាស់ នោះលោកសុភាចារបុរសចង្អុលថា បានឃើញសំបុត្រលេខ៥០ ចុះថ្ងៃ១៩ មករា ១៩៥០ អំពីកុម្មីស្សែរផ្នែកទី២ ប៉ូលិសក្រុង ។ ឯសំបុត្រនោះគឺនិយាយអំពី បញ្ជូនរូបឯ. ឌ. អៀវ-កើស ដែលមានរបួសនៅមន្ទីរពេទ្យព្រះកេតុមាលាទេតើ ? សំបុត្រនេះគ្មានទាក់ទងអ្វីនឹងការស៊ើបសួរទេ ។

បើនិយាយពីលទ្ធិច្បាប់វិញ សេចក្ដីកត់ហេតុដែលលោកតាន់-គិមតិក ជានាយក្រុមព្រះនគរបាលជាតិ ជាមុខការក្រុមព្រះនគរបាលយុត្តិធម៌ ដោយមានដីការចាត់ខាងលើនេះ នោះត្រូវទុកសេចក្ដីកត់ហេតុនេះ ជាអសារឥតការ តាមផ្លូវស៊ើបសួរ ។

ប៉ុន្តែមានករណីមួយ គឺសេចក្ដីកត់ហេតុដែលថាចុះថ្ងៃ១៥-១-៥០ ពីម៉ោង១៥

និង៣០នាទី ដែលលោកតាន់-គីមតិក ខាងក្រុមព្រះនគរបាលជាតិ និងលោកសេង ទិប ខាងក្រុមប៉ូលិសក្រុង បានធ្វើឡើងវិញជាមួយគ្នា ពីម៉ោង២០ដល់ម៉ោង២៤នៅមន្ទីរកុម្មីស្សែរផ្នែកទី២ ។ សេចក្ដីកត់ហេតុនេះធ្វើជំនួសសេចក្ដីកត់ហេតុ ដែលលោកតាន់-កែមឡុងបានធ្វើជាមួយលោកជា-ឡុង ក្នុងរវាងម៉ោង១៥និង៣០នាទី ទៅដល់ម៉ោង១៨ (ដែលបំបាត់ទៅហើយនោះ) ។

ឯសេចក្ដីកត់ហេតុ ដែលក្រុមព្រះនគរបាលយុត្តិធម៌បានធ្វើនោះ គ្រាន់តែទុកជាពត៌មានប៉ុណ្ណោះទេ ។

ចុះសេចក្ដីកត់ហេតុដែលបានធ្វើជំនួស ដើម្បីផ្លាស់ប្ដូរចម្លើយឲ្យប្លែកពីគ្នានោះ នឹងទុកជាពត៌មានដូចម្ដេច ? ។

ចុះសេចក្ដីកត់ហេតុ ដែលធ្វើឡើងដោយការបង្ខិតបង្ខំ (ឃុំឃាំងក្នុងទីស្ងាត់ហួសកំណាត់ច្បាប់) គ្មានបង្គាប់អំពីលោកសុភាចារបុរស គ្មានសេចក្ដីយល់ព្រមពីអ-យ្យកា ចំណែកចៅ-ស៊ុន ១២៤ថ្ងៃ, ចំណែកឃុន-លុត ៩៤ថ្ងៃ និងទុកជាពត៌មានដូចម្ដេច ?

ឯ. ឱ.កុសល បំភ័ន្តក្រុមសង្គហៈព្រះរាជវង្សានុវង្ស ដើម្បីឲ្យបានអនុញ្ញាតចោទប្រកាន់ទៅលើព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ជាកូនក្ដីរបស់ខ្ញុំ ដោយធ្វើសេចក្ដីរាយការណ៍ ទំនងពូតផ្សែងជាដុំ ផ្លុំឆេះជាភ្លើង បិទបាំងកិច្ចការដែលធ្វើទាស់ខុសនឹងរបៀបច្បាប់ និងអំពើដែលក្រុមព្រះនគរបាលជាតិបានប្រព្រឹត្តចូលជាបទឧក្រិដ្ឋ ដើម្បីបង្ខិតបង្ខំឲ្យឆ្លើយទទួលនឹងឆ្លើយដាក់គ្នា ដូចបានពោលមកខាងលើនេះ ។

ដែលឯ. ឱ. កុសល ស្មានថា ត្រូវតែធ្វើដូច្នេះទើបបាន នោះគួរឲ្យស្ដាយក្រោយពន់ពេកណាស់, ព្រោះជាអំពើនាំឲ្យអ្នកផង បូញមាត់ពេបជ្រាយដល់តុលាការខ្មែរ ។

សាលាក្រុងចោទ សអង្គហេតុក្នុងសានក្រមដែលបញ្ជូនរឿងក្ដីនេះឲ្យទៅសាលាឧក្រិដ្ឋជំនុំជំរះ ៖

បានការពារឯ. ឱ. កុសល កាលណោះធ្វើជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ថាសេចក្ដីដែលខ្ញុំបន្ទោសនោះមិនត្រឹមត្រូវទេ ។ ថាដែលខ្ញុំសំអាងដល់នីតិសាស្ត្រ ដាឡូស, ដូណ្ណឺយ៉ឺ ដឺវ៉ាប្រេនឹងអេថៃន កាប៉ង់ចេរ នោះជាអាសារឥតការទេ ។ ថាច្បាប់បារាំងមិនត្រូវយកមកប្រើក្នុងតុលាការខ្មែរទេ ។

មាត្រា៥៤ ក.ភ.ព.ទ. អំពីការសួរចម្លើយសាក្សីសំដែងថា ៖ «ក្រុមព្រះនគរបាលយុត្តិធម៌ ក៏មានអំណាចសួរកត់ចម្លើយសាក្សី...» ។

មាត្រា១៤៤ ក.ភ.ព.ទ. សំដែងថា ៖ «បើសាក្សីនៅទីតំបន់ណាមួយ ក្រៅពីនាទីសាលានោះ សុភាចារបុរសនឹងចាត់ភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ ឲ្យសួរក

ត់យកចម្លើយសាក្សីនោះក៏បាន...» ។

មាត្រា១៨៥ ក.ភ.ព.ទ. សំដែងថា ៖ «ក្រៅអំពីកិច្ចការសួរសាក្សីនោះ សុភាចារបុរសត្រូវសំរេចកិច្ចការផ្សេងៗទៀត...» គឺសួរចម្លើយមនុស្សត្រូវចោទ និង...» ។

មាត្រានេះពុំបាននិយាយ ការចាត់ឲ្យក្រុមព្រះនគរបាលយុត្តិធម៌ ឲ្យសួរចម្លើយអំពីមនុស្សត្រូវចោទទេ ។

កាលណាច្បាប់ខ្មែរ មានសេចក្តីមិនច្បាស់លាស់ ឬមិនគ្រប់គ្រាន់ទេ នោះមានចៅក្រមខ្មែរណាដែលមិនព្រមយកលទ្ធិច្បាប់បារាំងមកបញ្ជាក់ ?

បើចំពោះក្នុងរឿងនេះ សាលាក្រុមចោទយល់ថា មិនត្រូវពិគ្រោះមើលនីតិសាស្ត្របារាំងទេ, ត្រូវតែយើងដុតបណ្ណាល័យច្បាប់សាលាវិនិច្ឆ័យ និងបុយរ៉ូលោកទីប្រឹក្សាច្បាប់ចោលឲ្យអស់ទៅ ហើយជំរាបលោកឲ្យបានជ្រាបថា «ពួកយើងលែងត្រូវការនឹងលោកទៀតហើយ» ។

សាលាក្រុមចោទ បានការពារលោក តាន់-គឹមតិក នាយក្រុមព្រះនគរបាលជាតិថា ដែលកូនក្តីរបស់ខ្ញុំអះអាងអំពីការវាយដំធ្វើទុក្ខបុកម្នេញមិនបានការ ៖

១- ដោយហេតុថា គ្មានសាក្សីណាមួយបានឃើញអ្នកណាវាយមនុស្សត្រូវចោទ ។

២- ដោយហេតុថា គ្មានឃើញរបួសស្លាកស្នាមលើរូបមនុស្សទាំងនេះ ។

អយ្យការក៏ការពារសេចក្តីយល់ឃើញរបស់ក្រុមចោទ ។

មន្ទីរក្រុមព្រះនគរបាលជាតិ មិនមែនជាទីផ្សារឬកន្លែងកាស៊ីណូ ដែលគេចូលរហេតរហូតបាន ដើម្បីធ្វើជាបន្ទាល់សាក្សីនោះទេ, គឺជាគ្រឹស្ថានសាធារណៈមួយគួរឲ្យស្ញប់ស្ញែង, កាលគេបានចូលទៅ តែងព្រឺក្បាលសំពោងព្រលឹងនៅចុងសក់។ នៅក្នុងគុកងងឹត តើនឹងរកសាក្សីពីណាបាន ។

ធ្វើដូចម្តេច នឹងបង្ហាញរបួសស្លាកស្នាមកើត ៖

បើលោកតាន់-គឹមតិក មិនព្រមអនុញ្ញាតឲ្យគ្រូពេទ្យ ពិនិត្យរូបមនុស្សត្រូវចោទ តាមសេចក្តីសុំរបស់លោកមេធាវី គង់-ម៉ង់ ជាសហភាតរៈរបស់ខ្ញុំ ហើយថាដែលសុំឲ្យពិនិត្យមើលរាងកាយនោះ ជាការឥតប្រយោជន៍ ដោយលោកបានពិនិត្យដោយខ្លួនឯង គ្មានបានឃើញស្នាមរបួសស្លាកស្នាមអ្វីសោះ ។

ខ្ញុំមានកូនម្នាក់ កាលពីដើមធ្វើនៅព្រះនគរបាលដែរ កាលមួយថ្ងៃកូននោះបាននិយាយអួតប្រាប់ខ្ញុំថា «ប៉ាខ្ញុំចេះរបៀបវាយមិនឲ្យឃើញមានរបួសស្លាកស្នាម» ។

ខ្ញុំបានប្រាប់ទៅកូនវិញថា «កូនប្រយ័ត្នមានកម្មពៀរវេរា» ។

សាលាក្រុមចោទបានបន្ទោសខ្ញុំថា នាំឲ្យយឺតយូរការ ។

ឯការយឺតយូរនេះ មកតែពីក្រុមព្រះនគរបាលជាតិទុកសំណុំរឿងតាំងពីថ្ងៃទី

១៦ មករា ដល់ថ្ងៃទី១៦ ឧសភា ១៩៥០ រួមជា៤ខែ ។

# សូមជំរាបតុលាការ

ចុះបទឧក្រិដ្ឋនេះ កើតឡើងអំពីសាហេតុអ្វី ?

ខ្ញុំជឿជាក់ថា ព្រះតេជព្រះគុណទាំងអស់ មូលមាត់ជាមួយនឹងខ្ញុំថា មិនមែនកើតឡើង ៖

ដោយកម្លាំងកំហឹងជ្រុលពេក,

ដោយសេចក្ដីស្នេហា,

ដោយសេចក្ដីប្រច័ណ្ឌ,

ដោយអាការស្រវឹង,

ឬដោយសេចក្ដីល្មោភធនធាន

បណ្ដាលចិត្តពួកដែលសមគំនិតនឹង នូ-យ៉ា បង្គាប់ឲ្យប្រព្រឹត្តបទល្មើសទេ គឺកើតឡើងដោយសេចក្ដីគំនុំគុំគួនព្យាបាទ ។

ប៉ុន្តែពុំមែនសេចក្ដីគុំគួនព្យាបាទផ្ទាល់ខ្លួន; គឺសេចក្ដីគុំគួនព្យាបាទខាងផ្លូវនយោបាយ ។

យើងត្រូវតែរករឿងនេះ ក្នុងផ្លូវនយោបាយវិញ គឺយើងត្រូវរកហេតុផល អំពីមនុស្សដែលមានលាយឡំក្នុងរឿងនេះ ។

ចុះអំពើខាងផ្លូវនយោបាយដូចម្ដេច ដែល ឯ. ឧ. អៀវ-កើស ឬពួកតំណាងរាស្ត្រខាងគណបក្សប្រជាធិបតេយ្យបានធ្វើ បណ្ដាលឲ្យព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ និងចៅ-ស៊ុន, ឃួន-លុត ដែលជាប់ចោទជាមួយគ្នា ធ្វើឃាតកម្ម ឯ. ឧ. អៀវ-កើស ? គឺគ្មានសោះ ។

ចុះអំពើខាងផ្លូវនយោបាយដូចម្ដេច របស់ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ និងពួកសមាជិកសេរីភាព២០នាក់ បានធ្វើចាក់ដោតដល់ ឯ. ឧ. ឬពួកសមាជិកតំណាងរាស្ត្ររបស់លោក ? គឺគ្មានសោះ ។

ចាប់តាំងពីពេលរលាយរដ្ឋសភា គណបក្សប្រជាធិបតេយ្យ និងគណបក្សរាស្ត្រសេរីភាព បានពួតដៃគ្នាតទល់នឹងសត្រូវរួមជាមួយគ្នា ដូចអ្នករាល់គ្នាបានដឹងស្រាប់ ។

ដែលគណៈប្រតិភូ និងពួកសមាជិកគណបក្សប្រជាធិបតេយ្យបានយល់ព្រមជាឯកច្ឆន្ទ អំពីញត្តិរបស់ប្រតិភូនៃគណបក្សរាស្ត្រសេរីភាព នៅពេលដែលជំនុំគ្នានៅមន្ទីរសំណាក់ការគណបក្សប្រជាធិបតេយ្យ ក្នុងថ្ងៃទី១៤ មករា ១៩៥០ មុនពេលគេឃាតកម្ម ជាភស្តុតាងជាក់ស្ដែងស្រាប់ ។

ចុះអំពើនយោបាយដូចម្ដេចរបស់ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ, ចៅ-ស៊ុន និងឃួន-លុត ដែលជាប់ចោទជាមួយគ្នា ឬតំណាងរាស្ត្រសេរីភាព២០នាក់ ឬពួកសមាជិកគណៈរាស្ត្រសេរីភាពទាំងអស់ បានប្រព្រឹត្តឲ្យឃើញជាក់ស្ដែង ថាជាស្នូ-គ្រូបក្ខពួក ដើម្បីសំរេចទោសប្រហារជីវិត ដែលត្រូវធ្វើតាមសំរេចរបស់ក្រុមធ្វើឃាតកម្ម របស់ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ និងចៅ-ស៊ុន, ឃួន-លុត ? គឺគ្មានសោះ គឺគ្មានដោយដាច់ខាត ។

ដោយឥតមានឯកសារអ្វីមួយជាភស្តុតាងសោះ មានតែចម្លើយឆ្លើយដោយបញ្ចេះ ដោយបង្ខិតបង្ខំធ្វើទុកបុកម្នេញ ដោយស្នាដៃថោកទាបរបស់ក្រុមព្រះនគរបាល ដែលជាអំពើធ្វើ គួរឲ្យមានទោសជាឧក្រិដ្ឋ ដែលគួរឲ្យប្រទេសកាន់លទ្ធិប្រជាធិបតេយ្យខ្មាស់គេ ។

ចៅ-ស៊ុន, ឃួន-លុត និងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ ជាកូនក្ដីរបស់ខ្ញុំពិតជាសុចរិត ។ គឺជាអ្នកទទួលគ្រោះក្នុងផ្លូវកិច្ចកលខាងនយោបាយ ។

ក្រោយបូជាយ័ញ្ញ រូប ឯ. ឧ. អៀវ-កើស គេចង់កំចាត់កំចាយមនុស្សសុចរិតក្រៅពីនោះទៀត ដើម្បីបំពេញចំណង់ដោយសេរី នៃអ្នកនយោបាយ ដែលគេបានស្គាល់រាល់គ្នាហើយ មានចិត្តរំលោភមិនចេះឆ្អែតឆ្អន់សោះ ។

## ដូច្នេះឃើញច្បាស់ថែទថា

គេចង់សម្លាប់ប្រមុខគណៈទាំងពីរ,

គេចង់រំលាយគណៈទាំងពីរគឺ ៖ គណបក្សប្រជាធិបតេយ្យ និងគណៈរាស្ត្រសេរីភាព គឺគណៈតែពីរនេះទេ ដែលមានអ្នកតំណាងក្នុងរដ្ឋសភា ដែលរលាយបាត់ទៅហើយនោះ ។

ទើបថ្មីៗមុននេះបន្តិច ស្រាប់តែខាងក្រុមព្រះនគរបាលជាតិខេត្តកំពង់ឆ្នាំងប្ដឹងឲ្យការណ៍ថា លោកប៊ុន-វង្សវត្តិ លោករស់-សុមិត និងមេធាវីខ្ញុំបានទៅកំពង់ឆ្នាំងជួលមនុស្សមកសម្លាប់ ឯ. ឧ. យ៉ែម-សំបូរ និងលោកតាន់-គីមតិក ។

ចុះគ្រាប់បែកដែលបោះនៅមន្ទីរភោជនាហារ ឌុច-និល និងគេហស្ថាន ឯ. ឧ. ឃួន-ណៃ នោះព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជចោលដែរឬ ?

## សេចក្ដីសន្និដ្ឋានបញ្ចប់

តាមដែលបានពណ៌នាមកហើយនេះ យល់ឃើញថា មិនមានពិរុធនិងវិមុត្តិសង្ស័យលើរូបកូនក្ដីរបស់ខ្ញុំគឺ ៖

ចៅ-ស៊ុន

យួន-លុត
ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ
អំពីបទសមគំនិតធ្វើមនុស្សឃាដដោយចេតនានិងគិតទុកជាមុន លើរូបឯ. ឧ. អៀវ-កើសនោះ គ្មានទេ ។

អំពីបទសមគំនិតក្នុងការបំណាង នឹងធ្វើមនុស្សឃាដខាងលើនេះ ដោយចេតនា និងគិតទុកជាមុន លើរូបលោកង៉េត-ហ៊ាននោះ គ្មានទេ ។

អំពីបទធ្វើជាស្មគ្រគបក្ខពួកតាំងជាក្រុម ដើម្បីនឹងធ្វើមនុស្សឃាដ ក៏គ្មានដែរ ។

## សូមជំរាបតុលាការ

ចំណែកខាងខ្ញុំយល់ឃើញថា រឿងនេះហាក់ដូចជានឹងចប់ត្រឹមប៉ុណ្ណោះ (ខ្ញុំថាហាក់ដូចជាចប់, គឺមិនទាន់ចប់នៅឡើយទេ) ។

ឥឡូវខ្ញុំសូមប្រគល់ភ័ព្វសំណាងរបស់កូនក្តីខ្ញុំទាំង៣លើដៃព្រះតេជព្រះគុណ ព្រះតេជព្រះគុណាក៏យល់ពិតប្រាកដហើយ តាមសតិនិងសម្បជញ្ញៈរបស់ខ្ញុំយល់ជាក់ច្បាស់ តាមឃោបល់ផ្ទាល់ខ្លួនខ្ញុំថា កូនក្តីរបស់ខ្ញុំ ពេញទីសុចរិតទៀងត្រង់មែន ។ ត្រូវតែតុលាការប្រកាសសេចក្តីសុចរិតពិតត្រង់របស់កូនក្តីខ្ញុំនេះ ឲ្យប្រជាជាតិខ្មែរបានដឹងឮទូទៅផង, ព្រោះប្រជាជាតិខ្មែររង់ចាំតែស្តាប់សេចក្តីសុចរិត យុត្តិធម៌របស់តុលាការ ។

ខ្ញុំបានដឹងច្បាស់ថា តុលាការជាចៅក្រមមិនចូលក្នុងផ្លូវគតិ, មានតែត្រឹមត្រូវស្រឡាញ់ស្នេហា ចំពោះសេចក្តីយុត្តិធម៌ នេះហើយដែលខ្ពង់ខ្ពស់ ជាកំពូលលើគំនិតនិងការប្រឆាំងគណបក្ស ។

សេចក្តីសំរេចរបស់តុលាការ មុខជានឹងបានសំរេច ដូចទេព្តាបានសំរេចមកមុនរួចហើយ, មុខជាតុលាការនឹងសំរេចឲ្យចៅ-ស៊ុន, យួន-លុត និងព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ រួចផុតពីសេចក្តីចោទប្រកាន់ ។

ដែលសំរេចដូច្នេះ ពិតជាតុលាការសំរេចដោយសេចក្តីយុត្តិធម៌ ដ៏ឧត្តមជាពុំខាន ។

ភ្នំពេញនៅថ្ងៃទី១៧ សីហា ១៩៥០
ហត្ថលេខា **ម៉ៃត្រេណាង់ដែស្សេ-សមសុន**

# តុលាការ

ក្រោយដែលពិភាក្សាជាងមួយម៉ោង

វិនិច្ឆ័យសេចក្តី

១) កាត់ទោស ប្រហាជីវិតបង់

| | |
|---|---|
| | -នួ-យ៉ា ឃុំខ្លួន |
| លើរូបមនុស្សជាប់ចោទ | -ប៉ុល-សៀង (បាត់ខ្លួន) |
| | -ទេព-សួន (បាត់ខ្លួន) |

ក- ពីបទធ្វើមនុស្សឃាត ដោយចេតនាគិតទុកជាមុនលើរូប ឯ. ឧ. អៀវ-កើស

ខ- ពីបទបំណងធ្វើមនុស្សឃាដដោយចេតនាគិតទុកមុន លើរូបលោកង៉ែត-ហ៊ាន

គ- និងបទ ធ្វើស្ម័គ្របក្ខពួកនិងក្រុមសំរេចឃាដ

២) កាត់ឲ្យរួចខ្លួន ពីបទចោទរៀងខ្លួន

| | |
|---|---|
| ចៅ-ស៊ិន | (ឃុំខ្លួន) |
| ឃួន-លុត | (-ដិ-) |
| ហាន-ច្រិច | (-ដិ-) |
| ឡាំ-សុត | (-ដិ-) |
| ព្រះអង្គម្ចាស់សុទ្ធាវង្ស-នរិន្ទតេជ | (បាត់ខ្លួន) |
| អ៊ុំ-យូវ | (-ដិ-) |
| អ៊ុក-សាយ | (-ដិ-) |
| អ៊ូ-មុំ | (-ដិ-) |
| មៀច-ឆែម | (-ដិ-) |

មេធាវី អ៊ុំ-ផុន សុំកុំឲ្យសំរេចទោសប្រហារជីវិតលើរូប នួ-យ៉ា សុំឲ្យគង់ជីវិតទុកថ្ងៃក្រោយរកហេតុពីពួកមនុស្សសម-គំនិត ដោយបង្គាប់ឲ្យឃើញ ។

មេធាវី សោម-ឃឹម សង្គ្រោះ នួ-យ៉ា ឥតមានតវ៉ាអ្វីទេ ។

~ចប់~